ក្រសួងអប់រំយុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ប្រធានបទ៖ ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

# THE EFFECTIVENESS OF THE IMPLEMENTAION ON 12+4 CURRICULUM AT TEACHER EDUCATION COLLAGE, PHNOM PENH ( PTEC )

ដោយ/By
ទៀង ចាន់សុភាព/Mrs. TIENG CHANSOPHEAP

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ជំនាន់ទី ៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា៖ ២០១៩-២០២០

ក្រសួងអប់រំយុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ប្រធានបទ៖ ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

# THE EFFECTIVENESS OF THE IMPLEMENTAION ON 12+4 CURRICULUM AT TEACHER EDUCATION COLLAGE, PHNOM PENH ( PTEC )

ដោយ/By

ទៀង ចាន់សុភាព/Mrs. TIENG CHANSOPHEAP

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបង្គោល ៖ លោក សៀង វាសនា

គ្រូដឹកនាំរង ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

# សេចក្តីអះអាងរបស់បេក្ខជន

នាងខ្ញុំឈ្មោះ **ទៀង ចាន់សុភាព** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**" សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺពិតជាស្នាដៃស្រាវជ្រាវរបស់នាងខ្ញុំទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីក្នុងឯកសារយោងឡើយ។

និក្ខេបបទខាងលើនេះត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំផ្ទាល់ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២០

**ហត្ថលេខា**

**ទៀង ចាន់សុភាព**

# លិខិតបញ្ជាក់

**លោក សៀង វាសនា** ជាគ្រូដឹកនាំបង្គោល

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **ទៀង ចាន់សុភាព** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២០

......................................................................... .........................................................................

| | |
|---|---|
| **លោក សៀង វាសនា** | **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** |
| គ្រូឧទ្ទេស | នាយក |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧០៤/៧ **អយក.ឧទ**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារុំម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ រីក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ិន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ប៉ៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ លោក/លោកស្រីជាសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុតក្នុងការបង្ហាត់បង្រៀន និងចែករំលែកបទពិសោធន៍ដល់នាងខ្ញុំ ក៏ដូចជាមិត្តភក្តិរួមជំនាន់ទី៧ទាំងអស់គ្នា។ សូមថ្លែងអំណរគុណដល់លោកបណ្ឌិត **សិត សេង** ព្រមទាំងគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិតទាំងអស់នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដែលបានអនុញ្ញាតនិងចូលរួមសហការណ៍ក្នុងដំណើរការប្រមូលទិន្នន័យតាមការបំពេញកម្រងសំណួរដែលធ្វើឱ្យដំណើរការនៃការសិក្សាស្រាវជ្រាវនេះសម្រេចបានលទ្ធផលល្អប្រសើរ និងទាន់ពេលវេលា។

នាងខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **លោក សៀង វាសនា** គ្រូដឹកនាំបង្គោលដែលបានដឹកនាំក្នុងដំណើរការសរសេរនិក្ខេបបទដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃដើម្បីជួយពន្យល់ណែនាំបង្ហាញផ្លូវ និងផ្ដល់នូវចំណេះដឹងដ៏ល្អៗ ព្រមទាំងបទពិសោធន៍នានា ដែលទាំងនេះបានជំរុញធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់នាងខ្ញុំទទួលបានជោគជ័យ និងបញ្ចប់ដោយភាពរលូន។ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់ **ឯកឧត្ដមបណ្ឌិត សៀង សុវណ្ណា** គ្រូដឹកនាំរង ដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ចំណេះដឹង និងចែករំលែកបទពិសោធន៍ដល់រូបនាងខ្ញុំព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី៧ និងមិត្តរួមការងារទាំងអស់ដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ធ្វើឱ្យរូបនាងខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

នាងខ្ញុំសូមថ្លែងនូវការដឹងគុណចំពោះក្រុមគ្រួសារ លោកឪពុក អ្នកម្ដាយ ស្វាមី កូនៗ និងមិត្តភក្ដិទាំងអស់ដែលតែងតែផ្ដល់នូវការគាំទ្រ លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យរូបនាងខ្ញុំបានបន្តការសិក្សារហូតដល់ចប់តាមសេចក្ដីប្រាថ្នា។

ជាទីបញ្ចប់នាងខ្ញុំសូមគោរពជូនពរចំពោះឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ លោក-លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ !*

# មាតិកា

**សេចក្ដីអះអាងរបស់បេក្ខជន** ... i
**លិខិតបញ្ជាក់** ... ii
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ... iii
**សេចក្ដីថ្លែងអំណរគុណ** ... iv
**មាតិកា** ... v
**មូលន័យសង្ខេប** ... 1
**បញ្ជីតារាង** ... 3
**បញ្ជីក្រាហ្វ** ... 4
**បញ្ជីអក្សរកាត់** ... 6
**ជំពូកទី១៖ សេចក្ដីផ្ដើម** ... 7
១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ... 7
១.២ បញ្ហាស្រាវជ្រាវ ... 12
១.៣ គោលបំណងនៃការស្រាវជ្រាវ ... 13
១.៤ សំណួរស្រាវជ្រាវ ... 13
១.៥ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ... 13
១.៦ សារៈប្រយោជន៍នៃប្រធានបទ ... 14
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ... 15
**ជំពូកទី២៖ រំលឹកទ្រឹស្ដី** ... 17
២.១ និយមន័យ ... 18
២.២ ទ្រឹស្ដីពាក់ព័ន្ធនឹងប្រធានបទ ... 18
២.២ ១ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន ... 18
២.២.២ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ... 21
២.៣ ការសិក្សាអប់រំតាមប្រព័ន្ធក្រេឌីត ... 22

២៤ . ទ្រឹស្តីពីបញ្ហាប្រឈម ការអនុវត្តកម្មវិធីសិក្សា....................23
២.៥ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ....................24
២.៦ ការអនុវត្តកម្មវិធីសិក្សា ១២ + ៤ តាមប្រព័ន្ធក្រេឌីត....................25
២.៧ ប្រព័ន្ធក្រេឌីត ម៉ោងសម្រាប់ថ្នាក់រៀន និងម៉ោងសិក្សា....................26
២.៨ គន្លងអាជីពគ្រូបង្រៀននៃប្រទេសកម្ពុជា....................28
២.៩ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន....................29
២.១០ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សទី២១....................32
២.១១ ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ការបង្រៀន....................34
២.១២ ការរៀបចំនូវកិច្ចតែងការបង្រៀន....................35
២.១៣ កម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតសម្រាប់គ្រូនៅប្រទេសសិង្ហបុរី....................35
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**....................37
៣.១ គម្រោងវិភាគ....................37
៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ....................37
៣.៣ ឧបករណ៍ស្រាវជ្រាវ....................38
៣.៣.១ កម្រិតចង្អុលបង្ហាញ....................39
៣.៣.២ កម្រងសំណួរ....................40
៣.៤ ការជ្រើសរើសភាគសំណាក....................43
៣.៥ ការវិភាគទិន្នន័យ....................43
**ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា**....................45
៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរដែលទទួលបានពីការឆ្លើយតបរបស់អ្នកចូលរួមបំពេញកម្រងសំណួរ....................45
៤.១.១ ទិន្នន័យព័ត៌មានទូទៅ....................46
៤.១.២ ទិន្នន័យឆ្លើយតបទៅលើកម្មវិធីសិក្សា....................51

៤.១.៣ ទិន្នន័យឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា (ការបង្រៀននិងរៀននិងសម្ភារៈឧបទេស) ....56
៤.១.៤ ទិន្នន័យឆ្លើយតបទៅលើការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈ....66
៤.១.៥ ទិន្នន័យឆ្លើយតបទៅលើបញ្ហាប្រឈមក្នុងពេលដំណើរការអនុវត្តកម្មវិធីសិក្សា ....76
៤.២ ការពិភាក្សាទៅលើលទ្ធផលរបស់អ្នកឆ្លើយតប....79
**ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**....85
៥.១ សន្និដ្ឋាន ....85
ក. ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា....85
ខ. បញ្ហាប្រឈមនៅក្នុងការអនុវត្តកម្មវិធីសិក្សារបស់ក្រុមគ្រូឧទ្ទេស និងគរុនិស្សិត ....86
៥.២ សំណូមពរ ....87
ក. វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ....88
ខ. គ្រឹះស្ថានបណ្តុះបណ្តាលក្រោយៗដែលនឹងក្លាយខ្លួនជាវិទ្យាស្ថានគរុកោសល្យគួរត្រៀមខ្លួនទៅលើចំណុចមួយចំនួនដូចជា៖....89
គ. ក្រសួងអប់រំ យុវជន និងកីឡា ....90
**ឯកសារយោង**....91
**ឧបសម្ព័ន្ធ**....96
ឧបសម្ព័ន្ធ (ក) ៖ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស ....97
ឧបសម្ព័ន្ធ (ខ) ៖ កម្រងសំណួរសម្រាប់គរុនិស្សិត....105
ឧបសម្ព័ន្ធ (គ) ៖ កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធាន ....111
ឧបសម្ព័ន្ធ (ឃ) ៖ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ....120
ឧបសម្ព័ន្ធ (ង) ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះប្រមូលទិន្នន័យ ..128
ឧបសម្ព័ន្ធ (ច) ៖ លិខិតឧទ្ទេសនាមនិស្សិត ចុះប្រមូលទិន្នន័យតាមរាជធានីខេត្ត/ក្រុង ....130
ឧបសម្ព័ន្ធ (ឆ)៖ លិខិតឧទ្ទេសនាមចាត់តាំងជាគ្រូដឹកនាំ និងគ្រូដឹកនាំរង ....131

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការអភិវឌ្ឍគុណភាពគ្រូបង្រៀន និងគុណភាពវិស័យអប់រំ ។ ទន្ទឹមនឹងនេះផង ក្រសួងក៏បានធ្វើកំណែទម្រង់លើការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីឆ្លើយតបតាមរយៈការជំរុញឱ្យមានការកែប្រែកម្មវិធីសិក្សា ដើម្បីឱ្យសមស្របតាមតម្រូវការជាក់ស្តែង និងបញ្ហាប្រឈមនានា ព្រមទាំងចូលរួមចំណែកក្នុងការធ្វើឱ្យប្រព័ន្ធប្រតិបត្តិសាលារៀនមានការផ្លាស់ប្តូររីកចម្រើននិងលើកកម្ពស់ការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ទន្ទឹមនឹងនោះផងដែរ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ក៏បានបន្ថែមកម្មវិធីសិក្សា១២+៤ ក្នុងការបណ្តុះបណ្តាលគ្រូដែលបានអនុវត្តចាប់ពីឆ្នាំ២០១៨កន្លងមក។ ការសិក្សាស្រាវជ្រាវពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ គឺមានគោលបំណងសម្រាប់ស្វែងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ចំណេះដឹងទៅលើជំនាញវិជ្ជាជីវៈគ្រូបង្រៀន ការធានាដល់គុណភាពអប់រំ និងទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគរុនិស្សិតដែលកំពុងសិក្សានៅក្នុងវិទ្យាស្ថានគរុកោសល្យទៅលើការកែទម្រង់ទាំងមូលរបស់វិទ្យាស្ថានគរុកោសល្យ។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលតាមរយៈការប្រើប្រាស់កម្រងសំណួរ Google Form (Online) ដែលបានចូលរួមដោយគណៈគ្រប់គ្រងមានចំនួន០៣នាក់ ប្រធាន/អនុប្រធានមានចំនួន១១នាក់ គ្រូឧទ្ទេសមានចំនួន២១នាក់និងគរុនិស្សិតមានចំនួន៧៩នាក់នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញដោយជ្រើសរើសតាមកម្មវិធីTaro Yamane (១៩៦៧) ជាមួយភាពជឿជាក់៩៥% ។ ទិន្នន័យដែលទទួលបានមានពីរប្រភេទគឺបែបបរិមាណ និងបែបគុណវិស័យ។ ការវិភាគទិន្នន័យទាំងនេះ គឺធ្វើការវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធី Excel ដែលបានបង្ហាញចេញជាភាគរយសម្រាប់ធ្វើការបកស្រាយសម្រាប់បរិមាណវិស័យ និងស្រង់មតិយោបល់ដោយចាត់ជាចំណាត់ថ្នាក់ទៅតាមក្រុមនៃអ្នកឆ្លើយតបទាំងអស់សម្រាប់គុណវិស័យ។

តាមរយៈលទ្ធផលនៃការសិក្សាបានបង្ហាញឱ្យឃើញថា ការអនុវត្តកម្មវិធីសិក្សា១២+៤ ទទួលបានប្រសិទ្ធភាពក្នុងកម្រិតមួយល្អ ដោយសារកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះ សមស្របនឹងសមត្ថភាពឆ្លើយតបនឹងតម្រូវការ និងការពេញចិត្តរបស់គ្រូឧទ្ទេស និងគរុនិស្សិត។ កម្មវិធីសិក្សាថ្មីនេះត្រូវបានរៀបចំឡើងដោយកំណត់នូវវត្ថុបំណងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ជាពិសេសផ្តល់នូវភាពបត់បែនសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិតមានការបត់បែនម៉ោងសិក្សាទៅតាមលទ្ធភាពជាក់ស្តែង ដែលខុសពីកម្មវិធីសិក្សាតាមប្រព័ន្ធចាស់(១២+២)។ លើសពីនេះ កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះ បានបណ្តុះបណ្តាលគរុនិស្សិតឱ្យទទួលបានចំណេះដឹង និងជំនាញចាំបាច់ (ជំនាញទន់) ដូចជាភាពជឿជាក់ ការសហការ និងការដោះស្រាយបញ្ហាជាដើម។ ជំនាញទន់ទាំងនេះគឺចាំបាច់និងមានសារៈសំខាន់ណាស់បំផុតដល់គរុនិស្សិតនៅក្នុងជីវិតប្រចាំថ្ងៃ ដែលទាំងនេះជាគោលបំណងមួយនៃកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីត ហើយក៏ជាចំណុចពិសេសខុសប្លែកពីកម្មវិធីសិក្សាពីមុនផងដែរ។ ទន្ទឹមនឹងការរីកចម្រើនមួយចំនួនរបស់គរុនិស្សិត កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត នេះបានផ្តល់ឱកាសគ្រូឧទ្ទេស បង្កើននូវចំណេះដឹង វិធីសាស្ត្របង្រៀនថ្មីៗ របៀបរៀបចំកម្មវិធីសិក្សា និងជំនាញស្រាវជ្រាវជាដើម។

ដោយឡែកនៅក្នុងការអនុវត្តកម្មវិធីសិក្សានេះ ក៏ជួបនូវបញ្ហាប្រឈមមួយចំនួនទាំងគ្រូឧទ្ទេស និងគរុនិស្សិតផងដែរ។ បញ្ហាប្រឈមទាំងនោះ រួមមាន កម្មវិធីសិក្សាមួយចំនួននៅមិនទាន់សមស្រប ខ្លឹមសារនិងវិធីសាស្ត្របង្រៀននៅមានកម្រិត ចំណាយពេលវេលាច្រើន កង្វះខាតសម្ភារៈឧបទេស និងឯកសារបង្រៀនជាភាសាខ្មែរជាដើម។ ដើម្បីការអនុវត្តកម្មវិធីសិក្សាទទួលបានប្រសិទ្ធភាពខ្ពស់ លុះត្រាតែបញ្ហាប្រឈមខាងលើ នេះត្រូវបានឆ្លើយតប។

# បញ្ជីតារាង


តារាងទី 1៖ តារាងស្ថិតិបុគ្គលិកអប់រំ (២០១៩-២០២០) ........................................................ 24

តារាងទី 2 ៖ តារាងស្ថិតិគរុសិស្ស/គរុនិស្សិត (២០១៩-២០២០) .................................................. 24

តារាងទី 3 ៖ រចនាសម្ព័ន្ធ .............................................................................................. 26

តារាងទី 4 ៖ បំណែងចែកក្រេឌីតសិក្សា (១៣០) ក្នុងរយៈពេល៤ឆ្នាំ ............................................ 27

តារាងទី 5 ៖ ភាគសំណាកដែលត្រូវបានជ្រើសរើសក្នុងការសិក្សាស្រាវជ្រាវ ................................... 43

តារាងទី 6 ៖ ចំនួនសំណាកអ្នកចូលរួមក្នុងការបំពេញកម្រងសំណួរ .............................................. 46

តារាងទី 7 ៖ អាយុអ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ .................................................... 46

តារាងទី 8 ៖ បទពិសោធន៍អ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ ............................................. 47

តារាងទី 9 ៖ បទពិសោន៍អ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ .............................................. 48

តារាងទី 10 ៖ ចំណេះដឹងភាសាបរទេស(ភាសាអង់គ្លេស) ........................................................ 49

# បញ្ជីក្រាហ្វ


ក្រាហ្វទី 1៖ កម្រិតពេញចិត្តទៅនឹងការអនុវត្តកម្មវិធីសិក្សា ........ 51

ក្រាហ្វទី 2៖ កម្រិតសមស្របក្នុងការកំណត់វត្ថុបំណងទៅតាមឯកទេសនីមួយៗ ........ 52

ក្រាហ្វទី 3៖ កម្រិតសមស្របទៅនឹងចំណេះដឹង សមត្ថភាពរបស់គ្រូឧទ្ទេស និងគរុនិស្សិតទៅនឹងការអនុវត្តកម្មវិធីសិក្សា ........ 53

ក្រាហ្វទី 4៖ កម្រិតយល់ដឹងរបស់គ្រូឧទ្ទេសចំពោះកម្មវិធីសិក្សាថ្មី និងបំណែងចែកកម្មវិធីសម្រាប់បង្រៀន..54

ក្រាហ្វទី 5៖ កម្រិតការយល់ដឹងអំពីទស្សនៈវិស័យលើការលើកម្ពស់គុណភាពបង្រៀននិងរៀន ........ 55

ក្រាហ្វទី 6៖  កម្រិតងាយស្រួលក្នុងការផលិតសម្ភារៈឧបទេស ........ 56

ក្រាហ្វទី 7៖ កម្រិតងាយស្រួលក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀនជាប្រចាំ ........ 57

ក្រាហ្វទី 8៖ កម្រិតងាយស្រួលក្នុងការបង្រៀននិងរៀន ........ 58

ក្រាហ្វទី 9៖ កម្រិតយល់ដឹងអំពីការបង្រៀនតាមរយៈការបង្កើតសម្ភារៈឧបទេសសិក្សាសំបូរបែប ........ 59

ក្រាហ្វទី 10៖ កម្រិតយល់ដឹង និងអនុវត្តបច្ចេកទេសបំផុសគំនិតផ្សេងៗ ក្នុងការបង្រៀន ........ 60

ក្រាហ្វទី 11៖  កម្រិតក្នុងការប្រើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព ........ 61

ក្រាហ្វទី 12៖  កម្រិតភាពជឿជាក់លើការបង្រៀនប្រកបដោយប្រសិទ្ធភាព ........ 62

ក្រាហ្វទី 13៖ កម្រិតសមស្របក្នុងការអនុវត្តជាក់ស្តែង ........ 63

ក្រាហ្វទី 14៖ កម្រិតឆ្លើយតបជាមួយនឹងតម្រូវការរបស់សិស្ស ........ 64

ក្រាហ្វទី 15៖ កម្រិតវិសាលភាពការបង្រៀនដោយផ្ទាល់ និងដោយប្រយោល ........ 65

ក្រាហ្វទី 16៖ កម្រិតទំនួលខុសត្រូវ (គោរពេលវេលា)....................................................................66

ក្រាហ្វទី 17៖  កម្រិតរៀបចំសមស្របសមត្ថភាព និងពង្រីកវិសាលភាពនៃការបង្រៀននិងរៀន ...............67

ក្រាហ្វទី 18៖ ពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូឧទ្ទេសជាប្រចាំ .......................................68

ក្រាហ្វទី 19៖ កម្រិតប្រើប្រាស់បច្ចេកទេសក្នុងការវាយតម្លៃការបង្រៀន និងរៀន...................................69

ក្រាហ្វទី 20៖ កម្រិតយល់ឃើញអំពីនិរន្តភាពក្នុងការអនុវត្ត...........................................................70

ក្រាហ្វទី 21៖ កម្រិតនៃការទំនាក់ទំនងជាមួយខ្លឹមសារមេរៀនឯកទេស និងវិធីសាស្រ្តផ្សេង..................... 71

ក្រាហ្វទី 22៖ កម្រិតជំរុញ និងលើកទឹកចិត្តគ្រូ-សិស្សក្នុងការចូលរួមជាអតិបរមាក្នុងមេរៀននីមួយៗ .........72

ក្រាហ្វទី 23៖ កម្រិតងាយស្រួលក្នុងការប្រើបច្ចេកទេសក្នុងការវាយតម្លៃការសិក្សារបស់សិស្ស..................73

ក្រាហ្វទី 24៖ កម្រិតចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាពតាមរយៈ ការសង្កេត និងការវាយតម្លៃ..........................................................................................................74

ក្រាហ្វទី 25៖ កម្រិតក្នុងចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាលដល់បុគ្គលិកវិទ្យាស្ថាន ....................75

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| PTEC | : | Phnom Penh Teacher Education College |
| NIE | : | National Institute of Education |
| ESP | : | Education Sector Plan |
| JICA | : | Japan International; Cooperation Agency |
| VVOB | : | VVOB Cambodia Education for Development |
| ICT | : | Information and Communication Technology |
| UNESCO | : | United Nation Educational Scientific and Cultural Organization |

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាមានការបណ្តុះបណ្តាលគ្រូច្រើនកម្រិតដោយស្ថានភាពការអប់រំមុនពេលប្រទេសកម្ពុជាក្លាយជាអាណាព្យាបាលបារាំងនៅឆ្នាំ១៨៦៣ ការអប់រំតាមបែបប្រពៃណីនៅកម្ពុជាត្រូវបានគ្រប់គ្រងដោយវត្តអារាមក្នុងតំបន់ (វត្ត) ហើយព្រះសង្ឃគឺជាគ្រូបង្រៀន (Clayton, 1995)។ ខ្មែរបុរាណយោងទៅតាមលោកគង់ ប៊ុនឈឿន តែងតែនាំកូនៗរបស់ពួកគេជាពិសេសបុរសមកទទួលការអប់រំពីព្រះសង្ឃនៅសាលារៀនវត្ត (Kong, B. 2001 & 2003) ។

នៅសតវត្សទី១៩និងពាក់កណ្តាលទី១នៃសតវត្សទី២០សាលាវត្តគឺជាប្រភពដ៏សំខាន់នៃប្រព័ន្ធអប់រំនៅកម្ពុជាក៏ប៉ុន្តែសាលាវត្តទាំងនោះនៅមិនទាន់អាចផ្តល់នូវការអប់រំតាមបែបទំនើបបាននៅឡើយទេ (ហង់ ជួនណារ៉ុន, ២០១៦)។ នៅដើមសតវត្សរទី២០សាលារដ្ឋផ្លូវការបារាំង-ខ្មែរត្រូវបានបង្កើតឡើងបន្ទាប់ពីមានការរីកចម្រើននូវចំនួនសាលាផ្លូវការបារាំង-ខ្មែរ និងបង្កើតសាលាគរុកោសល្យមួយនៅក្នុងសាលាអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលគេហៅថាឧបសម្ព័ន្ធអនុវិទ្យាល័យព្រះស៊ីសុវត្ថិ (យ៉ង ជី និងស៊ន សំណាង, ១៩៩៨)។ នៅឆ្នាំ១៩៣៥ រយៈពេលនៃការបណ្តុះបណ្តាលគរុសិស្សប្រព្រឹត្តទៅរយៈពេល៤ឆ្នាំ និង១ឆ្នាំទៀតសម្រាប់មុខវិជ្ជាគរុកោសល្យ (យ៉ង ជី និងស៊ន សំណាង, ១៩៩៨)។

នៅឆ្នាំ១៩៤២ផ្នែកគរុវិជ្ជាបានបែកចេញពីវិទ្យាល័យស៊ីសុវត្ថិហើយត្រូវបង្កើតជាសាលាគរុកោសល្យដាច់ដោយឡែកដែលមានរយៈពេលរៀន៥ឆ្នាំដដែល។ នៅខែកក្កដាឆ្នាំ១៩៥៩ សាលាគរុកោសល្យបានប្រែក្លាយជាវិទ្យាស្ថានជាតិគរុកោសល្យវិញតាមព្រះរាជក្រមលេខ៤៣៨ នស ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៥៩ (យ៉ង ជី និងស៊ន សំណាង, ១៩៩៨)។ ក្រៅពីវិទ្យាស្ថានជាតិគរុកោសល្យ នៅមានមជ្ឈមណ្ឌលអប់រំគ្រូបង្រៀនមួយចំនួនទៀតដូចជាមណ្ឌលអប់រំគ្រូនៅកំពង់កន្ទួតបង្កើតឡើងនៅឆ្នាំ១៩៧៥ មណ្ឌលអប់រំគ្រូទន្លេបាទីបង្កើតឡើងនៅឆ្នាំ១៩៦៥ មានតួនាទីសម្រាប់បណ្តុះបណ្តាលគ្រូបឋមសិក្សា (ជា សោភារី និងហ៊ុយ ស៊ីវន, ២០០៧)។ ឆ្នាំ

១៩៦៥ វិទ្យាស្ថានជាតិគរុកោសល្យបានប្រែឈ្មោះជាមហាវិទ្យាល័យទទួលបន្ទុកបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិត១ (គ្រូបង្រៀននៅបឋមសិក្សា) និងគ្រូបង្រៀនកម្រិត២ (គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ)។ នៅឆ្នាំ១៩៧០ រដ្ឋាភិបាលបានបង្កើតសាលាគរុកោសល្យមួយទៀតនៅទីក្រុងភ្នំពេញឈ្មោះថា សាលាគរុវិជ្ជាជាន់ខ្ពស់ទទួលបន្ទុកបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិត៣ គ្រូបង្រៀននៅវិទ្យាល័យ (ជា សោភារី និងហ៊ុយ ស៊ីវន, ២០០៧)។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំកម្ពុជាត្រូវបានរៀបចំ និងស្ដារឡើងវិញដោយគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនសំខាន់ពីរគឺមហាវិទ្យាល័យគរុកោសល្យ និងសាលាគរុវិជ្ជាជាន់ខ្ពស់។ មហាវិទ្យាល័យគរុកោសល្យពេលនោះមានឈ្មោះថាសាលាគរុកោសល្យ និងវិក្រិតការមជ្ឈឹម បន្ទាប់មកមានឈ្មោះសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំសម្រាប់បណ្ដុះបណ្ដាលកម្មាភិបាលគ្រប់គ្រងអប់រំ។ បច្ចុប្បន្នសាលានេះមានឈ្មោះថា វិទ្យាស្ថានជាតិអប់រំ ចំណែកសាលាគរុវិជ្ជាជាន់ខ្ពស់វិញមានតួនាទីបណ្ដុះបណ្ដាលគ្រូបង្រៀនមធ្យមសិក្សាកម្រិត២ (គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ) និងគ្រូបង្រៀនមធ្យមសិក្សាកម្រិត៣ (គ្រូបង្រៀននៅវិទ្យាល័យ) បច្ចុប្បន្នសាលានេះមានឈ្មោះថាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៣)។ បន្ទាប់មក សាលាគរុកោសល្យ និងវិក្រឹតការរាជធានី/ខេត្ត ត្រូវបានបង្កើតឡើង និងប្រែក្លាយជាសាលាបណ្ដុះបណ្ដាលគ្រូកម្រិតទី១ក្នុងឆ្នាំ១៩៨៣។ ជាមួយគ្នានេះ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បានបង្កើតឡើងនៅឆ្នាំ១៩៨៤ មានភារកិច្ចបណ្ដុះបណ្ដាលបណ្ដាលគ្រូបង្រៀនមធ្យមសិក្សាកម្រិតទី២ (គ្រូមធ្យមសិក្សាបឋមភូមិ)។

ប្រទេសកម្ពុជាបានធ្វើការកែទម្រង់វិស័យអប់រំចាប់តាំងពីឆ្នាំ២០១២រហូតមកដល់បច្ចុប្បន្ន។ រយៈពេលប្រាំឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តនូវការងារចម្បងៗចំនួនប្រាំបីនៅឆ្នាំ២០១៤ និងដំណើរការបន្តនូវកំណែទម្រង់ទាំង១៥ចំណុចចាប់ពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០១៨។ ការកែទម្រង់ទាំង១៥ចំណុចនោះរួមមាន (១)ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២)

ការអភិវឌ្ឍគ្រូបង្រៀន (៣)ការពង្រឹងលើមជ្ឈមណ្ឌលគរុកោសល្យ (៤)ការពង្រឹងលើគុណវុឌ្ឍិគ្រូបង្រៀន (៥) អធិការកិច្ច (៦)ស្វ័យវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (៧)ពង្រឹងការប្រឡងមធ្យមសិក្សាសិក្សាទុតិយភូមិ (៨)កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (៩)សំណង់អគារនិងសម្ភារបូបវ័ន្ត (១០)ការវាយតម្លៃនៅឧត្តមសិក្សា (១១)ការពង្រឹងទៅលើកីឡា (១២)ការពង្រឹងផែនការសកម្មភាពនៃគោលនយោបាយយុវជន (១៣)ការអប់រំបច្ចេកទេស (១៤)ការបង្កើតសាលាជំនាន់ថ្មី និង(១៥)កំណែទម្រង់ និងការបណ្តុះបណ្តាលគន្លងអាជីពសម្រាប់នាយកសាលា (ESP 2014-2018)។

ក្រោយពីការធ្វើការកំណែទម្រង់នេះមកយើងសង្កេតឃើញថាលទ្ធផលសិក្សារបស់សិស្សមានការរីកចម្រើនជាងមុនរួមទាំងការបំពេញការងាររបស់គ្រូផងដែរ។ ជំហ៊ានបន្ទាប់នេះក្រសួងអប់រំបានធ្វើការពង្រឹងទៅការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (School Based management) និងការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតសិក្សា រួមទាំងកម្មវិធីសិក្សានៅតាមសាលាបណ្តុះបណ្តាលគ្រូផងដែរ។ នៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ក្នុងអណត្តិទី៦នេះរាជរដ្ឋាភិបាលកម្ពុជាបានកត់សម្គាល់ឃើញថាការអភិវឌ្ឍធនធានមនុស្សគឺជាចំណុចសំខាន់ដែលជាអាទិភាពទី១ក្នុងការអនុវត្ត។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានកំណត់ចេញផងដែរទៅលើការអនុវត្តទៅ "គុណភាពនៃការអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Quality of Education, Science and Technology)" ដោយផ្អែកលើទៅលើចំណុចអាទិភាពចំនួនប្រាំពីរគឺ (១)ការពង្រឹងទៅលើគ្រូបង្រៀន (២)ការដាក់ចេញនូវវិសាលភាពតាមសាលាទាំងបីកម្រិត (៣)ការពង្រឹងទៅលើការងារអធិការកិច្ចតាមរយៈការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (៤)ពង្រឹងការអប់រំបច្ចេកទេសអប់រំនៅសាលាមធ្យមសិក្សាចំណេះទូទៅ (៥)ការអប់រំជំនាញសម្រាប់ទីផ្សារការងារ (៦)ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និង(៧)ការត្រៀមខ្លួនសម្រាប់ទទួល SEA Game (ESP 2019-2023)។

ដូចនេះសាលាបណ្តុះបណ្តាលគ្រូទាំងអស់បានយកចិត្តទុកដាក់ជាពិសេសលើការអនុវត្តលើមុំទាំងប្រាំដែលក្នុងនោះនៅមុំទី៤ (គុណភាពអប់រំ) បានចែងថា គុណភាពអប់រំត្រូវពឹងផ្អែកទៅលើការវិភាគទៅលើសូចនាករ

ចំនួន០៤គឺៈ (១)គ្រូបង្រៀន (២)កម្មវិធីសិក្សា (៣)សៀវភៅសិក្សា និងសម្ភារៈបង្រៀន និង(៤)អគារសិក្សា សម្ភារៈបំពាក់ និងបរិក្ខារ ដើម្បីជួយឱ្យគរុនិស្សិតទទួលបានចំណេះដឹង និងជំនាញត្រឹមត្រូវ។ បច្ចុប្បន្ននេះនៅមានបុគ្គលិកអប់រំ និងគ្រូបង្រៀនមួយចំនួនពុំមានបទពិសោធន៍ និងពុំបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យជាពិសេសបុគ្គលិកអប់រំដែលកំពុងបង្រៀននៅតាមជនបទ (MoEYS, 2012)។ ជាងនេះទៀតបុគ្គលិកអប់រំមួយចំនួនធំដែលកំពុងបង្រៀន និងមិនបានបង្រៀននៅតាមសាលា មានកម្រិតសិក្សានៅទាបនៅឡើយ និងមានបុគ្គលិកអប់រំតិចតួចដែលមានសញ្ញាបត្របណ្ឌិត (MoEYS, 2011) ។

សព្វថ្ងៃយើងមានគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនចំនួន២៤ ដែលកំពុងដំណើរការបណ្តុះបណ្តាល និងផ្គត់ផ្គង់គ្រូបង្រៀននៅគ្រប់កម្រិតភូមិសិក្សាទូទាំងប្រទេសក្នុងនោះសាលាគរុកោសល្យ និងវិក្រិតការខេត្តចំនួន ១៦ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន០៤ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមចំនួន០១ វិទ្យាស្ថានជាតិអប់រំចំនួន០១ និងវិទ្យាស្ថានគរុកោសល្យរាជធានី/ខេត្តចំនួន០២ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, ផែនការអនុវត្តកម្មវិធីអប់រំ, ២០១៨)។

ការអប់រំនិងបណ្តុះបណ្តាលគ្រូនៅប្រទេសកម្ពុជាមានការកែប្រែជាបន្តបន្ទាប់ដោយការកែប្រែដូច្នេះនៅក្នុងឆ្នាំ ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកំណែទម្រង់ ការគ្រប់គ្រង ការបណ្តុះបណ្តាលក៏ដូចជាកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលនៅសាលាបណ្តុះបណ្តាលគ្រូចំនួនពីរគឺ (១)វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និង(២)វិទ្យាស្ថានគរុកោសល្យបាត់ដំបង ដែលត្រូវបានបង្កើតឡើងដោយបញ្ចូលគ្នារវាងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រិតការ ក្នុងគោលបំណងដើម្បីដំឡើងកម្រិតនៃការអប់រំគ្រូបង្រៀនដោយផ្លាស់ប្តូរប្រព័ន្ធបណ្តុះបណ្តាលគ្រូ ១២+២ ទៅ ១២+៤ (អនុក្រិតលេខ៧៣ អនក្រ. ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧) ។ កំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូនេះ គឺដើម្បីអភិវឌ្ឍន៍គរុនិស្សិតឱ្យក្លាយជាគ្រូបង្រៀនពេញដោយជំនាញវិជ្ជាជីវៈនិងចំណេះដឹងសម្រាប់ទៅបណ្តុះបណ្តាល សិស្សានុសិស្សនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិក្រោយបញ្ចប់ការសិក្សារបស់ខ្លួន។ ក្នុងស្ថានភាពបែបនេះ

យើងឃើញថាគុណភាពនៃការអប់រំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ប៉ុន្តែវាមានលក្ខណៈ ដោយឡែករហូតមកដល់បច្ចុប្បន្ននេះពុំទាន់មានការស្រាវជ្រាវណាមួយដែលបញ្ជាក់ឱ្យឃើញថាក្រោយ ពីការកែទម្រង់នៃការបណ្តុះបណ្តាលក៏ដូចជាការគ្រប់គ្រងវិទ្យាស្ថានទាំងពីរនេះស្តីពីប្រសិទ្ធភាពនៃការអនុវត្តនៅឡើយទៅលើការអនុវត្តរយៈពេលកន្លងមក។

ប្រសិទ្ធភាពនៃការបង្រៀននិងការរៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។ ការកែលម្អគុណភាពអប់រំ គឺអាស្រ័យលើគុណភាពរបស់គ្រូបង្រៀនផ្សារភ្ជាប់ទៅនឹងកម្មវិធីគរុកោសល្យដែលទាមទារគរុនិស្សិតត្រូវឆ្លងកាត់ការរៀនជំនាញឯកទេសលើការអនុវត្តទ្រឹស្តី និងហ្វឹកហាត់ការអនុវត្តកម្មវិធីគរុកោសល្យជាដើម។ ការធានានូវគុណភាពនៃការបង្រៀននិងការរៀននៅតែជាបញ្ហាប្រឈមដែលប្រទេសទាំងអស់កំពុងយកចិត្តទុកដាក់បំផុត (Phin, 2014) ។

ប្រសិទ្ធភាព និងគុណភាពនៃការបង្រៀន ទទួលបានកម្រិតខ្ពស់គឺអាស្រ័យលើកត្តាជាច្រើន។ ក្នុងនោះ ចំណេះដឹងលើឯកទេស និងគុណវុឌ្ឍិរបស់គ្រូ គឺជាកត្តាដ៏សំខាន់និងចាំបាច់បំផុត ដើម្បីជួយសិស្ស ឱ្យទទួលបាននូវចំណេះដឹង និងជំនាញពេញលេញ (Kreber 2002)។ លើសពីនេះ គ្រូមានតែចំណេះដឹងតែមួយមុខមិនទាន់គ្រប់គ្រាន់ទេ ចាំបាច់ត្រូវដឹងពីរបៀបផ្ទេរចំណេះដឹងទាំងនោះទៅឱ្យសិស្សរបស់ខ្លួនថែមទៀត ទើបការបង្រៀនទទួលបានប្រសិទ្ធភាពខ្ពស់ (Kreber 2002, p,9) ។ នេះស្របជាមួយនឹងការលើកឡើងរបស់ លោក Penny (2003) ដើម្បីឱ្យការបង្រៀនទទួលបានប្រសិទ្ធភាពខ្ពស់ជាពិសេសនៅឧត្តមសិក្សា គឺចាំបាច់ត្រូវផ្តោតទៅលើការរៀនរបស់សិស្ស និងចំណុចខ្សោយរបស់ពួកគេ។ បរិយាកាសថ្នាក់រៀនក៏ជាចំណុចមួយជះឥទ្ធិពលដល់គុណភាពនៃការរៀនសូត្ររបស់សិស្សផងដែរ។ ដែលក្នុងនេះ លោក Hativa, Barak and Simhi (2001) លើកឡើងពីប្រសិទ្ធភាពនៃការបង្រៀន ទាក់ទងទៅនឹងចំណុចសំខាន់ៗ ដូចជាការទាក់ទាញចាប់អារម្មណ៍ ភាពច្បាស់លាស់នៃគោលបំណង ការរៀបចំមេរៀនសមស្រប ដែលជំរុញឱ្យមានបរិយាកាសវិជ្ជមានក្នុងបង្រៀននិងរៀនរបស់សិស្ស។ ប៉ុន្តែចំណុចទាំងបួននេះនៅតែមិនអាចបានអនុវត្តបានពេញលេញនៅកម្រិត

ឧត្តមសិក្សា ដោយសារតែភាពស្មុគស្មាញ និងការអនុវត្តរបស់វា។ ដូចនេះ ដើម្បីធានាបាននូវគុណភាពនៃការរៀនសូត្ររបស់សិស្ស គឺតម្រូវឱ្យគ្រូមានជំនាញ ចំណេះដឹង និងការអនុវត្តជាក់លាក់ ដែលសមស្របទៅនឹងតម្រូវការរបស់សិស្ស ទៅតាមបរិបទសង្គមដែលកើតមានឡើង។

## ១.២ បញ្ហាស្រាវជ្រាវ

ដោយសារតែកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនតាមរូបមន្ត ១២+៤ នេះជាកម្មវិធីថ្មីដែលក្រសួងទើបដាក់ចេញឱ្យអនុវត្តនៅវិទ្យាស្ថានគរុកោសល្យពីរ (១)វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និង(២)វិទ្យាស្ថានគរុកោសល្យបាត់ដំបង។ ជាមួយនឹងការកំណែទម្រង់តាមរូបមន្តថ្មី ពីការបណ្តុះបណ្តាលរយៈពេល២ឆ្នាំទៅការបណ្តុះបណ្តាលរយៈពេល៤ឆ្នាំតាមប្រព័ន្ធក្រេឌីតរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(PTEC) អាចនឹងជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលអាចប៉ះពាល់ដល់ការបង្រៀន និងការរៀនរបស់គរុនិស្សិត។ មួយវិញទៀត ដោយយោងទៅលើការសិក្សាស្រាវជ្រាវមួយថ្មី ពីស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យទាំងពីរបានលើកឡើងពី បញ្ហាប្រឈមមួយចំនួនទាក់ទងនឹងក្របខណ្ឌកម្មវិធីសិក្សាកម្មវិធីសិក្សាលម្អិត បរិមាណ និងគុណវុឌ្ឍិគ្រូឧទ្ទេស (ឆាយ បូនី ២០១៩, p 5)។ ដោយហេតុនេះទើបធ្វើឱ្យអ្នកស្រាវជ្រាវផ្តោតការចាប់អារម្មណ៍ ទៅលើការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនេះ ថាតើការអនុវត្តកម្មវិធីសិក្សាថ្មី១២+៤ ទទួលបានប្រសិទ្ធភាពយ៉ាងដូចម្តេច? តើដំណើរការនៃការផ្លាស់ប្តូរការអនុវត្តកម្មវិធីសិក្សាពី១២+២ ទៅ១២+៤ តាមប្រព័ន្ធក្រេឌីតជួបនូវបញ្ហាប្រឈមអ្វីខ្លះ?

លទ្ធផលនៃការសិក្សានេះ នឹងចូលរួមសម្រួលដល់ដំណើរការអនុវត្តនិងការប្រព្រឹត្តទៅរបស់វិទ្យាស្ថាន ឱ្យមានភាពរលូន និងសម្រេចបាននូវបេសកកម្មនិងចក្ខុវិស័យរបស់ខ្លួន ក្នុងការអភិវឌ្ឍគ្រូបង្រៀន ដែលពោរពេញដោយសមត្ថភាពនាពេលអនាគត សម្រាប់ការអភិវឌ្ឍប្រទេសជាតិទាំងមូល។ ដោយឈរលើគោលគំនិតនេះ

អ្នកស្រាវជ្រាវយល់ថា វាពិតជាចាំបាច់ណាស់ក្នុងការធ្វើការសិក្សានេះឡើង ដើម្បីជួយសម្រួលនិងដោះស្រាយបញ្ហាទាំងអស់នេះ។

## ១ ៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាទៅលើ " **ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**" គឺមានគោលបំណងសម្រាប់ស្វែងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងទស្សនៈយល់ឃើញរបស់គរុនិស្សិតដែលកំពុងសិក្សានៅក្នុងវិទ្យាស្ថានគរុកោសល្យទៅលើការកែទម្រង់ទាំងមូលរបស់វិទ្យាស្ថានគរុកោសល្យ ដែលក្នុងនោះរួមមាន៖ សមត្ថភាពគ្រូបង្រៀន ការអនុវត្តកម្មវិធីសិក្សា សម្ភារៈបង្រៀន ដើម្បីយកព័ត៌មានទាំងនេះសម្រាប់ផ្តល់ជូនគណៈគ្រប់គ្រងវិទ្យាស្ថាននេះសម្រាប់ធ្វើការអភិវឌ្ឍនិងកែលម្អដើម្បីទទួលបាននូវការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសិក្សាស្រាវជ្រាវនេះនឹងប្រើប្រាស់សំណួរ

១.តើការអនុវត្តកម្មវិធីសិក្សា១២+៤នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមានប្រសិទ្ធភាពកម្រិតណា?

២.តើបញ្ហាប្រឈមចំពោះការផ្លាស់ប្តូរការអនុវត្តកម្មវិធីសិក្សាពី១២+២ទៅ១២+៤តាមប្រព័ន្ធក្រេឌីតនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញជួបប្រទះបញ្ហាអ្វីខ្លះ?

## ១.៥ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដើម្បីមានការសិក្សាស្រាវជ្រាវទៅលើប្រធានបទបានល្អ និងការវិភាគបានគ្រប់ជ្រុងជ្រោយទៅលើប្រធានបទ៖ **ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ** អ្នកសិក្សាស្រាវជ្រាវបានកំណត់យកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញមកធ្វើការស្រាវជ្រាវ។ ដោយវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះមានការបណ្តុះបណ្តាលគ្រូបង្រៀនទាំង ១២+២ និង ១២+៤ អ្នកស្រាវជ្រាវបាន

កំណត់ជ្រើសរើសសំណាកយកតែអ្នកពាក់ពន្ធ័មួយចំនួនតែប៉ុណ្ណោះគឺៈគណៈគ្រប់គ្រងចំនួន០៣នាក់ (នាយក ០១នាក់ នាយករង០១នាក់ និងនាយិការង០១នាក់) ប្រធាន/អនុប្រធាន ចំនួន១១នាក់ គ្រូឧទ្ទេស ដែលបង្រៀន១២+៤ ចំនួន២១នាក់ និងគរុនិស្សិតបរិញ្ញាបត្រអប់រំជំនាន់ទី១ និងជំនាន់ទី២ (កម្រិតមូលដ្ឋាន ១២+៤)ចំនួន៧៩នាក់ នៃវិទ្យាស្ថានគរុកោសល្យក្នុងឆ្នាំសិក្សា ២០១៨-២០១៩ និងឆ្នាំសិក្សា ២០១៩-២០២០។

## ១.៦ សារៈប្រយោជន៍នៃប្រធានបទ

ដោយសារវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(PTEC) ទើបតែត្រូវបានផ្លាស់ប្តូរពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ ដោយតំឡើងកម្មវិធីបណ្តុះបណ្តាលពី ១២+២ ទៅ ១២+៤ ដល់គរុនិស្សិត ដែលនឹងក្លាយទៅជាគ្រូមធ្យមសិក្សាបឋមភូមិពេលបញ្ចប់ការសិក្សា។ ការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់អត្ថប្រយោជន៍ដូចជា៖ **(១)**សម្រាប់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ(PTEC)ដែលជាគ្រឹះស្ថានស្រាវជ្រាវមួយ៖ ដោយហេតុនេះលទ្ធផលពីការសិក្សានេះអាចដើរតួជាត្រីវិស័យសម្រាប់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេ (PTEC) ដើម្បីមើលឃើញពីបញ្ហាប្រឈមជាក់ស្តែងដែលខ្លួនកំពុងជួបប្រទះ។ បន្ថែមពីនេះទៀត ការសិក្សាក៏នឹងបង្ហាញនូវដំណោះស្រាយជាក់លាក់មួយចំនួន ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ។ ដូចនេះ អាចជាកត្តាមួយជួយឱ្យវិទ្យាស្ថាន អាចដោះស្រាយ និងគ្រប់គ្រងបញ្ហាប្រឈមទាំងអស់នោះបានដោយជោគជ័យ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន ទាំងក្នុងការបង្រៀន និងរៀនរបស់គរុនិស្សិត។ **(២)**ចំពោះក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងគ្រឹះស្ថានអប់រំ៖ ការស្រាវជ្រាវនេះនឹងដើរតួនាទីជាសូចនាករ និងឯកសារការណែនាំសម្រាប់ក្រសួង ដើម្បីចាត់វិធានការណ៍នានា ក្នុងគោលបំណងជួយដល់ការអនុវត្តរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) ដើម្បីឱ្យទទួលជោគជ័យក្នុងការអប់រំរបស់ខ្លួន។ លើសពីនេះទៅទៀត ការរកឃើញចេញពីការសិក្សានេះ ក្រសួង អាចមើលឃើញជាមុននូវរាល់បញ្ហាប្រឈមដែលនឹងអាចកើតមានឡើង និងអាចកំណត់វិធានការណ៍ដ៏សមស្រប ដើម្បីទប់ស្កាត់និងកាត់បន្ថយ ផលវិបាក

ជាអវិជ្ជមានដែលកើតឡើងទាំងនោះបាន។ មិនតែប៉ុណ្ណោះ ក្រសួង អាចអនុវត្តឬប្រើប្រាស់លទ្ធផលនៃការសិក្សានេះ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលគ្រូដទៃផ្សេងទៀត ដើម្បីចៀសវាងបញ្ហាប្រឈមដូចគ្នា ឬប្រហាក់ប្រហែលគ្នា និងដោះស្រាយនូវបញ្ហាប្រឈម និងការខ្វះចន្លោះទាំងនោះឱ្យសមស្របទៅតាមស្ថានភាពជាក់ស្តែង។ និង(៣)ចំពោះអ្នកស្រាវជ្រាវដទៃទៀត៖ ពួកគាត់អាចប្រើប្រាស់លទ្ធផលនៃការសិក្សានេះ ធ្វើជាគោលដើម្បីធ្វើការសិក្សាស៊ីជម្រៅបន្តទៀតលើប្រធានបទស្រដៀងគ្នានេះ ដែលអាចស្វែងរកលទ្ធផល បានកាន់តែស៊ីជម្រៅ និងឈានទៅរកការរកឃើញថ្មីៗ ដែលផ្តល់អត្ថប្រយោជន៍ល្អបំផុត ដល់គ្រឹះស្ថានអប់រំ ដែលជាការរួមចំណែកដ៏សំខាន់ដល់ការអភិវឌ្ឍប្រទេស និងសង្គម។

## ១ ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ស្នាដៃសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗក្នុងនោះរួមមាន៖ **ជំពូកទី១ សេចក្តីផ្តើម៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ **ជំពូកទី២ រំលឹកទ្រឹស្តី៖** នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងប្រមូលយកទ្រឹស្តីពីអ្នកសិក្សាស្រាវជ្រាវមុនៗ និងឯកសារនានាដែលពាក់ព័ន្ធនានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ហើយកំណត់ចំណងជើង និងចំណងជើងរង ដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនេះ ដើម្បីធ្វើជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។ **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីគម្រោងវិភាគ វិធីសាស្ត្រប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ (កម្រិតចង្អុលបង្ហាញកម្រងសំណួរ) វិធីសាស្ត្រក្នុងការវិភាគទិន្នន័យ លក្ខណៈរបស់ភាគសំណាក ។ **ជំពូកទី៤ លទ្ធផលស្រាវជ្រាវ៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងការអនុវត្តកម្មវិធីជាក់ស្តែងរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើសេ

ចក្តីសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងលើកជាសំណូមពរមួយចំនួនទៅកាន់អ្នកពាក់ព័ន្ធ ក្នុងគោលបំណង រួមចំណែកធ្វើឱ្យការអនុវត្តកម្មវិធីសិក្សា១២+៤នៅវិទ្យាស្ថានរាជធានីភ្នំពេញកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ព្រមទាំងជាចំណុចដែលគ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្រោយៗគួរបានគិតគូរធ្វើយ៉ាងណាដើម្បីគ្រឹះស្ថានរបស់ខ្លួនទទួលបានប្រសិទ្ធភាពក្នុងពេលអនុវត្តកម្មវិធីសិក្សានៅពេលក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

វិស័យអប់រំ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងការរីកចម្រើនរបស់ប្រទេស។ ការកែលម្អគុណភាពអប់រំគឺអាស្រ័យលើគុណភាពរបស់គ្រូបង្រៀនផ្សារភ្ជាប់ទៅនឹងកម្មវិធីគរុកោសល្យដែលទាមទារគរុនិស្សិតត្រូវឆ្លងកាត់ការរៀនជំនាញឯកទេសលើការអនុវត្តទ្រឹស្តី និងការហ្វឹកហាត់ការអនុវត្តកម្មវិធីគរុកោសល្យជាដើម។ ប៉ុន្តែការធានានូវគុណភាពនៃការបង្រៀននិងរៀននៅតែជាបញ្ហាប្រឈមដែលប្រទេសទាំងអស់កំពុងយកចិត្តទុកដាក់បំផុត ជាពិសេសប្រទេសកំពុងអភិវឌ្ឍ (Phin, 2014) ។

មានការសិក្សាបានធ្វើស្រាវជ្រាវពីកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការអប់រំ។ លោក(Penny 2003) បានកំណត់ថា ការបង្រៀនប្រកបដោយប្រសិទ្ធភាពគឺជាបង្រៀនដែលផ្តោតការយកចិត្តទុកដាក់ទៅលើការរៀនរបស់សិស្ស និងអ្វីដែលពួកគេនៅខ្វះខាត ។ ស្រដៀងគ្នានេះដែរ លោក Kreber (2002) លើកបន្ថែមក្រៅពីចំណេះដឹងលើឯកទេសរបស់ខ្លួន ទាមទារជំនាញក្នុងការផ្ទេរចំណេះដឹងទាំងអស់នេះ និងការជួយសិស្សឱ្យទទួលបានចំណេះដឹង។ ដើម្បីធានាបាននូវគុណភាពនៃការរៀនសូត្ររបស់សិស្ស តម្រូវឱ្យមានជំនាញនិងការអនុវត្តជាក់លាក់ដែលសមស្របទៅនឹងតម្រូវការនៃបរិបទដែលកើតមានឡើង ។ មានការពណ៌នាច្បាស់លាស់អំពីលទ្ធផលសិក្សារបស់គរុនិស្សិតដោយបញ្ជាក់ពីចំណេះដឹង ជំនាញ និងឥរិយាបថ ដែលគរុនិស្សិតទទួលបាន។ ប្រើវិធីសាស្ត្រ ឧបករណ៍ និងមធ្យោបាយច្រើនយ៉ាងក្នុងការវាយតម្លៃលើការសិក្សារបស់គរុនិស្សិតដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ត្រឹមត្រូវ។ ពិនិត្យ និងកែលម្អឱ្យបានទៀងទាត់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ (វិទ្យាស្ថានគរុកោសល្យ , ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧) ។

ការធ្វើកំណែទម្រង់ប្រព័ន្ធបណ្តុះបណ្តាលគ្រូ ដោយប្តូរពីប្រព័ន្ធនៃការបណ្តុះបណ្តាលពី១២+២ ទៅការបណ្តុះបណ្តាលតាមរូបមន្ត១២+៤ ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការអប់រំគ្រូបង្រៀន ដែលជាសេនាទិកាយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពនៃការអប់រំក្នុងប្រទេសទាំងមូល។ ដូច្នេះការផ្លាស់ប្តូរពីមជ្ឈមណ្ឌល

គរុកោសល្យភូមិភាគ ទៅជាវិទ្យាស្ថានគរុកោសល្យ បានធ្វើឱ្យវិទ្យាស្ថានប្រែក្លាយទៅជាគ្រឹះស្ថានឧត្តមសិក្សា ដោយដំឡើងរូបមន្តនៃការបណ្ដុះបណ្ដាលគ្រូទៅជារយៈពេល៤ ឆ្នាំ បន្ទាប់ពីសិស្សបញ្ចប់ការអប់រំចំណេះទូទៅរយៈពេល១២ឆ្នាំរបស់ខ្លួនរួច។ បន្ទាប់ពីចំណាយពេល ៤ ឆ្នាំ នៅវិទ្យាស្ថានគរុកោសល្យគរុកោសល្យ គរុនិស្សិតនឹងអាចទទួលបានបរិញ្ញាបត្រផ្នែកអប់រំ មុនពេលពួកគេត្រូវបានចេញទៅបង្រៀនតាមអនុវិទ្យាល័យដែលបានកំណត់ទូទាំងប្រទេស។ ដើម្បីធានាប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាលវិទ្យាស្ថានគរុកោសល្យរាជធានីដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់ៗជាច្រើន ដូចជាការកែប្រែកម្មវិធីអប់រំជាប្រព័ន្ធក្រេឌីតជាដើម។ ការសិក្សានេះ នឹងសិក្សាស្វែងយល់ពីការអនុវត្តប្រព័ន្ធក្រេឌីតដោយផ្ដោតទៅលើកត្តាជាច្រើនទៀត។

## ២.១ និយមន័យ

"**ប្រសិទ្ធភាព**" គឺជាអំណាចដើម្បីបង្កើតលទ្ធផលដែលរំពឹងទុក( Wilson, Business Modeling, 2018 )។ "**ប្រសិទ្ធភាព**" មានន័យថាជាប្រតិបត្តិការ ឬ សកម្មភាពមួយ អនុវត្ត សម្រេចបានតាមគោលដៅ និងគោលបំណងរួម ( Account Dictionary 2019 ) ។ "**ប្រសិទ្ធភាព**" គឺសំដៅទៅលើការផ្សារភ្ជាប់គ្នារវាងសកម្មភាព (ឬអន្តរាគមន៍ ) និងលទ្ធផល ដែលចង់បាន( Giusto, 2012 ) ។

## ២.២ ទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ

### ២ ២.១ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន

ប្រសិទ្ធភាពរបស់សាលាត្រូវបានសង្កត់ធ្ងន់ទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស និងលក្ខណះរបស់សាលារៀន និងថ្នាក់រៀនដែលពាក់ព័ន្ធនឹងលទ្ធផលទាំងនេះ។ ក្នុងអំឡុងទសវត្ស១៩៦០ និង ១៩៧០ អ្នកស្រាវជ្រាវជាច្រើនបានអះអាងថា ស្ថានភាពគ្រួសារ សង្គម និងសេដ្ឋកិច្ច គឺជាកត្តាចំបងដែលជះឥទ្ធិពលដល់សមិទ្ធិផលនៃការសិក្សារបស់សិស្សនិងនិស្សិត។ ដោយហេតុនេះអ្នកស្រាវជ្រាវចាប់ផ្ដើមពិនិត្យ ថាតើសាលារៀនអាចជះឥទ្ធិពលយ៉ាងដូចម្ដេចទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស/និស្សិត ដោយមិនគិតពីស្ថានភាពគ្រួសារនិង

សង្គមរបស់ពួកគេ (Kember and Mc Naught 2007) ។ ផ្អែកលើការសិក្សានេះ ១០ គោលការណ៍ ដែលធ្វើឱ្យការបង្រៀននិងរៀនមានប្រសិទ្ធភាពខ្ពស់ (Kember, Ma and Mc Naught, 2006, and Kember and Mc Naught, 2007) ត្រូវបានលើកឡើង ដែលមានដូចជា៖

1. ការបង្រៀននិងការរៀបចំកម្មវិធីសិក្សាចាំបាច់ត្រូវផ្តោតលើការបំពេញតម្រូវការនាពេលអនាគតរបស់សិស្ស ដោយបណ្តុះ និងអភិវឌ្ឍន៍សមត្ថភាពសិស្ស ដូចជាការគិតវិភាគបែបស៊ីជម្រៅ ការធ្វើការជាក្រុម និងជំនាញទំនាក់ទំនងជាមួយអ្នកដទៃ។
2. និស្សិតត្រូវតែមានការយល់ដឹងឱ្យបានហ្មត់ចត់អំពីគោលគំនិតជាមូលដ្ឋានគ្រឹះនៃមេរៀននិងកម្មវិធីសិក្សា
3. ការបង្រៀនត្រូវតែបង្កើតឡើងដោយប្រើឧទាហរណ៍ជាក់ស្តែងផ្សារភ្ជាប់នឹងស្ថានភាពបច្ចុប្បន្ន ដោយសារផ្សារភ្ជាប់ពីទ្រឹស្តីនឹងការអនុវត្តផ្ទាល់។
4. ជំនឿឬគំនិតភាន់ច្រឡំរបស់សិស្ស ត្រូវកំណត់ និងត្រូវបកស្រាយ។
5. កិច្ចការនិងសកម្មភាពសិក្សាត្រូវមានច្រើនប្រភេទ ដែលអាចឱ្យសិស្សាមានការចូលរួម ពិភាក្សា និងដោះស្រាយ ដើម្បីឱ្យការរៀនប្រកបដោយអត្ថន័យកើតមានឡើង។
6. ទំនាក់ទំនងពិតប្រាកដនិងការយល់ចិត្តគ្នាជាមួយសិស្សម្នាក់ៗគួរតែត្រូវបានបង្កើតឡើងដើម្បីឱ្យការបង្រៀនមានអន្តរកម្មកើតឡើងក្នុងថ្នាក់រៀន។
7. គ្រូបង្រៀនគួរតែជំរុញ និងលើកទឹកចិត្តសិស្សតាមរយៈការបង្ហាញភាពរីករាយរបស់គ្រូក្នុងការបង្រៀនលើកទឹកចិត្តសិស្សឱ្យរៀន និងបង្កើតថ្នាក់រៀនដ៏គួរឱ្យចាប់អារម្មណ៍ រីករាយ និងសកម្ម។
8. ការអភិវឌ្ឍកម្មវិធីសិក្សា ត្រូវតែធានាថា គោលបំណង ខ្លឹមសារ សកម្មភាពបង្រៀននិងរៀន និងការវាយតម្លៃការសិក្សា សមស្របទៅនឹង លទ្ធផលនៃការសិក្សា ដែលមានទាក់ទងទៅនឹងតម្រូវការរបស់សិស្សនាពេលអនាគត។

9. មេរៀននីមួយៗត្រូវតែត្រូវបានគ្រោងទុកនិងរៀបចំយ៉ាងហ្មត់ចត់ ប៉ុន្តែអាចបត់បែនបាន។ ដូច្នេះការសម្របសម្រួលចាំបាច់អាចនឹងត្រូវធ្វើឡើងទៅតាមស្ថានភាពជាក់ស្តែងនៅពេលបង្រៀន និងសមត្ថភាពរបស់សិស្ស។

10. ការវាយតម្លៃការសិក្សា ត្រូវតែស៊ីគ្នាជាមួយនឹងលទ្ធផលនៃការសិក្សាដែលចង់បាន។ ដូច្នេះការបង្កើតតេស្តវាយតម្លៃការសិក្សារបស់សិស្ស ជាភារកិច្ចដ៏ចម្បងនៃវិជ្ជាជីវៈគ្រូ។

ប៉ុន្តែការសិក្សាទៅលើប្រសិទ្ធភាពនៃការបង្រៀន និងរៀនដោយផ្អែកលើគោលការណ៍ទាំង១០ខាងលើរបស់លោក Kember និង Mc Naught នៅឆ្នាំ ២០០៧ គឺនៅមានការខ្វះចន្លោះនៅឡើយ។ ដោយសារតែពួកគាត់សិក្សាតែមួយផ្នែក គឺពីគ្រូបង្រៀននៅកម្រិតឧត្តមសិក្សាតែមួយក្រុមប៉ុណ្ណោះ ដោយពុំបានសិក្សាលើអ្នកពាក់ព័ន្ធផ្សេងទៀត ដែលអាចជះឥទ្ធិពលលើប្រសិទ្ធភាពនៃការបង្រៀននិងរៀននោះទេ។ ដោយឡែក លោក Marsh (1994) បានប្រើប្រាស់ធាតុចូលពីប្រភពផ្សេងៗ ដូចជា សិស្ស/និស្សិត និងអ្នកជំនាញអប់រំ ដើម្បីបង្កើតកម្រងសំណួរវាយតម្លៃការបង្រៀននៅកម្រិតឧត្តមសិក្សាបន្ថែមពីលើទស្សនៈរបស់សាស្ត្រាចារ្យ។ ជាមួយគ្នានេះដែរ Martens Lueckenhausen និង Mc Cormack (2004) បានអះអាងថា ដើម្បីធានាបាននូវភាពជឿជាក់នៃការសិក្សាទៅលើការបង្រៀនប្រកបដោយប្រសិទ្ធភាពនៅកម្រិតឧត្តមសិក្សា ត្រូវសិក្សាពីអ្នកពាក់ព័ន្ធជាច្រើន ដែលរួមទាំងនិស្សិតផងដែរ។ នៅឆ្នាំ ១៩៩៥ Marsh និង Roche (១៩៩៤ ទំព័រ ៣៥) បានធ្វើការសិក្សាបន្ថែមទៀត អំពីប្រសិទ្ធភាពនៃការបង្រៀននិងការរៀននៅកម្រិតឧត្តម ដោយប្រើប្រាស់ការវាយតម្លៃរបស់សិស្សទៅលើគុណភាពអប់រំ (Students' Evaluation of Educational Quality (SEEQ)) រួមមាន ៩ ចំណុច គឺ៖ (១)ការរៀនសូត្រ/គុណតម្លៃនៃការសិក្សា (២)ឆន្ទៈសាស្ត្រាចារ្យ (៣)ការរៀបចំនិងភាពច្បាស់លាស់(៤)ការងារក្រុម (៥)ការស្រាវជ្រាវ (៦)ទំហំនៃការគ្របដណ្តប់ (៧)ការវាយតម្លៃ / ការដាក់ពិន្ទុ (៨)កិច្ចការ / ការអាន និង(៩)បន្ទុកការងារ / ការលំបាករបស់សិស្ស។

### ២.២.២ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

ប្រសិទ្ធភាពនៃការបង្រៀន ពឹងផ្អែកយ៉ាងសំខាន់ទៅលើចំណេះដឹង បទពិសោធន៍ និងជំនាញរបស់គ្រូ។ ការអភិវឌ្ឍជំនាញ និងចំណេះដឹងរបស់គ្រូជាប្រចាំឱ្យសមស្របទៅនឹងការផ្លាស់ប្តូររបស់សង្គមនិងសេដ្ឋកិច្ច គឺជាកត្តាចាំបាច់។ លោក Hargreaves (2000) បានផ្តល់និយមន័យ វិជ្ជាជីវៈគ្រូបង្រៀន (Professionalism) គឺសំដៅទៅលើការកែលម្អគុណភាព និងស្តង់ដានៃការអនុវត្តរបស់គ្រូដោយឡែក ។ ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន មាន៤ដំណាក់កាលៈ (១)The pre-professional age គឺការបង្រៀនប្រព្រឹត្តទៅតាមវិធីសាស្ត្របុរាណ ឬបែបប្រពៃណីដោយផ្អែកលើបទពិសោធន៍នៃការបង្រៀនរៀងៗខ្លួន។ ការបង្រៀនផ្តោតទៅលើទ្រឹស្តីជាជាងការអនុវត្តដែលជំរុញឱ្យមានការស្រាវជ្រាវ។ ចំណេះដឹងគ្រូភាគច្រើន នៅមានកម្រិតទាប។ ថ្នាក់រៀនត្រូវបាន ដឹកនាំ និងគ្រប់គ្រងដោយគ្រូ សិស្សស្តាប់ និងអនុវត្តតាម (Elliot 1991)។ (២)Autonomous professional age គ្រូទទួលបានការតម្រង់ទិស និងការបណ្តុះបណ្តាលទៅលើការអភិវឌ្ឍកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន និងការបង្កើតថ្មី។ គ្រូមានទំនាក់ទំនងជាមួយសិស្សច្រើន ប៉ុន្តែផ្តោតលើវិន័យ និងបញ្ហារបស់សិស្សជាបុគ្គល ដោយពុំបានមើលគោលបំណង វត្ថុបំណងនៃកម្មវិធីសិក្សា ទៅនឹងវិធីបង្រៀនរបស់ខ្លួន និងរបៀបរៀនរបស់សិស្ស។ (៣)ហៅថា Professional គ្រូចាប់ផ្តើមទទួលយកការរីកចម្រើននៃបច្ចេកវិទ្យា និងបរិបទនៃសង្គមទំនើបកាន់តែប្រសើរឡើង។ វប្បធម៌នៃការសហការរបស់គ្រូត្រូវបានជំរុញកាន់តែខ្លាំងដើម្បីធ្វើការអភិវឌ្ឍយុទ្ធវិធីបង្រៀន និងរៀនស្របតាមតម្រូវការសិស្ស (Elliott, 1991)។ គ្រូចាប់អភិវឌ្ឍន៍ចំណេះតាមរយៈការធ្វើការស្រាវជ្រាវ និងការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកាន់តែច្រើនឡើងនៅក្នុងការបង្រៀន។ និង (៤)ដំណាក់កាលចុងក្រោយ គឺវិជ្ជាជីវៈគ្រូបង្រៀនក្នុងសម័យទំនើប (Postmodern Professional)។ ក្នុងសតវត្សទំនើប ការរីកចម្រើនផ្នែកសេដ្ឋកិច្ច ទំនាក់ទំនង និងបច្ចេកវិទ្យា បានជំរុញឱ្យការអប់រំកាន់តែមានលក្ខណៈសកលភាវូបនីយកម្ម និងប្រកួតប្រជែង។ ដូចនេះ ទាមទារឱ្យមានបទដ្ឋាន និងស្តង់ដារក្នុងការត្រួតពិនិត្យគុណភាព ការវាយតម្លៃ និងស្តង់ដារនៃការបង្រៀន។ គ្រូបង្រៀនត្រូវធ្វើការអភិវឌ្ឍចំណេះដឹង ជំនាញ

និងវិធីសាស្ត្រដើម្បីបញ្ជាក់ពីគុណភាពនៃការបង្រៀនរបស់ខ្លួន។ ដំណាក់កាលទាំងបួនរបស់លោក Hargreaves គឺបង្ហាញពីធម្មជាតិនៃការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន ហើយដំណាក់ទាំងនេះវាមិនមែនកើតឡើងជាខ្សែត្រង់នោះទេ ហើយក៏មិនមែនវិជ្ជាជីវៈរបស់គ្រូត្រូវឆ្លងកាត់គ្រប់ដំណាក់កាលទាំងនេះដែរ។

## ២.៣ ការសិក្សាអប់រំតាមប្រព័ន្ធក្រេឌីត

នៅអំឡុងទស្សវត្ស ១៨៧០ ដោយសារការវិវត្តនៃសង្គម និងសេដ្ឋកិច្ច កម្មវិធីសិក្សានៅឧត្តមសិក្សាជាពិសេសនៅលោកខាងលិច បានផ្លាស់ប្តូរពីប្រព័ន្ធសិក្សាតាមបែបបុរាណ (Fixed curriculum) ទៅជាការសិក្សាតាមប្រព័ន្ធក្រេឌីត (Acadamic credit system) (Regel & Mundial, 1992)។ កម្មវិធីសិក្សានេះ មានលក្ខណៈបត់បែន និងផ្តោតទៅលើតម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នកសិក្សា (Aithal & Kumar, 2016)។ ប្រព័ន្ធសិក្សានេះ បានផ្តល់សេរីភាពផ្តល់គ្រឹះស្ថានសិក្សា ក្នុងការបង្កើតមុខវិជ្ជា និងកម្មវិធីសិក្សាថ្មីៗ ដែលផ្តល់ជាជម្រើសផ្សេងៗគ្នា សមស្របតាមតម្រូវ និងទិសដៅរបស់អ្នកសិក្សា (Aithal & Kumar, 2015)។ លោក Regal and Mundial បានកំណត់ការសិក្សាតាមប្រព័ន្ធក្រេឌីតមានលក្ខណៈដូចជា៖

- មួយឆ្នាំសិក្សាបែងចែកជាឆមាស ឬត្រីមាស ការវាយតម្លៃធ្វើឡើងនៅបំណាច់ឆមាស ឬត្រីមាស នីមួយៗ។ ការសិក្សារបស់សិស្ស ត្រូវបានគិតពីចំនួនមុខវិជ្ជាដែលសិស្សបានរៀន ជាជាងរយៈពេលដែលសិស្សត្រូវរៀនដើម្បីបញ្ចប់ការសិក្សា។
- មុខវិជ្ជានីមួយៗ ត្រូវបានកំណត់ចំនួនក្រេឌីត និងម៉ោងជាក់លាក់។ សិស្សត្រូវឆ្លងកាត់ការវាយតម្លៃទៅតាមល័ក្ខខ័ណ្ឌនៃការវង្វាយតម្លៃនៃមុខវិជ្ជា។ ចំនួនម៉ោងក្នុងក្រេឌីត ត្រូវបានកំណត់ដោយចំនួនម៉ោងក្នុងថ្នាក់ (អាចជាការអនុវត្ត ឬពិសោធន៍) និងម៉ោងមេរៀន។ (Regel & Mundial, 1992, p. 3)

អ្នកសិក្សាអាចធ្វើការជ្រើសរើសមុខវិជ្ជា (មុខវិជ្ជាជម្រើស) ក្រៅពីមុខវិជ្ជាគោល នៅក្នុងឯកទេស ឬជំនាញផ្សេងៗ។

## ២.៤ ទ្រឹស្តីពីបញ្ហាប្រឈម ការអនុវត្តកម្មវិធីសិក្សា

ដោយសារតែភាពរីកចម្រើន និងការវិវត្តនៃសង្គមសេដ្ឋកិច្ចនៅកម្ពុជា តំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ទាមទារឱ្យពលរដ្ឋកម្ពុជាមានការអភិវឌ្ឍនូវសមត្ថភាព ក្លាយជាពលរដ្ឋពេញលេញ ដោយផ្សារភ្ជាប់ទៅ និងបទពិសោធន៍របស់ពួកគាត់ និងការអនុវត្តជាក់ស្តែងនៅក្នុងជីវភាពរស់នៅ។ កម្មវិធីសិក្សា ដើរតួនាទី យ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្សឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សង្គមសេដ្ឋកិច្ច។ យោងតាមលោក (Buczynski & Hansen,2010) បានរកឃើញថា បញ្ហាប្រឈមជាច្រើនដែលគ្រូបានរាយការណ៍រួមមាន៖ កង្វះខាតការបែងចែកពេលវេលាតាមកម្មវិធីបង្រៀនដែលត្រូវការប្រើប្រាស់ចំណេះដឹង និងជំនាញថ្មីតម្រូវឱ្យបង្រៀនមេរៀនទៅតាមកម្មវិធីសិក្សាជាដំណាក់ៗ កង្វះខាតធនធាន (ដូចជាសម្ភារៈបម្រើឱ្យកម្មវិធីសិក្សា គ្រឿងបម្រុងបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ) ព្រមទាំងបញ្ហាការគ្រប់គ្រងថ្នាក់។ ការសិក្សានោះបានសន្និដ្ឋានថា កង្វះធនធាន គឺជាឧបសគ្គដ៏ធំបំផុត ដែលធ្វើឱ្យរាំងស្ទះលើការអនុវត្ត និងការអភិវឌ្ឍវិជ្ជាជីវៈ។ Badri (2016) បានរកឃើញបញ្ហាប្រឈមបន្ថែមទៀតដែលគ្រូបានជួបប្រទះមានដូចជា៖ កង្វះខាតការជួយជ្រោមជ្រែងពីនិយោជក ការជាន់គ្នានឹងកាលវិភាគបំពេញការងារ កង្វះខាតពេលវេលាព្រោះរវល់ជាមួយគ្រួសារ និងកង្វះខាតការផ្តល់វគ្គអភិវឌ្ឍន៍វិជ្ជាជីវៈដែលប្រើការបានសម្រាប់ការងាររបស់ខ្លួន។ ការសិក្សាផ្សេងមួយទៀតដោយ (Ros & Oleksiyenko, 2017) បានរកឃើញថា ស្ថាប័នគ្រប់គ្រងគ្មានធនធានគ្រប់គ្រង និងទឹកចិត្តក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដល់បុគ្គលិក។ ហើយក៏មានកត្តាប្រាំមួយ ដែលមានឥទ្ធិពលលើភាពជោគជ័យនៃសមាហរណកម្មបច្ចេកវិទ្យា៖ កង្វះធនធាន កង្វះខាតចំណេះដឹង និងជំនាញច្បាស់លាស់ រចនាសម្ព័ន្ធស្ថាប័ន ឥរិយាបថគ្រូ និងជំនឿទៅលើបច្ចេកវិទ្យា ប្រភេទនៃការវាយតម្លៃ និងវប្បធម៌មុខវិជ្ជានីមួយៗ(Hew,2007)។ លើសពីនេះកម្មវិធីសិក្សា ក៏ជាកត្តាដ៏សំខាន់មួយដែលជាការផ្សំឡើងនូវបទពិសោធន៍ទាំងឡាយដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ(Caswell & Campbell, 1935)។

## ២.៥ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

វិទ្យាស្ថានមានក្រុមប្រឹក្សាភិបាល សម្រាប់ដឹកនាំ និងផ្តល់យោបល់ ការដឹកនាំគ្រប់គ្រង និងការងារប្រតិបត្តិ (ប្រកាសលេខ១៦៩៦ អយក.ប្រក)មានសមាជិកចំនួន៩នាក់ ដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន ជាប្រធាន។ វិទ្យាស្ថានមាននាយក០១នាក់ និងនាយករង០៤នាក់ ការិយាល័យ០៣ និងដេប៉ាតឺម៉ង់ ០៧ដឹកនាំដោយប្រធាន និងអនុប្រធាន បានតែងតាំងរួច និងបានកំណត់តួនាទី ភារកិច្ចទទួលបន្ទុកច្បាស់លាស់(ប្រកាសលេខ៤៤៩អយក.ប្រក)។

*តារាងទី 1៖ តារាងស្ថិតិបុគ្គលិកអប់រំ (២០១៩-២០២០)*

| ល.រ | បុគ្គលិកអប់រំ | កម្រិតវប្បធម៌ | | | | | | | | សរុបរួម | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | មធ្យមសិក្សាទុតិយភូមិ | | បរិញ្ញាបត្រ | | បរិញ្ញាបត្រជាន់ខ្ពស់ | | បណ្ឌិត | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | គណៈគ្រប់គ្រង | ០ | ០ | ០ | ០ | ៣ | ១ | ២ | ០ | ៥ | ១ |
| ២ | បុគ្គលិកការិយាល័យ | ៨ | ៤ | ១១ | ៥ | ១៧ | ៥ | ០ | ០ | ៣៦ | ១៤ |
| ៣ | គ្រូឧទ្ទេស | ៩ | ៣ | ៥០ | ២៦ | ៦៤ | ២១ | ០ | ០ | ១២៣ | ៥០ |
| **សរុបរួម** | | | | | | | | | | **១៦៤** | **៦៥** |

*តារាងទី 2 ៖ តារាងស្ថិតិគរុសិស្ស/គរុនិស្សិត (២០១៩-២០២០)*

| ល.រ | គរុសិស្ស/និស្សិត | ចំនួនថ្នាក់ | #គរុនិស្សិតសរុប | ស្រី | #សរុបតាមកម្មវិធី |
|---|---|---|---|---|---|
| ១ | គរុនិស្សិតឆ្នាំទី១ (១២+៤) កម្រិតបឋមសិក្សា ជំនាន់ទី២ | ៦ | ១៤៨ | ១០៧ | សរុបគរុនិស្សិត ១២+៤ មាន ចំនួន ៤៨២នាក់ (ស្រី៣១៤) |
| ២ | គរុនិស្សិតឆ្នាំទី២ (១២+៤) កម្រិតបឋមសិក្សា ជំនាន់ទី១ | ៦ | ១៤៧ | ៩៤ | |

| | | | | | |
|---|---|---|---|---|---|
| ៣ | គរុនិស្សិតឆ្នាំទី១ (១២+៤) កម្រិតមូលដ្ឋាន ជំនាន់ទី២ | ៤ | ៩៨ | ៦៦ | |
| ៤ | គរុនិស្សិតឆ្នាំទី១ (១២+៤) កម្រិតមូលដ្ឋាន ជំនាន់ទី១ | ៤ | ៨៩ | ៤៧ | |
| ៥ | គរុសិស្សឆ្នាំទី១ (១២+២) កម្រិតមូលដ្ឋាន ជំនាន់ទី៣០ | ៣ | ២៨ | ១៤ | សរុបគរុសិស្ស ១២+២មានចំនួន ១៣៣នាក់ (ស្រី៨១នាក់) |
| ៦ | គរុសិស្សឆ្នាំទី២ (១២+២) កម្រិតមូលដ្ឋាន ជំនាន់ទី២៩ | ៦ | ៥៥ | ៣៥ | |
| ៧ | គរុសិស្សឆ្នាំទី២ (១២+២) កម្រិតបឋមសិក្សា ជំនាន់ទី៣៧ | ២ | ៥០ | ៣៥ | |
| | **សរុបរួម** | **៣១** | **៦១៥** | **៣៩៨** | |

វិទ្យាស្ថានគរុកោសល្យជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ អប់រំគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រកម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ (វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ, ២០១៩)។ ដោយវិទ្យាស្ថានមានយន្តការកំណត់ចំនួនក្រេឌីតសិក្សា និងគោលនយោបាយឬគោលការណ៍នៃការផ្ទេរក្រេឌីតស្របតាមបទបញ្ញត្តិជាធរមាន។ ដោយផ្អែកលើចក្ខុវិស័យរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញគឺចង់ក្លាយទៅជាវិទ្យាស្ថានឈានមុខគេក្នុងសតវត្សរ៍ទី២១ ដោយមានបេសកកម្ម (១) អប់រំគរុនិស្សិត និងអភិវឌ្ឍន៍សមត្ថភាពឱ្យមានគុណសម្បទាពេញលេញ (២)លើកកម្ពស់ការស្រាវជ្រាវអប់រំដើម្បីបង្កើនគុណភាពការបង្រៀននិងរៀន (៣)ផ្តល់សេវាសហគមន៍ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រូបង្រៀន។ ដោយឈរលើគុណតម្លៃជាគន្លឹះចំនួន៥គឺៈ (១)ការគោរព (២)សុចរិត (៣)នវានុវត្តន៍ (៤)ការប្តេជ្ញាចិត្ត និង(៥)ប្រសិទ្ធផល។ (វិទ្យាស្ថានគរុកោសល្យ , ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ, ២០១៧)។

## ២.៦ ការអនុវត្តកម្មវិធីសិក្សា ១២ + ៤ តាមប្រព័ន្ធក្រេឌីត

កម្មវិធីសិក្សាលម្អិត (១២+៤) គឺបានមកពីកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ NIE សិង្ហបុរី កម្មវិធីសិក្សាបរិញ្ញាបត្ររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និង

គ្រឹះស្ថានអប់រំឧត្តមសិក្សាផ្សេងៗទៀត កម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី១ ដល់ទី១២ (២០១៦) កម្មវិធីសិក្សាបរិញ្ញាបត្រអប់រំរបស់សាកលវិទ្យាល័យជប៉ុន និងជំនួយសហប្រតិបត្តិការរបស់គម្រោង ETEC/JICA និង VVOB ៖ (១)ដើម្បីអភិវឌ្ឍន៍កម្មវិធីសិក្សាដែលប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព (២)កម្មវិធីសិក្សាមានលក្ខណៈស្របតាមគោលនយោបាយជាតិ ក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម (៣)កម្មវិធីសិក្សាមានការសរសេរកម្មវិធីសិក្សាលម្អិតច្បាស់លាស់ដោយផ្អែកលើសៀវភៅសិក្សាគោល សៀវភៅយោង គេហទំព័រ ឯកសារសិក្សា និងឯកសារបង្រៀនផ្សេងៗទៀត និង(៤)ជាការសិក្សាតាមប្រព័ន្ធក្រេឌីតដែលមានចំនួន១៣០ក្រេឌីត ហើយបែងចែកជា២ដំណាក់គឺ៖ **១)** ដំណាក់ថ្នាក់មូលដ្ឋាន១ឆ្នាំសិក្សា (មិនតិចជាង៣០ក្រេឌីត) និង **២)** ដំណាក់កាលថ្នាក់ជំនាញ៣ឆ្នាំសិក្សា (ច្រើនជាង៩០ក្រេឌីត) ដូចមានរចនា សម្ព័ន្ធខាងក្រោម៖

*តារាងទី 3 ៖ រចនាសម្ព័ន្ធ*

| ១ | ២ | ៣ | ៤ |
|---|---|---|---|
| ថ្នាក់មូលដ្ឋាន | ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា | | |
| ខ្លឹមសារ និងមុខវិជ្ជារួម | ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ | | |
| កម្មសិក្សាប្រតិបត្តិត្រូវអនុវត្តរៀងរាល់ឆ្នាំ | | | |

## ២.៧ ប្រព័ន្ធក្រេឌីត ម៉ោងសម្រាប់ថ្នាក់រៀន និងម៉ោងសិក្សា

វិទ្យាស្ថានគរុកោសល្យបានអនុវត្តតាមប្រព័ន្ធក្រេឌីតនៃសេចក្តីសម្រេចលេខ ០៤/០៤ គទក.សសរ ឆ្នាំ២០០៤ ជំពូកទី២៖ អនុវត្តន៍ប្រព័ន្ធក្រេឌីត (គទក ឆ្នាំ២០០៤) ។

**ក. ការបង្រៀន៖** ការបង្រៀន១ក្រេឌីត ត្រូវបង្រៀនម៉ោងនៅក្នុងថ្នាក់រៀនក្នុង១សប្តាហ៍មិនតិចជាង ១៥ម៉ោងក្នុង១ឆមាស។

**ខ. មន្ទីរពិសោធន៍/សិក្ខាសាលា៖** ក្រេឌីតសម្រាប់មន្ទីរពិសោធន៍/សិក្ខាសាលា គឺជាការបណ្ដុះបណ្ដាល ឬធ្វើការពិសោធន៍នៅក្នុងមន្ទីរពិសោធន៍ ដែលតម្រូវយ៉ាងហោចណាស់២ម៉ោងក្នុងសប្ដាហ៍ ឬយ៉ាងណាស់៣០ ម៉ោងក្នុង១ឆមាស។

**គ. កម្មសិក្សា៖** ក្រេឌីតសម្រាប់កម្មសិក្សា គឺជាការបណ្ដុះបណ្ដាលដែលគរុនិស្សិតនឹងត្រូវចុះសិក្សានៅតាម កសិដ្ឋាន ក្រុមហ៊ុន មន្ទីរពេទ្យ ឬទីកន្លែងផ្សេងៗដែលតម្រូវឱ្យមានយ៉ាងហោចណាស់ ៣ម៉ោងក្នុង១សប្ដាហ៍ ឬយ៉ាងតិច៤៥ម៉ោងក្នុង១ឆមាស។

ក្រេឌីតជាតំណាងកម្រិតតម្លៃ(មាឌ) សិក្សាដែលតម្រូវឱ្យគរុនិស្សិតត្រូវតែរៀនឱ្យបានពេញលេញតាមមុខវិជ្ជានៅក្នុងថ្នាក់រៀន។ ស្ដង់ដា១ក្រេឌីតសម្រាប់មុខវិជ្ជាក្នុងថ្នាក់រៀនស្មើនឹង៤៥ម៉ោងនៃការសិក្សា (សរុបទាំងរៀនក្រៅថ្នាក់ និងរៀនក្នុងថ្នាក់)។

ផ្អែកតាមគោលការណ៍នេះ ចំនួនម៉ោងក្នុងថ្នាក់សម្រាប់មុខវិជ្ជាក្នុងថ្នាក់នីមួយៗអាស្រ័យទៅតាមប្រភេទថ្នាក់។ ក្នុងករណីបង្រៀនសុទ្ធនៅក្នុងថ្នាក់សម្រាប់១ក្រេឌីតស្មើនឹង១៥ម៉ោងក្នុង១ឆមាស មានន័យថា៣០ម៉ោងផ្សេងទៀត ដើម្បីឱ្យគរុនិស្សិតរៀបចំមានពេលគ្រប់គ្រាន់ទៅលើការស្រាវជ្រាវបន្ថែមលើមេរៀននីមួយៗ សម្រាប់ឱ្យគរុនិស្សិតរៀបចំបទបង្ហាញ និងពិភាក្សាមេរៀនរំលឹកមេរៀនឡើងវិញ និងសម្រាប់ឱ្យគរុនិស្សិតធ្វើកិច្ចការសាលាដែលគ្រូដាក់ឱ្យធ្វើនៅផ្ទះ។ ថ្នាក់មន្ទីរពិសោធន៍/សិក្ខាសាលា ចំនួន៣០ម៉ោងក្នុងថ្នាក់រៀន និង១៥ម៉ោងសម្រាប់រៀនក្រៅថ្នាក់ក្នុង១ឆមាស និងកម្មសិក្សា (កម្មសិក្សាគរុកោសល្យ) ចំនួន៤៥ម៉ោងក្នុង១ឆមាស។

ដោយយោងទៅតាមប្រព័ន្ធក្រេឌីតនៃវិទ្យាស្ថានគរុកោសល្យត្រូវកំណត់ឱ្យបាន៣០ក្រេឌីតក្នុង១ឆ្នាំ និង១៥ក្រេឌីតក្នុង១ឆមាស។វិទ្យាស្ថានគរុកោសល្យត្រូវលើកទឹកចិត្តដល់គរុនិស្សិតឱ្យសកម្មក្នុងការរៀនសូត្រនិងផ្ដល់បទពិសោធន៍សិក្សាឱ្យបានច្រើនទាំងនៅក្នុងថ្នាក់និងក្រៅថ្នាក់។ដូចមាននៅក្នុងបំណែងចែកក្រេឌីតសិក្សា

*តារាងទី 4 ៖ បំណែងចែកក្រេឌីតសិក្សា (១៣០) ក្នុងរយៈពេល៤ឆ្នាំ*

| ឆ្នាំ | ក្រេឌីតសិក្សា | | ក្រេឌីតកម្មសិក្សា | |
|---|---|---|---|---|
| | កម្រិតបឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ |
| ឆ្នាំទី១ | ៣៣ | ៣១ | ២ (២សប្ដាហ៍) | ២ (២សប្ដាហ៍) |
| ឆ្នាំទី២ | ២៩ | ២៨ | ៥ (៥សប្ដាហ៍) | ៥ (៥សប្ដាហ៍) |
| ឆ្នាំទី៣ | ២៦ | ២៦ | ៥ (៥សប្ដាហ៍) | ៥ (៥សប្ដាហ៍) |
| ឆ្នាំទី៤ | ២០ | ២៣ | ១០ (១០សប្ដាហ៍) | ១០ (១០សប្ដាហ៍) |
| សរុបក្រេឌីតតាមផ្នែក | ១០៨ | ១០៨ | ២២ | ២២ |
| **សរុបរួម** | **១៣០** | | | |

## ២.៨ គន្លងអាជីពគ្រូបង្រៀននៃប្រទេសកម្ពុជា

គន្លងអាជីពគ្រូបង្រៀនជាប្រព័ន្ធលើកទឹកចិត្តគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ។ អាជីពគ្រូបង្រៀនចែកចេញជាបីគន្លង គឺគន្លងគ្រូបង្រៀន គន្លងគណៈគ្រប់គ្រងសាលារៀន និងគន្លងអ្នកឯកទេសអប់រំ។ គន្លងគ្រូបង្រៀន ត្រូវបានរៀបចំសម្រាប់គ្រូបង្រៀនដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន និងចែកជាបីកម្រិត៖(១) **គ្រូឈានមុខ៖** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅតាមសាលារៀនកម្រិតស្រុក ឬខេត្ត។ (២) **គ្រូគម្រូ៖** មានគុណផលការងារធ្វើឱ្យប្រសើរនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅតាមសាលារៀនកម្រិតស្រុក ឬខេត្ត។ និង(៣) **គ្រូឆ្នើម៖** មានគុណផលការងារធ្វើឱ្យប្រសើរដល់គោលនយោបាយ និងអន្តរាគមន៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃគុណផលសិក្សារបស់សិស្ស និងគុណផលសាលារៀននៅកម្រិតជាតិ (ក្រសួងអប់រំយុវជន និងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨) ។

## ២.៩ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

ទាក់ទងជាមួយនឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន ឯកសារស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៩ ក៏បានលើកឡើងផងដែរថា ការបង្រៀនមួយដែលមានគុណភាព និងប្រសិទ្ធភាពល្អគឺទាមទារឱ្យគ្រូមានលំនាំសកម្មភាពនៃការបង្រៀន ដែលជានាបាននូវកម្រិតស្តង់ដារក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន។ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន គឺជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀន ដែលអាចអនុវត្តបានហើយមានឥទ្ធិពលទៅលើសិស្ស។ គឺជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀនហើយក៏ជាខ្នាតគម្រូសម្រាប់អ្នកអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលគ្រូនិងសម្រាប់ការធ្វើផែនការកសាងសមត្ថភាពគ្រូបង្រៀន។ ស្តង់ដារគ្រូបង្រៀន គឺបានបញ្ជាក់អំពីការបង្រៀនដែលមានគុណភាព ដោយអាចប្រាប់បានពីអ្វី ដែលគេបានឱ្យតម្លៃនៅក្នុងការបង្រៀន ដែលបញ្ជាក់ថា គ្រូបង្រៀនគួរយល់ដឹងអ្វីខ្លះ ហើយនិងអាចធ្វើអ្វីខ្លះបានប្រសើរជាងមុនក្នុងរយៈពេលវែង។ ដើម្បីដឹងថាគ្រូបង្រៀនបានអនុវត្តសម្រេចដល់ត្រឹមកម្រិតស្តង់ដារណានោះ យោងត្រូវធ្វើការសង្កេត ឬរកភស្តុតាង។ ភស្តុតាងដែលយើងអាចរកឃើញបានតាមរយៈ ៖ (១) **ការបង្ហាញ៖** សង្កេតសកម្មភាពបង្រៀន(២) **ឯកសារកំណត់ត្រា៖** ពិនិត្យកំណត់ត្រា ឯកសារយោង កិច្ចតែការបង្រៀន គម្រូកិច្ចការសិស្ស...។ (៣) **សម្ភាសន៍៖** ស្តាប់របាយការណ៍ជាភស្តុតាង និងសម្ភាសន៍ជាមួយគ្រូបង្រៀន។ សកម្មភាពបង្រៀនដែលមានគុណភាព និងប្រសិទ្ធភាពនោះ គឺជាការបង្រៀនមួយដែលមានលក្ខណៈស្តង់ដារ។

ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមាន៖(១) **ចំណេះដឹងវិជ្ជាជីវៈ៖** គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប។ គាត់ត្រូវតែដឹងច្បាស់អំពីតម្រូវការសិក្សា សមត្ថភាព ប្រវត្តិការសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗ ហើយក៏យល់ដឹងផងដែរពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច...) ព្រមទាំងយល់ដឹងអំពីវិធីដោះស្រាយកត្តាទាំងនេះ។ គ្រូបង្រៀនត្រូវមានការយល់ដឹងពីវិធីដោះស្រាយកត្តាទាំងនេះ និងត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ

ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។ គ្រូបង្រៀនយល់អំពីទ្រឹស្តីនៃកិច្ចតែងការបង្រៀនដូចជា វត្ថុបំណង និងវិធីសាស្ត្របង្រៀន និងអាចជ្រើសរើសវិធីវាយតម្លៃលើលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនអាចយល់អំពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់អំពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជារបស់ខ្លួនទៅមុខវិជ្ជាមួយផ្សេងទៀតក្នុងន័យឱ្យសិស្សទទួលបាននូវបំណិនជាច្រើននិងមានចិត្តកាន់តែចង់រៀន។ គ្រូបង្រៀនត្រូវយល់ដឹងអំពីបរិស្ថានក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ជាពិសេសយល់ពីរបៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ **(២) ការប្រតិបត្តិវិជ្ជាជីវៈ៖** គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាពតាមកម្មវិធីសិក្សា ដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារៈសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនគួរគប្បីរៀបចំសម្ភារៈបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយ សម្រេចការសិក្សារបស់សិស្សប្រកបទៅដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗពីគ្នាដែលសមស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស ។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស ឪពុកម្តាយ ឬអាណាព្យាបាលអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។ គ្រូបង្រៀនត្រូវផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាពហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវខ្ពស់លើការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចេះប្រើវិធីសាស្ត្របង្រៀនឱ្យបានសម្បូរបែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបាននូវវត្ថុបំណងមេរៀន។ ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សារួមនឹងតម្រូវការផ្សេងៗគ្នារបស់សិស្ស តាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតឱ្យបានល្អិតល្អន់ និងច្នៃប្រឌិត។ លើសពីនេះទៀត គឺគ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធាននៅក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យកិច្ចការងារបង្រៀន និងរៀន

កាន់តែមានប្រសិទ្ធភាពឡើងថែមទៀត។ (៣) **ការសិក្សាវិជ្ជាជីវៈ៖** យើងបានដឹងហើយថាគ្រូបង្រៀន គឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា ដូច្នេះគាត់ត្រូវតែស្វ័យសិក្សាវាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍន៍ខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍន៍ផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស ឪពុកម្តាយសិស្ស មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀតនៅក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលម្អការបង្រៀន និងរៀន ហើយក៏ត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវជ្ជាជីវៈ។ និង(៤) **សីលធម៌វិជ្ជាជីវៈ៖** សីលធម៌វិជ្ជាជីវៈ គឺទាក់ទងទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈជាគ្រូបង្រៀនដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបទៅដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់ស្តីពីការអប់រំ ។ គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ ។ គ្រូបង្រៀនគួរតែចូលរួមគ្រប់សកម្មភាពទាំងក្នុង និងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើទៅបាន។ គ្រូបង្រៀនដែលមានប្រសិទ្ធភាព គឺមិនរើសអើងសិស្សទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាពឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។ នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិទ្ធិសិស្ស ដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មដល់ពួកគេតាមរបៀបហិង្សានោះឡើយ។ គ្រូបង្រៀនត្រូវមានចរិយាសម្បត្តិ មានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរសម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍សិស្ស ធ្វើជាគម្រូដល់សិស្សក្នុងការរស់នៅនិងរៀនសូត្រល្អ

ពិសេសចេះលើកកម្ពស់ស្មារតីឱ្យសិស្សរឹងប៉ឹង និងវិជ្ជមាន ហើយបង្កើតស្មារតីលះបង់ និងរួមចំណែកក្នុងសហគមន៍ទាំងមូល។

## ២.១០ តួនាទីរបស់គ្រូបង្រៀនក្នុងសតវត្សទី២១

គ្រូបង្រៀន ជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ ។ ការងាររបស់គ្រូបង្រៀន គឺជាការងារសាំញ៉ាំ ដែលមានលក្ខណៈមិនច្បាស់លាស់ ប្រែលប្រួលជាប្រចាំ និងភាពស្រពិចស្រពិល ហើយទាមទារនូវគំនិតផ្តួចផ្តើម ការគិត សុកវិនិច្ឆ័យ និងជំនាញកម្រិតខ្ពស់ ដើម្បីជានាតួនាទីនេះប្រកបដោយគុណភាព ។ សម្រាប់ការអប់រំនាសតវត្សទី២១ គ្រូបង្រៀនលែងដើរតួនាទីសំខាន់ជាអ្នកផ្តល់ចំណេះដឹងដល់សិស្សដោយផ្ទាល់ដូចកាលពីមុនទៀតហើយ។ មានព័ត៌មានល្អៗ ជាច្រើនដែលសិស្សអាចទទួលបានមកពីប្រភពក្រៅ ។ តួនាទីគ្រូពេលនេះលែងជាអ្នកផ្តល់ចំណេះដឹងដល់សិស្សដោយផ្ទាល់ទៀតហើយ ប៉ុន្តែត្រូវដើរតួជាអ្នកជួយសម្របសម្រួលសិស្សក្នុងដំណើរការវិភាគ វាយតម្លៃកាសិក្សារៀនសូត្រ តាមរយៈមធ្យោបាយជំរុញឱ្យមានការច្នៃប្រឌិត ការគិតល្អិតល្អន់ ស៊ីជម្រៅ កិច្ចសហការ និងជំនាញទំនាក់ទំនង។ គោលវិធីសិស្សមជ្ឈមណ្ឌល ជាបេះដូងនៃការអប់រំនាសតវត្សទី២១ ដែលតួនាទីគ្រូ គឺត្រូវជួយសិស្សក្នុងការផ្ទៀងផ្ទាត់ សំយោគព័ត៌មាន ចំណេះដឹងអំពីមេរៀន សហការគ្នាស្វែងរកព័ត៌មានចំណេះដឹង និងដោះស្រាយរាល់បញ្ហាដែលបានកើតឡើង។ ក្នុងរយៈពេល១៥ឆ្នាំនៃសម័យសតវត្សទី២១នេះ យើងហាក់ដូចជាមិនទាន់បានធ្វើអ្វីច្រើនទាក់ទងនឹងការអប់រំ ឱ្យមានការផ្លាស់ប្តូរឆ្លើយតបនឹងគោលការណ៍នេះទេ។ គ្រូបង្រៀនត្រូវបានកំណត់ថាជាមនុស្សដ៏សំខាន់ ដែលធ្វើសកម្មភាពក្នុងស្មារតីខិតខំធ្វើយ៉ាងណាឱ្យសិស្សទទួលបាននូវការរីកចម្រើនខាងបញ្ញា ស្មារតី និងសុខភាពរាងកាយយ៉ាងល្អប្រសើរ។ វិធីសាស្ត្របង្រៀនសម្រាប់ការអប់រំសតវត្សទី២១ មានចរិតលក្ខណៈ សហការ និងផ្តល់ពហុជំនាញខុសៗគ្នាជាច្រើនដល់សិស្ស ។ ទម្រង់រៀន និងបង្រៀនបែបនេះ គ្រូបង្រៀន ក៏អនុវត្តជានិច្ចក្នុងសហគមន៍រៀនអាជីព ដែលហៅថា PLC ដែលផ្តោតសំខាន់ទៅលើដំណើរការសិក្សា និងលទ្ធផល ការសម្រេចចិត្តលើព័ត៌មានសិក្សា ការចែករំលែកចំណេះដឹងអំពីមេរៀន វិធីសាស្ត្រ និងជំនាញក្នុងចំណោមគ្រូបង្រៀន។ ជំនាញសម្រាប់គ្រូ

បង្រៀន ដើម្បីបង្រៀនក្នុងថ្នាក់រៀននៃសតវត្សទី២១ គឺជាបញ្ហាដ៏ស្មុគស្មាញ ក្នុងប្រទេសជាច្រើនក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ។ បច្ចុប្បន្ននេះ ពេលដែលអ្នករៀនភាគច្រើន អាចស្វែងរកប្រភពមេរៀនដោយប្រើបច្ចេកវិទ្យាបាន និងនៅពេលដែលចំណេះដឹងដែលយើងប្រើធម្មតាសព្វថ្ងៃនេះ មានគេធ្វើឌីជីថលរូបនីយកម្ម ឬផ្គត់ផ្គង់ពីក្រៅ និងនៅពេលដែលរបៀបរបបធ្វើការងារមានការប្រែប្រួលយ៉ាងឆាប់រហ័ស គ្រូបង្រៀនត្រូវជួយជំរុញសិស្សក្លាយជាអ្នកសិក្សាពេញមួយជីវិត ដើម្បីគ្រប់គ្រងរបៀបគិតស្មុគស្មាញដែលគ្មានវិធានច្បាស់លាស់ និងរបៀបនៃការធ្វើការដ៏ស្មុគស្មាញរបស់មនុស្ស ដែលម៉ាស៊ីនកុំព្យូទ័រមិនអាចជំនួសដោយស្រួលបាន។ ប្រព័ន្ធគ្រប់គ្រងការអប់រំ រួមមានការគ្រប់គ្រងគោលនយោបាយអប់រំ (ក្រសួងអប់រំ) ប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន និងសាលារៀន។ (Hoy and Miskel, 2008) បានសំយោគរបៀបគ្រប់គ្រងការអប់រំនៅកម្រិតសាលារៀនថា ជាប្រព័ន្ធសង្គមបើកចំហរមួយដែលមានធាតុផ្សំប្រាំ ឬឧបសម្ព័ន្ធប្រាំៈ រចនាសម្ព័ន្ធ បុគ្គល វប្បធម៌ នយោបាយ និងគរុកោសល្យ។ ឥរិយាបថស្ថាប័ន កើតចេញពីបន្សាំនៃអន្តរកម្មនៃធាតុទាំងប្រាំពោល គឺកើតចេញពីបរិបទនៃការបង្រៀន និងរៀន។ ដំណើរការបង្រៀន និងរៀនជាសកម្មភាពស្នូលនៃប្រព័ន្ធសង្គមសាលារៀន។

បរិស្ថានក៏ជាផ្នែកសំខាន់នៃជីវិតរបស់ស្ថាប័នសាលារៀនផងដែរ។ ប្រព័ន្ធសាលារៀនមិនត្រឹមតែផ្តល់នូវធនធានប៉ុណ្ណោះទេ ប៉ុន្តែវាក៏បន្ថែមនូវការប្រឈម និងកាលានុវត្តន៍ភាពផងដែរ។ សូនាករវាស់វែងប្រសិទ្ធភាពអាចនឹងត្រូវបានយកមកប្រើសម្រាប់ដំណាក់កាលនីមួយៗនៃប្រព័ន្ធបើកចំហរវដ្តនៃធាតុចូល (មនុស្ស និងហិរញ្ញវត្ថុ) វិរូបកម្ម (ដំណើរការខាងក្នុង និងរចនាសម្ព័ន្ធ) និងគុណផល។ ការចាត់ទុកសាលារៀនជាប្រព័ន្ធបើកចំហរមួយមានន័យថា គេបានមើលឃើញពីបណ្តុំនៃធាតុធ្វើឱ្យមានអន្តរកម្មក្នុងប្រព័ន្ធសាលារៀន គឺមានន័យថាប្រព័ន្ធសាលារៀនទទួលធនលាភពីខាងក្រៅ និងជានានិម្មិតកម្ម (transformation) និងវិបត្តិកម្ម (conversion) ធាតុចូលឱ្យទៅជាផលសម្រេច សម្រាប់បរិយាកាសសាលារៀន។ មនុស្ស វត្ថុធាតុដើម ព័ត៌មាន និងថវិកា ជាធាតុចូលធម្មតាសម្រាប់សាលារៀន។ ក្នុងដំណើរការនិម្មិតកម្មនេះ ធាតុចេញទាំងអស់ត្រូវបំប្លែងឱ្យទៅជាគុណតម្លៃមួយថ្មី ហៅថាផលសម្រេច ហើយត្រូវបានយកទៅប្រើក្នុងសាលារៀន។ ផល

សម្រេច ជាទូទៅជាផលិតផល និងសេវាកម្ម ប៉ុន្តែត្រូវរាប់បញ្ចូលទាំងសោមនស្សភាពរបស់បុគ្គលិក និងអនុផលផ្សេងៗទទួលបានពីដំណើរនិម្មិតកម្មផងដែរ។ បន្ទប់រៀន កុំព្យូទ័រ សៀវភៅសិក្សា គ្រូបង្រៀន និងសិស្ស គឺជាធាតុចូលយ៉ាងសំខាន់សម្រាប់សាលារៀន។ លក្ខខណ្ឌវិនិច្ឆ័យក្នុងដំណើរការនិម្មិតកម្ម សំដៅដល់បរិមាណ គុណភាព និងសង្គតិភាពនៃដំណើរការ និងរចនាសម្ព័ន្ធផ្ទៃក្នុង និងមានតួនាទីក្នុងការនិម្មិតធាតុចូលឱ្យទៅជាផល។ ឧទាហរណ៍អំពីលក្ខខណ្ឌវិនិច្ឆ័យក្នុងដំណើរការនិម្មិតកម្ម រួមមាន រចនាសម្ព័ន្ធ និងមាតិកានៃកម្មវិធីសិក្សា សុខភាពនៃអន្តរទំនាក់ទំនងមនុស្ស កម្រិតនៃការលើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ភាពជាអ្នកដឹកនាំក្នុងចំណោមគ្រូបង្រៀន និងមន្ត្រីរដ្ឋបាល គុណភាព និងបរិមាណនៃការបង្រៀន និងនីតិវិធីគ្រប់គ្រងគុណភាព។ ឧទាហរណ៍ ចំនួនតេស្តវាយតម្លៃសិស្ស វាយតម្លៃការបង្រៀន ការប្រើបច្ចេកវិទ្យាបង្រៀន និងការវាយតម្លៃបុគ្គលិក។ ដើម្បីជានាអតិបរមានៃប្រសិទ្ធភាពកម្រិតសាលារៀន ផលរំពឹងក្នុងផ្នែករដ្ឋបាល និងគ្រប់គ្រងវប្បធម៌ការងារជាក្រុម ផលរំពឹងទទួលផ្នែកនយោបាយ និងតម្រូវការតាមស្ថានភាពបុគ្គល ដើម្បីជានាសម្រេចគោលដៅគុណផលរបស់សាលារៀន។ កំណែទម្រង់ត្រូវចាប់ផ្តើមនៅសាលារៀនប្រទេសជាច្រើន បានប្តូរនិន្នាការទៅរកការពង្រីកស្វ័យភាព និងបង្វែរការទទួលខុសត្រូវទៅកម្រិតសាលារៀន មានន័យថា ជំរុញឱ្យសាលារៀនឆ្លើយតបនឹងតម្រូវការមូលដ្ឋាន។ កម្មវត្ថុនៃកំណែទម្រង់នៅសាលារៀន គឺសំដៅបង្កើនគុណផលតាមរយៈការអនុវត្តគោលវិធីគ្រប់គ្រងនៅកម្រិតសាលារៀន។ ហេតុដូច្នេះ ប្រទេសកំពុងអភិវឌ្ឍន៍គួរចាប់ផ្តើមកែទម្រង់អប់រំ ដោយធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសាលារៀន គ្រូបង្រៀន សិស្ស និងគ្រួសារ។

## ២.១១ ការប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ការបង្រៀន

ការបង្រៀន និងការសិក្សាដែលមានប្រសិទ្ធភាពតម្រូវឱ្យមានសម្ភារៈសិក្សាសមរម្យ និងសម្បូរបែប។ នៅក្នុងប្រទេសជាច្រើនករណីនេះមិនមែនជាបញ្ហាទេ។ ស្ថានភាពទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ ដែលក្នុងនោះមានដូចជា ការគិតគូរអំពីគោលនយោបាយគ្រប់គ្រងផលិតកម្ម និងការបែងចែកសៀវភៅសិក្សារួម ទាំងសម្ភារៈសិក្សាដទៃទៀត និងការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពី របៀបប្រើប្រាស់សម្ភារៈសិក្សាឱ្យមានប្រសិទ្ធ

ភាពដោយស្របទៅនឹងការអនុវត្តការបង្រៀនល្អ។ សម្រាប់ប្រទេសជាច្រើនការផ្តល់ដល់សិស្សនូវសំណុំទាំងមូលនៃសៀវភៅសិក្សា និងសម្ភារៈសិក្សាដទៃទៀតគឺជា "គោលដៅដ៏ល្អបំផុត" (Montanges, 2001)។

## ២.១២ ការរៀបចំផែនការកិច្ចតែងការបង្រៀន

តាមការស្រាវជ្រាវរបស់(NEP, 2005) បានចង្អុលបង្ហាញថា គ្រូភាគច្រើនបានទទួលនូវការលើកទឹកចិត្តតិចតួច និងប្រាក់បៀវត្សរ៍មានកម្រិតទាបដូចនេះពួកគាត់ក៏គ្មានជម្រើសក្រៅពីស្វែងរកមុខរបរទីពីរក្នុងគោលបំណងបង្កើនប្រាក់ចំណូលចិញ្ចឹមគ្រួសារដែលជាហេតុបណ្តាលឱ្យប្រសិទ្ធភាពក្នុងពេលបង្រៀននៅតែមានកម្រិត និងមានចន្លោះច្រើនក្នុងការរៀបចំកិច្ចតែងការបង្រៀន។ ការស្រាវជ្រាវបានបញ្ជាក់ទៀតថានៅប្រទេសកម្ពុជាគ្រូមធ្យមសិក្សាបឋមភូមិប្រមាណជា៣០% បាននិយាយថាពួកគាត់មកកាន់សាលារៀនកម្រនឹងរៀបចំប្លង់មេរៀនណាស់ ។ នៅតំបន់ដាច់ស្រយាលមានភាគរយកើនជាងនេះរហូតដល់៤៣% នេះជាលទ្ធផលមួយដែលអ្នកអប់រំទាំងអស់មានក្តីបារម្ភនិងត្រូវយកចិត្តទុកដាក់បំផុតលើការងាររៀបចំកិច្ចតែងការបង្រៀនសម្រាប់ជាគុណប្រយោជន៍ដល់ការបង្កើនប្រសិទ្ធភាពបង្រៀននិងសម្រេចវត្ថុបំណងរបស់មេរៀននីមួយៗដែលក្រសួងបានកំណត់។

## ២.១៣ កម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតសម្រាប់គ្រូនៅប្រទេសសិង្ហបុរី

កម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់ប្រទេសសិង្ហបុរី ក៏ដូចជាប្រទេសដទៃទៀតដែរ គឺផ្តោតសំខាន់ទៅលើចំណេះដឹង ការសិក្សាអប់រំវិធីសាស្រ្តបង្រៀន ការអនុវត្តជាក់ស្តែង និងការអភិវឌ្ឍខ្លួនរបស់គរុសិស្ស និងគរុនិស្សិត។ ចាប់ពីឆ្នាំ១៩៩៤ កម្មវិធីបណ្តុះបណ្តាលគ្រូសិង្ហបុរី បានផ្លាស់ប្តូរដោយផ្តោតលើប្រព័ន្ធអប់រំតាមបែបឧត្តមសិក្សាដែលឱ្យឈ្មោះថាប្រព័ន្ធក្រេឌីត (Academic Unit System) (Gopinathan et al., 1999)។ កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត នេះមានលក្ខណៈបត់បែន និងឆ្លើយតបទៅនឹងតម្រូវការរបស់គរុសិស្សនិងគរុនិស្សិតដោយផ្តល់ជម្រើសដល់ពួកគាត់ក្នុងការសិក្សា(Aithal & Kumar, 2016)។ ដូចគ្នានេះការបណ្តុះបណ្តាលគ្រូតាមប្រព័ន្ធក្រេឌីត នៅសិង្ហបុរី ត្រូវបានរៀបចំឡើងតាមលក្ខណៈ ដូចខាងក្រោម ៖

- មុខវិជ្ជាគោល (Core and Prescribed modules)
- មុខវិជ្ជាជម្រើស(១) ពង្រីកចំណេះដឹងរបស់ខ្លួនទៅលើផ្នែកឬឯកទេសផ្សេងៗទៀត ឬ (២) សិក្សាស៊ីជម្រៅលើមុខវិជ្ជាឯកទេសណាមួយ)។

ឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងសង្គមក្នុងសតវត្សទី២១ កម្មវិធីនៃការបណ្តុះបណ្តាលគ្រូនៃវិទ្យាស្ថានជាតិអប់រំសិង្ហបុរីយកចិត្តទុកដាក់ទៅលើគោលគំនិតនៃការអប់រំសំខាន់ៗបី($V^3SK$)គឺ៖ (១) គុណតម្លៃ (Values) (២) ជំនាញ (Skill) និង(៣) ចំណេះដឹង(Knowledge) (Ministry of Education Singapore, 2012)។ ក្នុងនោះគ្រូចាំបាច់ត្រូវមានជំនាញនៅក្នុងសតវត្សទី២១ដូចជា៖ ជំនាញនៃការឆ្លុះបញ្ចាំង ជំនាញគរុកោសល្យ ជំនាញនៃការគ្រប់គ្រងមនុស្ស និងគ្រប់គ្រងរដ្ឋបាល និងជំនាញនៃការទំនាក់ទំនង និងសម្របសម្រួលរួមទាំងជំនាញបច្ចេកវិទ្យា និងនវានុវត្តន៍ (Ministry of Education Singapore, 2012)។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ នឹងធ្វើការស្វែងយល់ពី ការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្មីរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ ទិន្នន័យដែលបានប្រមូលនេះមានពីរប្រភេទ (១) ទិន្នន័យជាប្រភេទបរិមាណវិស័យ (Quantitative data) ដែលជាទិន្នន័យបានមកពីការសិក្សាលើការអានឯកសារផ្សេងៗដោយធ្វើការសំយោគ និងបំពេញកម្រងសំណួរ(បិទ) និង(២)ទិន្នន័យជាប្រភេទគុណវិស័យ (Qualitative Data) ដែលទិន្នន័យទាំងនេះបានមកពីការបំពេញកម្រងសំណួរ(បើក)ជាមួយនឹងអ្នកចូលរួមមាន គណៈគ្រប់គ្រង(នាយក/នាយករង/នាយិកា) ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

## ៣.១ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ៤ប្រភេទ តាមបែបបរិមាណវិស័យ និងបែបគុណវិស័យដោយបន្សុីគ្នាជាមួយកម្រងសំណួរទាំងពីរនៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចស្រាវជ្រាវនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០២០ តាមផែនការគ្រោងទុក។ ការចុះប្រមូលទិន្នន័យ គឺធ្វើឡើងនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងក្រុមគោលដៅសម្រាប់បំពេញកម្រងសំណួរមាន៤ប្រភេទ គណៈគ្រប់គ្រង(នាយក/នាយករង/នាយិកា) ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

## ៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ក្នុងអំឡុងពេលបិទសាលារៀនដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រូបង្រៀនតាមសាលារដ្ឋចាប់ផ្តើមបង្រៀន និងដឹកនាំសិស្សរៀនតាមអនឡាញ។ លិខិតឧទ្ទេសនាមពីក្រសួងអប់រំ យុវជន និងកីឡា លេខ ១៩៧ វដអ ផ.ក ចុះថ្ងៃ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ

២០២០ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ ឱ្យចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញ (Online Google Form) ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេស ជាមួយគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរួចមកអ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានធ្វើការសហការជាមួយគណៈគ្រប់គ្រង ការិយាល័យរដ្ឋបាល ការិយាល័យសិក្សា ដើម្បីស្នើសុំធ្វើការប្រមូលទិន្នន័យទៅតាមការជ្រើសរើសសំណាកដែលបានគ្រោងទុក។

ក្នុងការប្រមូលទិន្នន័យខាងលើនេះ គឺត្រូវបានប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ ក្នុងការប្រមូលទិន្នន័យប្រើប្រាស់តាមរយៈ Online ដោយប្រើកម្រងសំណួរបំពេញតាមរយៈ(Google Form) ក្នុងនោះកម្រងសំណួរចែកចេញជាបួនប្រភេទ៖(១) កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង (២) កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធាន (៣)កម្រងសំណួរសម្រាប់គ្រូឧទ្ទេស និង(៤)កម្រងសំណួរសម្រាប់គរុនិស្សិត (១២+៤) សម្រាប់តែកម្រិតមធ្យមសិក្សា។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានប្រើប្រាស់កម្រងសំណួរដែលមានលក្ខណៈជាទម្រង់បិទ និងទម្រង់បើកសម្រាប់ឱ្យក្រុមគោលដៅធ្វើការបំពេញ និងឆ្លើយសំណួរទៅតាមទស្សនៈយល់ឃើញរបស់ពួកគេ។ កម្រងសំណួរទាំងនោះមានបួនប្រភេទដូចជា៖ ទី(១)កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង(នាយក/នាយករង/នាយិកា) ទី(២)កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធាន ទី(៣)កម្រងសំណួរសម្រាប់គ្រូឧទ្ទេស និងទី(៤)កម្រងសំណួរសម្រាប់គរុនិស្សិត។

### ៣.៣.១ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញដែលបានប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតជាក់លាក់។ កម្រិតចង្អុលបង្ហាញ ដោយបំពេញតាមរយៈអនឡាញនៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៤កម្រិតតាមបែប Ordinal Scale គឺជាកម្រិតលំដាប់លំដោយ និងចំណាត់ថ្នាក់ទិន្នន័យដែលត្រូវបានគេស្គាល់ថាជាទិន្នន័យមានគុណភាពដែលប្រើប្រាស់ទៅលើទិន្នន័យបរិមាណវិស័យ។ កម្រិតចង្អុលបង្ហាញនេះ គឺប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃលើកម្រិតនៃការអនុវត្ត និងដំណើរការបំពេញការងាររបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិតនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មាន៤កម្រិត ពីកម្រិតខ្ពស់បំផុត ទៅកម្រិតទាបបំផុត ដែលមានកម្រិតចង្អុលបង្ហាញដូចតទៅ៖

កម្រិតពេញចិត្ត៖

- កម្រិតពេញចិត្តខ្លាំងណាស់
- កម្រិតពេញចិត្ត
- កម្រិតមិនពេញចិត្ត
- កម្រិតមិនពេញចិត្តទាល់តែសោះ

កម្រិតយល់ស្រប៖

- កម្រិតយល់ស្របខ្លាំងណាស់
- កម្រិតយល់ស្រប
- កម្រិតមិនយល់ស្រប

- កម្រិតមិនយល់ស្របទាល់តែសោះ

និងកម្រិតស្រប៖

- កម្រិតសមស្របណាស់
- កម្រិតសមស្រប
- កម្រិតមិនសមស្រប
- កម្រិតមិនសមស្របទាល់តែសោះ

ក្នុងការបកស្រាយទៅលើការគណនាពីការប្រមូលទិន្នន័យ ដើម្បីវិភាគរកភាគរយនៃសូចនាករនីមួយៗ។ ដើម្បីឆ្លើយតបនឹងប្រធានបទនេះ ការវិភាគទៅលើសូចនាករនីមួយៗមានការគណនាបែងចែកចេញជាភាគរយនៅក្នុងចំណោមទំហំសំណាកទាំងអស់ ដោយការវាស់វែងនេះធ្វើឡើងបានអាស្រ័យលើប្រភេទសំណួរនីមួយៗដែលមាន៥ផ្នែកធំៗនៅក្នុងកម្រងសំណួរទាំង៤ប្រភេទសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

### ៣.៣.២ កម្រងសំណួរ

គោលបំណងនៃកម្រងសំណួរនេះ ដើម្បីសិក្សាស្វែងយល់ពី ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា១២+៤ និងស្វែងរកពីបញ្ហាប្រឈមនានាដើម្បីដោះស្រាយការលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែប្រសើរឡើងស្របនឹងតម្រូវការទីផ្សារនាពេលបច្ចុប្បន្ន និងអនាគត ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះមានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អដើម្បីឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី ។

#### ៣.៣.២.១ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស

កម្រងសំណួរសម្រាប់គ្រូឧទ្ទេស ដែលត្រូវប្រើប្រាស់សម្រាប់គ្រូឧទ្ទេសដែលកំពុងបង្រៀន១២+៤កម្រិតមធ្យមសិក្សា ឆ្នាំទី១ និងឆ្នាំទី២ ដែលចែកចេញជា៥ផ្នែកធំៗគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅមាន ទាក់ទងទៅនឹងតួនាទី ភេទ អាយុ កម្រិតវប្បធម៌ មុខជំនាញឯកទេស បទពិសោធន៍ការងារ និងចំណេះដឹងភាសាបរទេស។

**ផ្នែកទី២៖** ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សាដែលទាក់ទងទៅនឹង៣ចំណុចធំៗ

**ផ្នែកទី៣៖** ការអនុវត្តកម្មវិធីសិក្សា (ការបង្រៀន និងរៀន សម្ភារៈឧបទេស ) ដែលទាក់ទងនឹង៨ចំណុចធំៗ

**ផ្នែកទី៤៖** ការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈដែលទាក់ទងទៅនឹង៧ចំណុចធំៗមានដូចជា

**ផ្នែកទី៥៖** បញ្ហាប្រឈម និងមតិយោបល់

### ៣.៣.២.២ កម្រងសំណួរសម្រាប់គរុនិស្សិត

កម្រងសំណួរសម្រាប់គរុនិស្សិត ដែលត្រូវប្រើប្រាស់សម្រាប់គរុនិស្សិតដែលកំពុងទទួលការបណ្តុះបណ្តាលកម្រិតមូលដ្ឋាន១២+៤ ឆ្នាំទី១ និងឆ្នាំទី២ ដែលចែកចេញជា៥ផ្នែកធំៗគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅ ទាក់ទងទៅនឹងភេទ អាយុ កម្រិតវប្បធម៌ មុខជំនាញឯកទេស និងចំណេះដឹងភាសាបរទេស។

**ផ្នែកទី២៖** ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សាដែលទាក់ទងទៅនឹង៣ចំណុចធំៗ

**ផ្នែកទី៣៖** ការអនុវត្តកម្មវិធីសិក្សា (ការបង្រៀន និងរៀន សម្ភារៈឧបទេស) ដែលទាក់ទងទៅនឹង៨ចំណុចធំៗ

**ផ្នែកទី៤៖** ការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈដែលទាក់ទងទៅនឹង៧ចំណុចធំៗមានដូចជា

**ផ្នែកទី៥៖** បញ្ហាប្រឈម និងមតិយោបល់

### ៣.៣.១.៣ កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធាន

កម្រងសំណួរសម្រាប់ប្រធាន/អនុប្រធាន ដែលត្រូវប្រើប្រាស់សម្រាប់ប្រធាន/អនុប្រធានការិយាល័យសិក្សា ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់ ប្រធាន/អនុប្រធានការិយាល័យធានាគុណភាពផ្ទៃក្នុង ដែលចែកចេញជា៥ផ្នែកធំៗគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅមាន ទាក់ទងទៅនឹងតួនាទី ភេទ អាយុ កម្រិតវប្បធម៌ មុខជំនាញឯកទេស បទពិសោធន៍ការងារ និងចំណេះដឹងភាសាបរទេស។

**ផ្នែកទី២៖** ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សាដែលទាក់ទងទៅនឹង៣ចំណុចធំៗ

**ផ្នែកទី៣៖** ការអនុវត្តកម្មវិធីសិក្សា (ការបង្រៀន និងរៀន សម្ភារៈឧបទេស ) ដែលទាក់ទងនឹង៨ចំណុចធំៗ

**ផ្នែកទី៤៖** ការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈដែលទាក់ទងទៅនឹង៧ចំណុចធំៗមានដូចជា

**ផ្នែកទី៥៖** បញ្ហាប្រឈម និងមតិយោបល់

### ៣.៣.២.៣ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង ដែលត្រូវប្រើប្រាស់ សម្រាប់នាយក/នាយករង/នាយិការង ដែលចែកចេញជា៥ផ្នែកធំៗគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅមាន ទាក់ទងទៅនឹងតួនាទី ភេទ អាយុ កម្រិតវប្បធម៌ មុខជំនាញឯកទេស បទពិសោធន៍ការងារ និងចំណេះដឹងភាសាបរទេស។

**ផ្នែកទី២៖** ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សាដែលទាក់ទងទៅនឹង៣ចំណុចធំៗ

**ផ្នែកទី៣៖** ការអនុវត្តកម្មវិធីសិក្សា (ការបង្រៀន និងរៀន សម្ភារៈឧបទេស ) ដែលទាក់ទងនឹង៨ចំណុចធំៗ

**ផ្នែកទី៤៖** ការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈដែលទាក់ទងទៅនឹង៧ចំណុចធំៗ

**ផ្នែកទី៥៖** បញ្ហាប្រឈម និងមតិយោបល់

## ៣.៤ ការជ្រើសរើសភាគសំណាក

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដោយជ្រើសរើសសំណាកសម្រាប់សិក្សាស្រាវជ្រាវរួមមាន៖ គណៈគ្រប់គ្រងខាងក្រោមនេះ ជាតារាងលម្អិតនៃការជ្រើសរើសភាគសំណាកដោយប្រើវិធីតាមបែប Taro Yamane (១៩៦៧) ជាមួយភាពជឿជាក់៩៥%។

*តារាងទី 5 ៖ ភាគសំណាកដែលត្រូវបានជ្រើសរើសក្នុងការសិក្សាស្រាវជ្រាវ*

| ភាគសំណាក | ចំនួន | ស្រី |
|---|---|---|
| គណៈគ្រប់គ្រង | ៣ | ១ |
| ប្រធាន/អនុប្រធាន | ១១ | ៦ |
| គ្រូឧទ្ទេស | ២១ | ៨ |
| គរុនិស្សិត | ៧៩ | ៤៤ |
| **សរុបភាគសំណាក** | **១១៤** | **៥៩** |

## ៣.៥ ការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបនឹងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងសំណួរអំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានធ្វើការវិភាគតាមបែបបរិមាណវិស័យដោយប្រើជាប្រភេទ Ordinal Scale (កម្រិតពី១ដល់៤)។ ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់មានដូចជា គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។ ជាបឋមអ្នកសិក្សាស្រាវជ្រាវបានធ្វើការវិភាគដាច់ដោយឡែកពីគ្នាទៅតាមប្រភេទអថេរនីមួយៗ ដើម្បីយកមកសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅតាមផ្នែកនីមួយៗនៃកម្រងសំណួរ។ បន្ទាប់មកទៀតការសិក្សាស្រាវជ្រាវនេះអ្នកស្រាវជ្រាវបានប្រើប្រាស់កម្មវិធី Excel សម្រាប់គណនារកកម្រិតភាគរយនិងសម្រាប់ធ្វើជាក្រាបនៅក្នុងការវិភាគទិន្នន័យដើម្បីយកមកបកស្រាយអោយចេញជាព័ត៌មាន។ស្របគ្នានេះដែរដើម្បីឆ្លើយតប

ទៅនឹងសំណួរស្រាវជ្រាវដែលទាក់ទងទៅនឹងប្រសិទ្ធភាពនៃការអនុវត្តការកម្មវិធីសិក្សា១២+៤នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដែលការសិក្សាស្រាវជ្រាវនេះបានធ្វើការវិភាគទិន្នន័យតាមបែបសំណួរបើកដោយធ្វើការស្រង់យកនូវបញ្ហាប្រឈម និងចំណុចខ្លាំងរបស់សំណាកនីមួយៗយកមកបង្ហាញ ហើយចាប់ជាក្រុមទៅតាមប្រភេទបញ្ហាប្រឈម និងចំណុចខ្លាំងនានាទៅតាមសំណាកទើបធ្វើការសន្និដ្ឋានរួមទៅលើប្រសិទ្ធភាពទាំងនោះដោយផ្អែកលើចម្លើយរបស់អ្នកចូលរួមដែលមានគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិតតាមរយៈការបំពេញកម្រងសំណួរទាំងអស់ហើយត្រូវបានធ្វើឡើងដោយវិធីសាស្ត្រវិភាគទិន្នន័យតាមបែបគុណវិស័យ។

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកអ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយលទ្ធផលនិងពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈបំពេញកម្រងសំណួរលើក្រុមគោលដៅដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវរួមមាន៖ គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិតនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ទៅនឹងទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវកន្លងមក មាននៅក្នុងជំពូកទី២ ។ នៅក្នុងជំពូកទី៤នេះ នឹងបង្ហាញនូវចំណុចសំខាន់ៗដែលបានចោទសួរក្នុងសំណួរស្រាវជ្រាវទាក់ទងនឹង ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា ១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ។ ការស្រាវជ្រាវពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ដោយសិក្សាលើការរៀបចំកម្មវិធីសិក្សា ធនធានគាំទ្រដល់ការសិក្សា ការបង្រៀន និងវិធីសាស្ត្របង្រៀន រួមទាំងបញ្ហាប្រឈមនានាដែលវិទ្យាស្ថាន គ្រូឧទ្ទេស និងគរុនិស្សិត បានជួបប្រទះកន្លងមកសម្រាប់លើកយកមកបកស្រាយតាមលទ្ធផលជាក់ស្តែង និងធ្វើការវិភាគវែកញែករវាងលទ្ធផលដែលបានរកឃើញទៅនឹងទ្រឹស្តីដែលបានលើកឡើងដោយអ្នកស្រាវជ្រាវកន្លងមក។ លើសពីនេះទៅទៀត អ្នកសិក្សាស្រាវជ្រាវក៏បានបង្ហាញពីទស្សនៈយល់ឃើញលើការអនុវត្តកម្មវិធីសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញផងដែរដើម្បីទុកជាធាតុចូល និងជំរុញគុណភាពនៃការបណ្តុះបណ្តាលគ្រូឱ្យស្របតាមស្តង់ដារជាតិ និងអន្តរជាតិ។

## ៤.១. ការវិភាគទិន្នន័យលើកម្រងសំណួរដែលទទួលបានពីការឆ្លើយតបរបស់អ្នកចូលរួមបំពេញកម្រងសំណួរ

ក្នុងការសិក្សាស្រាវជ្រាវនេះ លទ្ធផលដែលទទួលបានពីការបំពេញកម្រងសំណួររបស់អ្នកចូលរួមនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ក្នុងនោះរួមមានគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិតបានបង្ហាញថា៖

### ៤.១.១ ទិន្នន័យព័ត៌មានទូទៅ

*តារាងទី 6 ៖ ចំនួនសំណាកអ្នកចូលរួមក្នុងការបំពេញកម្រងសំណួរ*

| អ្នកចូលរួម | ចំនួនសរុប | ស្រី |
|---|---|---|
| គណៈគ្រប់គ្រង | ៣ | ១ |
| ប្រធានអនុប្រធាន/ | ១១ | ៦ |
| គ្រូឧទ្ទេស | ២១ | ៨ |
| គរុនិស្សិត | ៧៩ | ៤៤ |
| សរុប | ១១៤ | ៥៩ |
| **%សរុប** | **១០០%** | **៥២%** |

តាមតារាងខាងលើបានបង្ហាញថា មានអ្នកចូលរួម ចំនួន១១៤នាក់ ក្នុងនោះស្រី៥៩នាក់ ដែលមានចំនួន ៥១.៧៥% ជាស្រី ដែលបានចូលរួមពីគណៈគ្រប់គ្រង៣%(៣នាក់) ប្រធាន/អនុប្រធាន១០%(១១នាក់) គ្រូឧទ្ទេស១៨%(២១នាក់) និងគរុនិស្សិត៦៩%ពីគរុនិស្សិត(៧៩នាក់) ដែលជាអ្នកដឹកនាំ គ្រប់គ្រង និងជាអ្នកដែលបានអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ផ្ទាល់។

*តារាងទី 7 ៖ អាយុអ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ*

| អ្នកចូលរួម | ក្រោម ២០ឆ្នាំ | ចន្លោះពី ២០ ឆ្នាំ ទៅ ៣០ ឆ្នាំ | ចន្លោះពី ៣០ ឆ្នាំ ទៅ ៤០ឆ្នាំ | ពី៤០ឆ្នាំឡើងទៅ | សរុប |
|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ០ | ០ | ០ | ៣ | ៣ |
| ប្រធាន/អនុប្រធាន | ០ | ១ | ៧ | ៣ | ១១ |
| គ្រូឧទ្ទេស | ០ | ៣ | ១៦ | ២ | ២១ |
| គរុនិស្សិត | ៣៧ | ៤២ | ០ | ០ | ៧៩ |
| សរុប | ៣៧ | ៤៦ | ២៣ | ៨ | ១១៤ |
| **%សរុប** | **៣២%** | **៤០%** | **២០%** | **៧%** | **១០០%** |

តាមតារាងខាងលើ បានបង្ហាញថា ក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរភាគច្រើន សម្រាប់គរុនិស្សិតគឺស្ថិតនៅអាយុក្រោម២០ឆ្នាំ៣២%(៣៧នាក់)និងចន្លោះអាយុចាប់ពី២០ឆ្នាំទៅ៣០ឆ្នាំ៤០%(៤៦នាក់) ។ ដោយឡែកសម្រាប់គ្រូឧទ្ទេស និងប្រធាន/អនុប្រធាន ភាគច្រើនមានអាយុចាប់ពី៣០ឆ្នាំឡើងទៅ៤០ឆ្នាំ ២០%(២៣នាក់) និងគណៈគ្រប់គ្រប់គ្រងគឺ អាយុចាប់ពី៤០ឆ្នាំឡើងមាន៧%(៨នាក់)។

*តារាងទី ៩ ៖ បទពិសោធន៍អ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ*

| អ្នកចូលរួម | បណ្ឌិត | បរិញ្ញាបត្រជាន់ខ្ពស់ | បរិញ្ញាបត្រ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ចំនួនស្រី | សរុប |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ១ | ២ | ០ | ០ | ១ | ៣ |
| ប្រធាន/អនុប្រធាន | ០ | ៩ | ២ | ០ | ៦ | ១១ |
| គ្រូឧទ្ទេស | ០ | ១៥ | ៦ | ០ | ៨ | ២១ |
| គរុនិស្សិត | ០ | ០ | ១៩ | ៦០ | ៤៤ | ៧៩ |
| សរុប | ១ | ២៦ | ២៧ | ៦០ | ៥៩ | ១១៤ |
| **%សរុប** | **០.៨៨%** | **២២.៨១%** | **២៣.៦៨%** | **៥២.៦៣%** | **៥១.៧៥%** | **១00%** |

តាមតារាងខាងលើបានបង្ហាញថា កម្រិតវប្បធម៌របស់អ្នកចូលរួមភាគច្រើន ដែលជាគរុនិស្សិតទទួលបានការអប់រំកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានមានចំនួន៥២.៦៣%(៦០នាក់) កម្រិតបរិញ្ញាបត្រមានចំនួន២៣.៦៨% (២៧នាក់) នៃចំនួនអ្នកចូលរួមពីប្រធាន/អនុប្រធាន (២នាក់) គ្រូឧទ្ទេស(៦នាក់) និងគរុនិស្សិត(១៩នាក់)និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់២២.៨១%(២៦នាក់)នៃចំនួនអ្នកចូលរួមពីគណៈគ្រប់គ្រង (២នាក់)ប្រធាន/អនុប្រធាន(៩នាក់)គ្រូឧទ្ទេស(១៥នាក់) និងមានគណៈគ្រប់គ្រងដែលទទួលបានការអប់រំដល់កម្រិតបណ្ឌិត០.៨៨%(១នាក់) ។

កម្រិតចំណេះដឹងរបស់គរុនិស្សិតដែលបានចូលមកសិក្សានៅវិទ្យាស្ថានគរុកោសល្យរាជធានីមានកម្រិតខុសៗគ្នាដោយគរុនិស្សិតមួយចំនួន បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យរួចមកហើយ ក្នុងនោះមាន២៤% ទទួលបានបរិញ្ញាបត្រឯកទេស និង៧៦%ទៀត ជាសិស្សទើបបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ។ ចំពោះគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញវិញ មាន៧១%បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងមានតែ ២៩% ប៉ុណ្ណោះដែលស្ថិតនៅកម្រិតបរិញ្ញាបត្រ។

ជារួម កម្រិតវប្បធម៌និងចំណេះដឹងរបស់អ្នកចូលរួម ភាគច្រើនពួកគាត់មានចំណេះដឹងសមស្របនឹងស្តង់ដាររបស់វិទ្យាស្ថានក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា។ ដោយឡែកមានចំនួនមួយភាគតូចប៉ុណ្ណោះនៃក្រុមអ្នកឆ្លើយតបគ្រូឧទ្ទេស ដែលវិទ្យាស្ថានគរុកោសល្យរាជធានីគួរយកចិត្តទុកដាក់ និងជម្រុញលើកទឹកចិត្តឱ្យបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីឱ្យស្របទៅនឹងគុណវុឌ្ឍិគ្រូបង្រៀន។

*តារាងទី ១ ៖ បទពិសោធន៍អ្នកឆ្លើយតបក្នុងការបំពេញកម្រងសំណួរ*

| អ្នកចូលរួម | ចន្លោះពី ១ឆ្នាំ ដល់ ៥ ឆ្នាំ | ចន្លោះពី ៦ ឆ្នាំ ដល់ ១០ ឆ្នាំ | ចន្លោះពី ១១ ឆ្នាំ ដល់ ១៥ ឆ្នាំ | លើសពី ១៥ ឆ្នាំ | សរុប |
|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ០ | ០ | ១ | ២ | ៣ |
| ប្រធាន/អនុប្រធាន | ០ | ៣ | ៣ | ៥ | ១១ |
| គ្រូឧទ្ទេស | ២ | ៦ | ៨ | ៥ | ២១ |
| សរុប | ២ | ៩ | ១២ | ១២ | ៣៥ |
| **%សរុប** | **៥.៧១%** | **២៥.៧១%** | **៣៤.២៩%** | **៣៤.២៩%** | **១00%** |

តាមតារាងខាងលើបានបង្ហាញថាបទពិសោធន៍ការងារសម្រាប់អ្នកចូលរួមដែលមានបទពិសោធន៍ការងារលើសពី១៥ឆ្នាំ និងចន្លោះពី១១ឆ្នាំដល់១៥ឆ្នាំ គឺមានចំនួនច្រើនដូចគ្នា៣៤.២៩%(១២នាក់) ហើយសម្រាប់

អ្នកដែលមានបទពិសោធន៍ការងារ ចន្លោះពី៦ឆ្នាំដល់១០ឆ្នាំ មានចំនួន២៥.៧១%(៩នាក់) និងអ្នកដែលមានពិសោធន៍ការងារតិចជាងគេ នៅចន្លោះពី១ឆ្នាំដល់៥ឆ្នាំ មានចំនួន៥.៧១%(២នាក់)។

យោងតាមទិន្នន័យនៃអ្នកចូលរួមជាគ្រូឧទ្ទេសមានបទពិសោធន៍ក្នុងការបង្រៀន គឺចាប់ពីចន្លោះ៦ឆ្នាំដល់១០ឆ្នាំ២៩%(៦នាក់) ចន្លោះពី១១ឆ្នាំដល់១៥ឆ្នាំ ៣៨.០៩%(៨នាក់) និងលើសពី១៥ឆ្នាំ២៤%(៥នាក់) ដោយឡែកមាន៩%(២នាក់)ក្នុងចំណោមគ្រូឧទ្ទេសដែលបានចូលរួមគាត់មានបទពិសោធន៍ ចន្លោះពី១ឆ្នាំដល់៥ឆ្នាំនេះ។ ទាំងនេះ គឺជាធាតុចូលដ៏សំខាន់សម្រាប់ដំណើរនៅការវិទ្យាស្ថានគរុកោសល្យព្រោះតាមរយៈបទពិសោធន៍ការងារបន្ថែមនឹងការពង្រឹងបន្ថែមនូវវិធីសាស្ត្រថ្មីៗទៀតវាផ្នែកមួយជួយបង្កើនល្បឿនឆ្ពោះទៅការការអនុវត្តកម្មវិធីសិក្សាកាន់តែមានប្រសិទ្ធភាពខ្ពស់ដែលស្របទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

*តារាងទី 10 ៖ ចំណេះដឹងភាសាបរទេស(ភាសាអង់គ្លេស)*

| អ្នកចូលរួម | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | ខ្សោយណាស់ | សរុប |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ២ | ០ | ០ | ១ | ០ | ៣ |
| ប្រធាន/អនុប្រធាន | ១ | ៧ | ០ | ៣ | ០ | ១១ |
| គ្រូឧទ្ទេស | ១ | ១៥ | ០ | ៥ | ០ | ២១ |
| គរុនិស្សិត | ១ | ៥០ | ០ | ២៣ | ៥ | ៧៩ |
| សរុប | ៥ | ៧២ | ០ | ៣២ | ៥ | ១១៤ |
| **%សរុប** | **៤.៣៩%** | **៦៣.១៦%** | **0%** | **២៨.០៧%** | **៤.៣៩%** | **១00%** |

តាមតារាងខាងលើបានបង្ហាញថាចំណេះដឹងភាសាបរទេស(ភាសាអង់គ្លេស) របស់អ្នកចូលរួមភាគច្រើនមានកម្រិតល្អ៦៣.១៦%(៧២នាក់) កម្រិតខ្សោយមានចំនួន២៨.០៧%(៣២នាក់) កម្រិតល្អណាស់និង

ខ្សោយណាស់មាន៤.៣៩%(៥នាក់) ដែលមានកម្រិតស្មើគ្នានេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

កម្រិតភាសាបរទេសរបស់ក្រុមអ្នកឆ្លើយតបជាគរុនិស្សិត បានបង្ហាញថាមាន៤៣.៨៦%(៥០នាក់)នៃចំនួនគរុនិស្សិត ដែលមានចំណេះដឹងភាសាបរទេស(អង់គ្លេស)បានល្អ ហើយមានតែម្នាក់ប៉ុណ្ណោះ០.៨៨% (នាក់)ដែលមានសមត្ថភាពអាចប្រើប្រាស់ភាសាអង់គ្លេសក្នុងកម្រិតល្អណាស់ ដោយឡែក២៤.៥៧% (២៨នាក់)ទៀតស្ថិតនៅកម្រិតខ្សោយនិងខ្សោយណាស់ (ខ្សោយ២០.១៨% និង ខ្សោយណាស់៤.៣៩%) ដូចគ្នានេះដែរ ក្នុងចំណោមគ្រូឧទ្ទេស ២១ នាក់ មាន ៥នាក់ (ប្រហែល ៤.៣៩%) មានកម្រិតភាសាអង់គ្លេសនៅមានកម្រិតទាប។

ជារួមគុណវុឌ្ឍិនៃការប្រើប្រាស់ចំណេះដឹងភាសាបរទេសសម្រាប់អ្នកចូលរួមក្នុងការស្រាវជ្រាវនេះភាគច្រើនពួកគាត់គឺមានចំណេះដឹងល្អក្នុងការនិយាយ សរសេរ និងស្តាប់ភាសាបរទេស ខណៈដែលនៅមានចំនួនមួយចំនួនតូចទៀតដែលវិទ្យាស្ថានគួរតែយកចិត្តទុកដាក់ក្នុងការបំប៉នដល់បុគ្គលិករបស់ខ្លួនឱ្យមានគុណវុឌ្ឍិខ្ពស់ក្នុងការប្រើប្រាស់ភាសាអង់គ្លេសដើម្បីជាទុនងាយស្រួលក្នុងការស្រាវជ្រាវនូវវិធីសាស្ត្របង្រៀនថ្មីៗ។

## ៤.១.២ ទិន្នន័យឆ្លើយតបទៅលើកម្មវិធីសិក្សា




*ក្រាហ្វទី 1៖ កម្រិតពេញចិត្តទៅនឹងការអនុវត្តកម្មវិធីសិក្សា*

តាមក្រាហ្វខាងលើបង្ហាញថា  លទ្ធផលនៃការស្រាវជ្រាវអំពីកម្រិតនៃការពេញចិត្តក្នុងការអនុវត្តកម្មវិធី១២+៤ នៅវិទ្យាស្ថានគរុកោសល្យ គណៈគ្រប់គ្រង បុគ្គលិក គ្រូឧទ្ទេស និងគរុនិស្សិតនៃវិទ្យាស្ថានគរុកោសល្យរាជធានី ពេញចិត្តនឹងការអនុវត្តម្មវិធីសិក្សា១២+៤ដែលមានកម្រិតពេញចិត្តខ្លាំងណាស់មានចំនួន២៣.៦៨% (២៧នាក់) កម្រិតពេញចិត្តចំនួន៧៤.៥៦%(៨៥នាក់) ហើយកម្រិតមិនពេញចិត្ត និងកម្រិតមិនពេញចិត្ត ទាល់តែសោះមានចំនួន០.៨៨%(១នាក់)។

សរុបជារួម  អ្នកចូលរួមស្រាវជ្រាវទាំងអស់មានការពេញចិត្តនិងពេញចិត្តខ្លាំងទៅលើការអនុវត្តកម្មវិធីសិក្សាថ្មី ១២ +៤ នៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនេះ ខណៈដែលមានគរុនិស្សិតតែម្នាក់គត់ដែលលើកឡើង

ពីការមិនពេញទៅលើការអនុវត្តកម្មវិធីសិក្សានេះ។ ដែលនេះអាចទាញទៅរកលទ្ធផលមួយដែលសមស្រប សម្រាប់គ្រូឧទ្ទេសក៏ដូចជាគរុនិស្សិតអនុវត្តក្នុងការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាពខ្ពស់។




*ក្រាហ្វទី 2៖ កម្រិតសមស្របក្នុងការកំណត់វត្ថុបំណងទៅតាមឯកទេសនីមួយៗ*

តាមក្រាហ្វខាងលើបានបង្ហាញពី ការយល់ឃើញរបស់អ្នកចូលរួមពីកម្មវិធីសិក្សានេះបានកំណត់វត្ថុបំណងក្នុងការរៀនសូត្រសមរម្យ និងតាមឯកទេសរបស់សិស្សនីមួយៗ មានកម្រិតសមស្របណាស់មានចំនួន ១០.៥៣%(១២នាក់) កម្រិតសមស្របចំនួន៨៥.០៩%(៩៧នាក់) និងកម្រិតមិនសមស្របមានចំនួន ៤.៣៩%(៥នាក់) ដែលជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួមអ្នកចូលរួមមានការយល់ស្របប៨៥.០៩%នេះជាកម្រិតល្អ ដែលយល់ឃើញទៅលើកម្មវិធីមានការកំណត់វត្ថុបំណងច្បាស់លាស់ទៅគ្រប់ឯកទេសដែលបានបណ្តុះបណ្តាល។ ដោយឡែកមានចំនួនតិចតួចណាស់ដែលមិនយល់ស្របគឺត្រឹម៤.៣៩%ប៉ុណ្ណោះ តែទោះបីជាយ៉ាងនេះក្តីសម្រាប់វិទ្យាស្ថានគួរមានការពិនិត្យទៅ

លើបំណែងចែកកម្មវិធីក៏ដូចជាវត្ថុបំណងមេរៀនគ្រប់ឯកទេសដើម្បីធានាគុណភាពអប់រំសម្រាប់បន្តទៅជំនាន់ក្រោយៗទៀតកាន់តែមានប្រសិទ្ធភាព។




*ក្រាហ្វទី 3៖ កម្រិតសមស្របទៅនឹងចំណេះដឹង សមត្ថភាពរបស់គ្រូឧទ្ទេស និងគរុនិស្សិតទៅនឹងការអនុវត្តកម្មវិធីសិក្សា*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីកម្មវិធីសិក្សា១២+៤ ដែលសមស្របទៅនឹងចំណេះដឹងសមត្ថភាពគ្រូឧទ្ទេស មានកម្រិតសមស្របណាស់មានចំនួន១៣.១៦%(១៥នាក់) កម្រិតសមស្របមានចំនួន៨៥.០៩%(៩៧នាក់) និងកម្រិតមិនសមស្របមានចំនួន១.៧៥%(២នាក់) ដែលជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជាសរុប ឆ្លងតាមការអនុវត្តកម្មវិធីសិក្សាថ្មី គ្រប់ក្រុមអ្នកឆ្លើយតប បានយល់ឃើញថា ការរៀបចំកម្មវិធីសិក្សា ១២+៤ នេះពិតជាសមស្របទៅនឹងចំណេះដឹង សមត្ថភាព ទាំងគ្រូឧទ្ទេស និងគរុនិស្សិត។




*ក្រាហ្វទី 4៖ កម្រិតយល់ដឹងរបស់គ្រូឧទ្ទេសចំពោះកម្មវិធីសិក្សាថ្មី និងបំណែងចែកកម្មវិធីសម្រាប់បង្រៀន*

តាមក្រាហ្វខាងលើបានបង្ហាញពីការឆ្លើយតបរបស់អ្នកចូលរួម គឺកម្រិតសមស្របមានចំនួន៩៤.២៩% (៣៣នាក់) និងកម្រិតមិនសមស្របមានចំនួន៥.៧១%(២នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន និងគ្រូឧទ្ទេស។

ជារួមតាមរយៈលទ្ធផលដែលទទួលបានពីការឆ្លើយតបរបស់អ្នកចូលរួមមានចំនួន៩៤.២៩%នេះគឺជាចំនួនច្រើនដែលបានយល់ស្របខ្លាំងលើកម្រិតយល់ដឹងរបស់គ្រូឧទ្ទេសចំពោះកម្មវិធីសិក្សាថ្មីនេះទៅលើបំណែងចែក ដូចលទ្ធផលទទួលបានតាមរយៈក្រាហ្វខាងលើបានបញ្ជាក់យ៉ាងច្បាស់ថាគ្រូឧទ្ទេសបានរៀបចំបំណែងចែកកម្មវិធីសម្រាប់បង្រៀនច្បាស់លាស់។




*ក្រាហ្វទី 5៖ កម្រិតការយល់ដឹងអំពីទស្សនៈវិស័យលើការលើកម្ពស់គុណភាពបង្រៀននិងរៀន*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីបុគ្គលិកទាំងអស់មានទស្សនៈវិស័យក្នុងការលើកកម្ពស់គុណភាពបង្រៀននិងរៀន ដែលមានកម្រិតយល់ស្របខ្លាំងណាស់២៨.០៧%(៣២នាក់) កម្រិតយល់ស្រប៦៨.៤២%(៧៨នាក់) ហើយកម្រិតមិនយល់ស្របនិងកម្រិតមិនយល់ស្របទាល់តែសោះមានត្រឹមចំនួនតិចតួច១.៧៥%(២នាក់)ដែលមានចំនួនតួលេខស្មើគ្នា ដែលទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ដូចនេះ ចំពោះបុគ្គលិករបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មានការយល់ច្បាស់ខ្លាំងទៅលើទស្សនៈវិស័យរបស់វិទ្យាស្ថាន តែក៏នៅមានបុគ្គលិក និងគរុនិស្សិតមួយចំនួនតូចដែរ ដែលមិនទាន់បានដឹងពីទស្សនៈវិស័យនេះច្បាស់នៅឡើយ ។ តែទោះបីជាយ៉ាងដូចនេះក៏ដោយ គណៈគ្រប់គ្រងរបស់វិទ្យាស្ថានគួរតែពន្យល់អំពីទស្សនៈវិស័យទាំងនេះឱ្យដល់បុគ្គលិក និងគរុនិស្សិតទាំងអស់នោះឱ្យបានច្បាស់ទាំងអស់គ្នា ។

### ៩.១.៣ ទិន្នន័យឆ្លើយតបទៅលើការអនុវត្តកម្មវិធីសិក្សា (ការបង្រៀននិងរៀននិងសម្ភារៈឧបទេស)




*ក្រាហ្វទី 6៖ កម្រិតងាយស្រួលក្នុងការផលិតសម្ភារៈឧបទេស*

តាមក្រាហ្វខាងលើបានបង្ហាញថា កម្មវិធីសិក្សានេះងាយស្រួលក្នុងការផលិតសម្ភារឧបទេស ដែលក្នុងនោះ កម្រិតសមស្របណាស់មានចំនួន៣.៥១%(៤នាក់) កម្រិតសមស្របមានចំនួន៥២.៦៣%(៦០នាក់) និង កម្រិតមិនសមស្របមានចំនួន៤៣.៨៦%(៥០នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួមមក តាមរយៈទិន្នន័យបានបង្ហាញពីក្រាបខាងលើទាក់ទងនឹងការផលិតសម្ភារៈឧបទេសឱ្យស្រប និងស៊ីជាមួយមេរៀនសម្រាប់គ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត៤៣.៨៥% គាត់មានសមត្ថភាពក្នុងការផលិតសម្ភារៈឧបទេស តែដោយឡែកមានគ្រូឧទ្ទេស និងគរុនិស្សិត៤១.៥០% យល់ឃើញថាពិបាកក្នុងការផលិត ។ គឺមានភាគរយប្រហាក់ប្រហែល ដូចនេះ ជាចំណុចមួយដែលគួរឱ្យកត់សម្គាល់សម្រាប់វិទ្យាស្ថានគរុកោសល្យគួរយកចិត្តទុកដាក់ពិនិត្យឡើងវិញពាក់ព័ន្ធនឹងសម្ភារៈឧបទេសដើម្បីផ្តល់ភាពងាយស្រួលទៅដល់ការអនុវត្តកម្មវិធី

សិក្សា ជាពិសេសគួរមានវគ្គបំប៉នទៅដល់បុគ្គលិកអប់រំ ជាពិសេសដល់គ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិតដែលជាអ្នកអនុវត្តផ្ទាល់ដើម្បីពង្រឹងនូវគុណភាពអប់រំព្រោះជាទុនដ៏សំខាន់ដើម្បីទៅរកការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀន។




*ក្រាហ្វទី 7៖ កម្រិតងាយស្រួលក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀនជាប្រចាំ*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមកម្មវិធីសិក្សា១២+៤ ងាយស្រួលសម្រាប់គ្រូឧទ្ទេសក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀនប្រចាំថ្ងៃដោយប្រើធនធានដែលមានស្រាប់ដែលមានកម្រិតសមស្របណាស់៤.៣៩%(៥នាក់) កម្រិតសមស្របមានចំនួន៥៣.៥១%(៦១នាក់) និងកម្រិតមានចំនួន៤២.១១%(៤៨នាក់) ដែលយល់ឃើញថាជួបនូវការពិបាកក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀនជាប្រចាំថ្ងៃ ដែលនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

សរុបជារួម សម្រាប់ការអនុវត្តកម្មវិធីសិក្សា ១២ + ៤ នៅក្នុងការបង្រៀននិងរៀន ក្រុមអ្នកឆ្លើយតបជា ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត ប្រហែល ៥៣.៥១% យល់ឃើញថា មានភាពងាយស្រួលក្នុងការបង្រៀន និងរៀន ដោយឡែក ប្រហែល ៤២.១១% មានការលំបាកទាំងការបង្រៀននិងរៀន។ ការលំបាកនេះក៏បាន លើកឡើងនៅក្នុងការផលិតសម្ភារៈឧបទេស ការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀន ហើយកម្រិតនៃភាពលំបាកនេះហាក់ដូចជាមានកម្រិតសមស្របខ្លាំងមាន៤.៣៩%(៥នាក់) ហើយប្រហែលជា៤២.១១%(៤៨នាក់)ដែលពិបាកក្នុងការផលិតសម្ភារៈ និងពិបាកក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀន នេះជាភាគរយមួយដែលប្រហាក់ប្រហែលគ្នាដែលអាចនាំឱ្យដំណើរការបង្រៀននិងរៀនជួបបញ្ហាប្រឈម។ ដូច្នេះវិទ្យាស្ថានគរុកោសល្យគួរពង្រឹងបន្ថែមដោយបំប៉នទៅដល់បុគ្គលិក ជាពិសេសទៅដល់គ្រូឧទ្ទេសនៅវិទ្យាស្ថានដើម្បីបន្ថែមនូវចំណេះដឹង ជំនាញដែលមានស្រាប់។




*ក្រាហ្វទី ៩៖ កម្រិតងាយស្រួលក្នុងការបង្រៀននិងរៀន*

តាមក្រាហ្វខាងលើបានបង្ហាញថា កម្មវិធីសិក្សា១២+៤ ងាយស្រួលក្នុងការបង្រៀននិងរៀន ក្នុងនោះកម្រិតសមស្របណាស់មានចំនួន៣.៥១%(៤នាក់) កម្រិតសមស្របមានចំនួន៦៤.៩១%(៧៤នាក់) និងកម្រិត

មិនសមស្របមានចំនួន៣១.៥៨%(៣៦នាក់) ដែលទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

តួយ៉ាងសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត មានការយល់ឃើញថា ការបង្រៀននិងរៀនតាមកម្មវិធីសិក្សាថ្មីនេះបានផ្តល់ងាយស្រួលកម្រិតល្អ៣.៥១%(៤នាក់) ដោយឡែកមានគ្រូឧទ្ទេស និងគរុនិស្សិត២៨.៩៥% (៣៣នាក់) ដែលយល់ឃើញថាមានការពិបាកក្នុងការបង្រៀននិងរៀន ។ ទាំងនេះអាចមកពីគ្រូឧទ្ទេស ជាពិសេសគរុនិស្សិតមួយចំនួនធំដែលទើបតែបញ្ចប់កម្រិតសញ្ញាបត្រទុតិយភូមិពួកគាត់បានយល់មិនទាន់ច្បាស់ពីកម្មវិធីសិក្សាថ្មី ដូចនេះទាមទារពេលវេលាបន្ថែមដើម្បីសិក្សាស៊ីជម្រៅ។




*ក្រាហ្វទី ១៖ កម្រិតយល់ដឹងអំពីការបង្រៀនតាមរយៈការបង្កើតសម្ភារៈឧបទេសសិក្សាសំបូរបែប*

តាមក្រាហ្វខាងលើបានបង្ហាញថា ការយល់ឃើញរបស់អ្នកចូលរួមលើគ្រូឧទ្ទេសយល់ដឹងអំពីការបង្រៀនតាមរយៈការបង្កើតសម្ភារៈឧបទេសសិក្សាសំបូរបែប ដែលមានកម្រិតសមស្របណាស់មានចំនួន៤.៣៩% (៥នាក់) កម្រិតសមស្របមានចំនួន៧៥.៤៤%(៨៦នាក់) កម្រិតមិនសមស្របមានចំនួន១៨.៤២%

(២១នាក់) និងកម្រិតមិនសមស្របទាល់តែសោះមានចំនួន១.៧៥%(២នាក់) ដែលជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួមក្នុងការដំណើរកម្មវិធីសិក្សាទៅបានអាស្រ័យដោយមានការចូលរួមយ៉ាងសកម្មទៅលើចំណេះដឹង ជំនាញរួមទាំងបំណិនប្រសប់របស់បុគ្គលម្នាក់ៗ ក្នុងការចូលរួមចំណែកផលិតនូវឧបករណ៍ជំនួយសម្រាប់បំពេញទៅក្នុងការអនុវត្តជាក់ស្តែង ។ ដូចនេះវិទ្យាស្ថានគរុកោសល្យរាជធានី គួរជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកអប់រំជាពិសេសគ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិតបណ្តុះនូវជំនាញបន្ថែមដល់ពួកគាត់ក្នុងការផលិតនូវសម្ភារៈសំបូរបែបដើម្បីផ្តល់ភាពងាយស្រួលដល់ការបង្រៀននិងរៀន។




*ក្រាហ្វទី 10៖ កម្រិតយល់ដឹង និងអនុវត្តបច្ចេកទេសបំផុសគំនិតផ្សេងៗ ក្នុងការបង្រៀន*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមមានការយល់ដឹង និងអនុវត្តបច្ចេកទេសបំផុសគំនិតផ្សេងៗ ក្នុងការបង្រៀន ដែលមានកម្រិតសមស្របណាស់មានចំនួន១១.៤០%(១៣នាក់)

កម្រិតសមស្របមានចំនួន៧៦.៣២%(៨៧នាក់) និងកម្រិតមិនសមស្របមានចំនួន១២.២៨%(១៤នាក់) នេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ក្រៅពីចំណេះដឹង ជំនាញ ឥរិយាបថ ការប្រើបច្ចេកទេសបំផុសគំនិតពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សមត្ថភាពដល់គរុនិស្សិត ដើម្បីផ្តល់បទពិសោធន៍ដល់ពួកគាត់អាចយកទៅប្រើប្រាស់បន្ត។




*ក្រាហ្វទី 11៖ កម្រិតក្នុងការប្រើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាព*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមលើការយល់ស្របទៅលើការប្រើយុទ្ធស្រាស្ត និងវិធីសាស្ត្របង្រៀនខុសៗគ្នាច្រើននឹងនាំឱ្យមានប្រសិទ្ធភាពជាងការប្រើយុទ្ធសាស្ត្រ និងវិធីសាស្ត្រតែមួយ ក្នុងនោះកម្រិតសមស្របខ្លាំងណាស់មានចំនួន៤៣.៨៦%(៥០នាក់) កម្រិតសមស្របមានចំនួន៥១.៧៥% (៥៩នាក់) និងកម្រិតមិនសមស្របមានចំនួន៤.៣៩%(៥នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

សរុបមក យើងឃើញថាគ្រូឧទ្ទេសភាគច្រើន ដែលគាត់មានការយល់ស្របចំពោះការប្រើវិធីសាស្ត្រច្រើនក្នុងការបង្រៀនព្រោះប្រសិនបើការបង្រៀនមិនបានប្រើវិធីសាស្ត្រច្រើន និងមានភាពបត់បែនទេ នោះភាពទាក់ទាញក៏មិនអាចកើតមានឡើងដែរ។ ដូច្នេះទាមទារបុគ្គលិកអប់រំ ជាពិសេសគ្រូឧទ្ទេសគួរសិក្សាស្រាវជ្រាវ និងបំពេញបន្ថែមទៅលើវិធីសាស្ត្របង្រៀនបែបថ្មីនិងទាន់សម័យកាលទើបសកម្មភាពក្នុងថ្នាក់មានភាពរស់រវើក។




*ក្រាហ្វទី 12៖ កម្រិតភាពជឿជាក់លើការបង្រៀនប្រកបដោយប្រសិទ្ធភាព*

តាមក្រាហ្វខាងលើបានបង្ហាញ ពីការយល់ឃើញរបស់អ្នកចូលរួមពីគ្រូឧទ្ទេសមានស្មារតី និងភាពជឿជាក់លើការបង្រៀនដើម្បីទទួលបានប្រសិទ្ធភាពខ្ពស់ក្នុងនោះកម្រិតសមស្របណាស់មានចំនួន៧.១៤%(១នាក់) កម្រិតសមស្របមានចំនួន៧១.៤៣%(១០នាក់) និងកម្រិតមិនសមស្របមានចំនួន២១.៤៣%(៣នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន។

ដោយផ្អែកទៅលើការឆ្លើយតបរបស់អ្នកចូលរួមឃើញថាមានកម្រិតនៃការយល់ស្របរហូតដល់ទៅ៧១.៤៣% ដែលនេះជាកម្រិតមួយខ្ពស់ ទាំងអស់នេះជាធាតុចូលដ៏ចម្បងក្នុងការប្តេជ្ញាចិត្តរបស់បុគ្គលិកអប់រំនៅវិទ្យាស្ថាន

គរុកោសល្យរាជធានីភ្នំពេញជាពិសេសគ្រូឧទ្ទេសផ្ទាល់ក្នុងពុះពាររាល់បញ្ហានានាដើម្បីឈានទៅរកប្រសិទ្ធភាពនៃការអនុវត្ត។




*ក្រាហ្វទី 13៖ កម្រិតសមស្របក្នុងការអនុវត្តជាក់ស្តែង*

តាមក្រាហ្វខាងលើបានបង្ហាញថា កម្មវិធីសិក្សាថ្មីនេះបានប្រើពេលវេលាសមស្របក្នុងការអនុវត្តជាក់ស្តែងកម្រិតសមស្របណាស់មានចំនួន៨.៧៧%(១០នាក់) កម្រិតសមស្របមានចំនួន៧៦.៣២%(៨៧នាក់) កម្រិតមិនសមស្របមានចំនួន១៤.០៤%(១៦នាក់) និងកម្រិតមិនសមស្របទាល់តែសោះមានចំនួន ០.៨៨%(១នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ការអនុវត្តកម្មវិធីសិក្សាជាក់ស្តែងនៅវិទ្យាស្ថានគរុកោសល្យរយៈពេលកន្លងមកមានដំណើរការសមស្របទៅនឹងកម្មវិធីដែលបានដាក់ ក៏ប៉ុន្តែដោយសារតែកម្មវិធីនេះជាកម្មវិធីថ្មី ធ្វើឱ្យគ្រូឧទ្ទេសចំណាយពេលវេលាច្រើន និងបន្ថែមការងារលើសក្នុងការសិក្សាស្វែងយល់ពីកម្មវិធីនេះ។ មួយវិញទៀត កម្មវិធីសិក្សាថ្មីកំពុងតែ

អនុវត្តបណ្តើរ កសាងបណ្តើរ ដែលជាហេតុធ្វើឱ្យគ្រូឧទ្ទេសមួយចំនួនពិបាកក្នុងការបង្រៀនពីកម្មវិធីថ្មីនេះ។ ដូចនេះវិទ្យាស្ថានគួរតែរៀបចំនិងពិនិត្យទៅលើកម្មវិធីនេះឱ្យបានមុនដើម្បីកុំឱ្យប៉ះពាល់ទៅដល់ដំណើរការបង្រៀននិងរៀនរបស់គ្រូឧទ្ទេស និងគរុនិស្សិត។




*ក្រាហ្វទី 14៖ កម្រិតឆ្លើយតបជាមួយនឹងតម្រូវការរបស់សិស្ស*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមកម្មវិធីសិក្សា១២+៤ នេះឆ្លើយតបជាមួយនឹងតម្រូវការរបស់សិស្សដែលមាន កម្រិតសមស្របណាស់មានចំនួន១៤.០៤%( ១៦នាក់) កម្រិតសមស្របមានចំនួន៧៨.៩៥%( ៩០នាក់) កម្រិតមិនសមស្របមានចំនួន៦.១៤%( ៧នាក់) និងកម្រិតមិនសមស្របទាល់តែសោះមានចំនួន០.៨៨%( ១នាក់) ដែលបានយល់ថាមានកម្រិតមិនល្អទាល់តែសោះ ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ដោយយោងតាមទិន្នន័យនៃការឆ្លើយតបរបស់អ្នកចូលរួមភាគច្រើនយល់ឃើញថាកម្មវិធីសិក្សាពិតជាបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងគរុនិស្សិតដែលបានអនុវត្តកន្លងមក។




*ក្រាហ្វទី 15៖ កម្រិតវិសាលភាពការបង្រៀនដោយផ្ទាល់ និងដោយប្រយោល*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួម ទៅលើកម្មិធីសិក្សាថ្មីនេះ ថាវិសាលភាព នៃការបង្រៀនដោយផ្ទាល់ និង ដោយប្រយោលនៃមេរៀន ដែលក្នុងនោះកម្រិតសមស្របណាស់មានចំនួន ១៩.៣០%(២២នាក់) កម្រិតសមស្របមានចំនួន៧៦.៣២%(៨៧នាក់) និងកម្រិតមិនសមស្របមានចំនួន ៤.៣៩%(៥នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុ និស្សិត។

រយៈពេលកន្លងមក យើងឃើញថាការរីករាលដាលជំងឺកូវីដ-១៩ មានការប៉ះពាល់ទៅដល់ការបង្រៀននិងរៀនរបស់គ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត។ ដោយសារតែគរុនិស្សិតភាគច្រើនគាត់មកពីតាមខេត្តមកបន្តការបណ្តុះបណ្តាលនៅរាជធានីភ្នំពេញ នៅពេលជួបបញ្ហាភ្លាមៗ និងបន្ទាន់គឺពិបាកក្នុងការបត់បែន។ ដូចនេះ ជាបទពិសោធន៍សម្រាប់វិទ្យាស្ថានគរុកោសល្យ ក៏ដូចជាគ្រឹះស្ថានបណ្តុះបណ្តាលនានា ជាពិសេស ក្រសួងអប់រំ

យុវជន និងកីឡា គួរមានការគិតគូរដោយមានវិធានការទប់ទល់នឹងហានិភ័យមួយចំនួនដែលអាចកើតឡើងភ្លាមដើម្បីចូលរួមទប់ស្កាត់រាល់បញ្ហាដែលនឹងកើតឡើងទៅមុខទៀត។

### **៤.១.៤ ទិន្នន័យឆ្លើយតបទៅលើការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈ**




*ក្រាហ្វទី 16៖ កម្រិតទំនួលខុសត្រូវ (គោរពេលវេលា)*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមរបស់គណៈគ្រប់គ្រង និងប្រធាន/អនុប្រធាន មើលឃើញថាគ្រូឧទ្ទេសមានទំនួលខុសត្រូវក្នុងការគោរពពេលវេលាបង្រៀន(ការគោរពម៉ោងពេលវេលា) ដែលមានកម្រិតសមស្របណាស់មានចំនួន១៧.១៤%(៦នាក់) កម្រិតសមស្របមានចំនួន៧៤.២៩% (២៦នាក់) និងកម្រិតមិនសមស្របមានចំនួន៨.៥៧%(៣នាក់)តែប៉ុណ្ណោះ។ ការលើកឡើងនេះ សរបញ្ជាក់ឱ្យឃើញថា គ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញស្ទើរតែទាំងអស់នៃចំនួនអ្នកចូលរួមឆ្លើយតប បានគោរពនូវពេលវេលា ដែលវិទ្យាស្ថានបានកំណត់ប្រកបដោយការទទួលខុសត្រូវ។ ដោយឡែកទន្ទឹមនឹងមានចំនួនគ្រូឧទ្ទេសច្រើនដែលមានការគោរពក៏ពិតមែន តែក៏នៅមានគ្រូឧទ្ទេសតិចតួចដែលនៅមានបញ្ហាទៅនឹងម៉ោងពេលក្នុងការបំពេញភារកិច្ចរបស់ខ្លួនផងដែរ។ ដូចនេះគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន

គួរគិតគូរពិចារណារកដំណោះស្រាយដាក់លាក់ណាមួយដើម្បីជំរុញពួកគាត់ឱ្យមានភាពទទួលខុសត្រូវជៀស វាងមានបាតុភាពមិនល្អដែលនាំឱ្យប៉ះពាល់ទៅដល់ការបង្រៀននិងរៀនរបស់គរុនិស្សិត។




*ក្រាហ្វទី 17៖ កម្រិតរៀបចំសមស្របសមត្ថភាព និងពង្រីកវិសាលភាពនៃការបង្រៀននិងរៀន*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីការរៀបចំសមស្របសមត្ថភាព និងពង្រីក វិសាលភាពនៃការបង្រៀននិងរៀន ដើម្បីសម្រេចបានគោលបំណង ក្នុងនោះដែរកម្រិតសមស្របណាស់មាន ចំនួន៨.៧៧%(១០នាក់) កម្រិតសមស្របមានចំនួន៨៣.៣៣%(៩៥នាក់) កម្រិតមិនសមស្របមានចំនួន ៧.០២%(៨នាក់) និងកម្រិតមិនសមស្របទាល់តែសោះ០.៨៨%(១នាក់) ទាំងនេះជាទស្សនៈយល់ឃើញ ពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ការជំរុញគាំទ្រ និងលើកចិត្តក្នុងការពង្រីកវិសាលភាពនៃការបង្រៀន ជាចំណុចសំខាន់បំផុតគ្រប់អង្គ ភាព ឬស្ថាប័ននានា ជាពិសេសវិទ្យាស្ថានគរុកោសល្យរាជធានី គួរតែបន្ថែមការយកចិត្តទុកដាក់ដល់បុគ្គលិក

អប់រំ ជាពិសេសគ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត ព្រោះការចូលរួមអនុវត្តទៅបានអាស្រ័យដោយមានការចូលរួមពីគ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត ព្រោះពួកគាត់ជាអ្នកដែលអនុវត្តដោយផ្ទាល់។




*ក្រាហ្វទី 18៖ ពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូឧទ្ទេសជាប្រចាំ*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីការពិនិត្យតាមដាន លើដំណើរការបង្រៀនរបស់គ្រូឧទ្ទេសជាប្រចាំ ដែលក្នុងនោះកម្រិតសមស្របណាស់មានចំនួន១.៧៥%(២នាក់) កម្រិតសមស្របមានចំនួន៧៨.០៧%(៨៩នាក់) និងកម្រិតមិនសមស្របមានចំនួន២០.១៨%(២៣នាក់) ទាំងអស់នេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ដំណើរការបង្រៀននិងរៀន ទាមទារនូវទម្រង់ជាក់លាក់ និងច្បាស់លាស់ដោយមានតម្លាភាពសម្រាប់ជាឧបករណ៍វាយតម្លៃដល់ការបង្រៀននិងរៀន។ ដូចដែលមានការយល់ស្របពីអ្នកចូលរួម ជាគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន ជាពិសេសេគ្រូឧទ្ទេស និងគរុនិស្សិត៧៨.០៧% ដែលយល់ស្របឱ្យមានការពិនិត្យតាមដាន និងធ្វើការវាយតម្លៃ ពីដំណើរការបង្រៀននិងរៀនប្រកបដោយគុណភាព។




*ក្រាហ្វទី 19៖ កម្រិតប្រើប្រាស់បច្ចេកទេសក្នុងការវាយតម្លៃការបង្រៀន និងរៀន*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីការប្រើប្រាស់បច្ចេកទេសក្នុងកាវាយតម្លៃការបង្រៀននិងរៀន ដើម្បីឆ្លើយតប និងសម្រេចគោលបំណង ដែលក្នុងនោះកម្រិតសមស្របណាស់មានចំនួន ២.៨៦%(៤នាក់) កម្រិតសមស្របមានចំនួន៥១.៤៣%(១៨នាក់) និងកម្រិតមិនសមស្របមានចំនួន ៣៧.១៤%(១៣នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន និងគ្រូឧទ្ទេស។

ជារួម ដើម្បីទទួលបានប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី គឺអាស្រ័យលើការវាយតម្លៃការបង្រៀននិងរៀនជាគោល ប្រសិនបើមិនមានប្រព័ន្ធវាយតម្លៃជាក់លាក់ណាមួយទេ ការបង្រៀននិងរៀន ក៏មិនអាចអភិវឌ្ឍន៍បានល្អដែរ។ ដូចនេះទាមទារ គ្រូឧទ្ទេស និងគរុនិស្សិតស្វែងយល់ និងបង្កើននូវការចូលរួមដើម្បីធានាបានការអប់រំប្រកបដោយគុណភាព និងតម្លាភាព។




*ក្រាហ្វទី 20៖ កម្រិតយល់ឃើញអំពីនិរន្តភាពក្នុងការអនុវត្ត*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីកម្មវិធីសិក្សា១២+៤ អាចនឹងមាននិរន្តភាពក្នុងការអនុវត្តកម្រិតល្អ និងអាចអនុវត្តបាន ដែលក្នុងនោះកម្រិតសមស្របណាស់ ដែលអាចអនុវត្តបានរហូតមានចំនួន១៤.២៩%(៥នាក់) និងកម្រិតសមស្របបានមានចំនួន៨០%(២៨នាក់) និងមានចំនួនតិចតួចដែលមិនសមស្របគឺមានតែ៦%(២នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន និងគ្រូឧទ្ទេស។

ជារួម គ្រប់អ្នកចូលរួមបានយល់ស្របចំពោះការអនុវត្តកម្មវិធីសិក្សានេះអាចមាននិរន្តភាពរហូត ព្រោះវិស័យអប់រំនៅប្រទេសកម្ពុជាមានការកែទម្រង់ជាហូរហែ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារនាពេលបច្ចុប្បន្ន និងនាពេលអនាគត។ ក្នុងនោះផងដែរសម្រាប់កម្រិតបង្រៀននៅអនុវិទ្យាល័យយ៉ាងហោចណាស់ក៏មានត្រឹមកម្រិតបរិញ្ញាបត្រដែរ ទើបអាចអភិវឌ្ឍន៍ធនធានមនុស្សកាន់តែរីកចម្រើនដើម្បីបម្រើដល់វិស័យអប់រំ និងឆ្លើយតបទៅនឹងផ្សារការងារ។




*ក្រាហ្វទី 21៖ កម្រិតនៃការទំនាក់ទំនងជាមួយខ្លឹមសារមេរៀនឯកទេស និងវិធីសាស្ត្រផ្សេង*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមអំពីកម្មវិធីសិក្សាថ្មីនេះមានទំនាក់ទំនងជាមួយខ្លឹមសារមេរៀនឯកទេសនិងវិធីសាស្ត្រផ្សេង ក្នុងនោះដែរកម្រិតសមស្របណាស់មានចំនួន១០.៥៣% (១២នាក់) កម្រិតសមស្របមានចំនួន៨៥.៩៦%(៩៨នាក់) និងកម្រិតមិនសមស្របមានចំនួន៣.៥១% (៤នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម សម្រាប់ខ្លឹមសារមេរៀន និងវិធីសាស្ត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀននិងរៀន ដោយគ្រូជាអ្នកផ្ទេរនូវចំណេះដឹង ជំនាញ និងបំណិនទៅដល់សិស្សប្រសិនបើគ្រូឧទ្ទេសខ្លួនឯងផ្ទាល់មិនយល់ពីខ្លឹមសារលម្អិតទាក់ទងនឹងមេរៀនឯកទេស ក៏ដូចជាវិធីសាស្ត្របង្រៀនដោយមានភាពបត់បែនទេ គឺបញ្ហានឹងកើតមានឡើងសម្រាប់គរុនិស្សិតដែលបានទទួលការបណ្តុះបណ្តាលមានការភ័នច្រឡំទៅនឹងវិធីសាស្ត្រដែលនាំមានការប៉ះពាល់ទៅដល់ការអភិវឌ្ឍធនធានមនុស្សទូទាំងប្រទេស។




*ក្រាហ្វទី 22៖ កម្រិតជំរុញ និងលើកទឹកចិត្តគ្រូ-សិស្សក្នុងការចូលរួមជាអតិបរមាក្នុងមេរៀននីមួយៗ*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមអំពីកម្មវិធីសិក្សានេះ បានជំរុញ និងលើកទឹកចិត្តគ្រូ-សិស្សក្នុងការចូលរួមជាអតិបរមាក្នុងមេរៀននីមួយៗ ដែលក្នុងនោះដែរកម្រិតសមស្របណាស់មានចំនួន១៣.១៦%(១៥នាក់) កម្រិតសមស្របមានចំនួន៨៤.២១%(៩៦នាក់) និងកម្រិតមិនសមស្របចំនួន២.៦៣%(៣នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ឆ្លងតាមការឆ្លើយតបពីអ្នកចូលរួមបានបង្ហាញឱ្យឃើញថា កម្រិតនៃការជំរុញ និងលើកទឹកចិត្ត នៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញយល់ស្របបេ៨៤.២១% ដែលលទ្ធផលនេះអាចឆ្លុះបញ្ចាំងបានថា ជាផលវិជ្ជមានមួយ ដើម្បីបាញ់ឆ្ពោះទៅដល់ការចូលរួមចំណែកក្នុងសកម្មភាពបង្រៀននិងរៀនកាន់តែសកម្ម។




*ក្រាហ្វទី 23៖ កម្រិតងាយស្រួលក្នុងការប្រើបច្ចេកទេសក្នុងការវាយតម្លៃការសិក្សារបស់សិស្ស*

តាមក្រាហ្វខាងលើបានបង្ហាញពីការយល់ឃើញរបស់អ្នកចូលរួមពីកម្មវិធីសិក្សានេះមានលក្ខណៈងាយស្រួលក្នុងការប្រើបច្ចេកទេសក្នុងការវាយតម្លៃការសិក្សារបស់សិស្សដើម្បីឆ្លើយតបនិងសម្រេចគោលបំណង ក្នុងនោះ កម្រិតសមស្របណាស់មានចំនួន៨.៧៧%(១០នាក់) កម្រិតសមស្របមានចំនួន៧៣.៦៨%(៨៤នាក់) និងកម្រិតមិនសមស្របមានចំនួន១៧.៥៤%(២០នាក់) ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ក្នុងការបង្រៀននិងរៀន ការវាយតម្លៃការសិក្សារបស់សិស្ស ពិតជាដើរតួនាទីយ៉ាងសំខាន់សម្រាប់បំពេញនូវលទ្ធផលសិក្សារបស់សិស្ស បើមិនមានការវាយតម្លៃជាក់លាក់ចំពោះលទ្ធផលសិក្សារបស់សិស្សនោះការអប់រំពិតជាពុំអាចទទួលបានប្រសិទ្ធភាពនោះទេ។ ដូចនៅក្នុងកម្មវិធីសិក្សាថ្មី គេមានបែងចែកច្បាស់លាស់ទៅតាមផែនការ តាមប្រព័ន្ធក្រេឌីត តាមសប្តាហ៍ ទាំងនេះនេះជាការបង្ហាញនូវលទ្ធផលជាក់លាក់ងាយស្រួលដល់គ្រូឧទ្ទេសធ្វើការវាយតម្លៃប្រកបដោយភាពច្បាស់លាស់ និងសុក្រិត ព្រោះមានទម្រង់វាយតម្លៃជាក់លាក់ និងច្បាស់លាស់ងាយស្រួលក្នុងការអនុវត្ត។




*ក្រាហ្វទី 24៖ កម្រិតចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាពតាមរយៈ ការសង្កេត និងការវាយតម្លៃ*

តាមក្រាហ្វខាងលើបានបង្ហាញពីកម្រិតចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាពតាមរយៈ ការសង្កេត និងការវាយតម្លៃ ក្នុងនោះកម្រិតសមស្របណាស់មានចំនួន១២.២៨%(១៤នាក់) កម្រិតសមស្របមានចំនួន៨១.៥៨%(៩៣នាក់) និងកម្រិតមិនសមស្របមានចំនួនត្រឹមតែ៦.១៤%(៧នាក់)តែប៉ុណ្ណោះ ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត។

ជារួម ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាពពិតជាការចូលរួមចំណែកដ៏ធំមួយ សម្រាប់ពង្រឹងគុណភាពអប់រំ ក៏ដូចជាអភិវឌ្ឍន៍នូវធនធានមនុស្ស ដើម្បីសង្គមជាតិរីកចម្រើនទៅទាន់សម័យកាល ហើយក្នុងនោះផងដែរយើងឃើញថា កម្រិតនៃការយល់ស្របប៨១.៥៨% នេះជាកម្រិតមួយល្អ ព្រោះគ្រូឧទ្ទេសមានបំណងក្នុងការអភិវឌ្ឍនូវសមត្ថភាពរបស់ខ្លួន ស្របទៅនឹងវិទ្យាស្ថាន ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា បានកំណត់យ៉ាងហោចណាស់ សម្រាប់គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យមានកម្រិតត្រឹមបរិញ្ញាបត្រជាន់ខ្ពស់ឡើងដែរ។




*ក្រាហ្វទី 25៖ កម្រិតក្នុងចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាលដល់បុគ្គលិកវិទ្យាស្ថាន*

តាមក្រាហ្វខាងលើបានបង្ហាញពី ការចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាលទៅដល់បុគ្គលិកក្នុងវិទ្យាស្ថាន ក្នុងនោះដែរកម្រិតសមស្របណាស់មានចំនួន១៤.២៩%(២នាក់) កម្រិតសមស្រប និងកម្រិតមិនសមស្របចំនួន៤២.៨៦%(៦នាក់)គឺមានកម្រិតស្មើគ្នា។ ទាំងនេះជាទស្សនៈយល់ឃើញពីការចូលរួមរបស់គណៈគ្រប់គ្រង និងប្រធាន/អនុប្រធាន ។

តាមទិន្នន័យដែលទទួលបានពីអ្នកចូលរួមខាងលើមានចំនួនយល់ស្រប៤២.៨៦% ដែលជាកម្រិតមួយល្អ តែទោះជាយ៉ាងនេះក្តី វិទ្យាស្ថានគួរមានការយកចិត្តទុកដាក់លើចំណុចដែលនៅខ្វះចន្លោះ ចំពោះការចែករំលែកនូវចំណេះដឹងថ្មីៗទាក់ទងទៅនឹងកម្មវិធីសិក្សាថ្មីនេះ ដល់បុគ្គលិកអប់រំ ជាពិសេសគ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត ដើម្បីទទួលបាននូវចំណេះដឹងថ្មី ជួយជំរុញដល់ការអនុវត្តកម្មវិធីកាន់តែទទួលបានគុណភាពខ្ពស់។

### ៤.១.៥ ទិន្នន័យឆ្លើយតបទៅលើបញ្ហាប្រឈមក្នុងពេលដំណើរការអនុវត្តកម្មវិធីសិក្សា

ទន្ទឹមនឹងនោះផងដែរក៏មានគរុនិស្សិត និងគ្រូឧទ្ទេសតិចបំផុតដែលយល់ថា កម្មវិធីនេះមានការលំបាក និងមិនឆ្លើយតបទៅនឹងសមត្ថភាពរបស់គរុនិស្សិត ។

*" គឺពិបាកត្រង់គរុនិស្សិតមួយចំនួនមានសមត្ថភាពមិនគ្រប់គ្រាន់នៅក្នុងការរៀន"*

*"...ខ្លឹមសារពិបាកយល់ និងទាមទារពេលវេលាស្រាវជ្រាវច្រើន"*

*"គឺខ្ញុំមានការខ្សោយខាងអង់គ្លេសនិងព័ត៌មានវិទ្យា"*

*"...មានកម្មវិធីសិក្សាលម្អិត ប៉ុន្តែឯកសារខ្លះពិបាករក ខ្វះមន្ទីរពិសោធន៍ជាពិសេសឯកសារជាភាសាខ្មែរ"*

មូលហេតុទាំងនេះអាចពាក់ព័ន្ធនឹងកម្មវិធីសិក្សានេះ ថ្មីពេកសម្រាប់គ្រូឧទ្ទេស ក៏ដូចជាគរុនិស្សិត ធ្វើឱ្យពួកគាត់មិនទាន់បន្សាំពីរបៀបបង្រៀននិងរៀនតាមវិធីថ្មីនេះ។ មួយវិញទៀត ចំណេះដឹងផ្នែកភាសាអង់គ្លេសរបស់គរុនិស្សិត និងគ្រូឧទ្ទេស ជាឧបសគ្គមួយក្នុងការស្វែងរក និងទទួលចំណេះដឹង។ ហើយគ្រូឧទ្ទេសមួយចំនួនពុំទាន់ទទួលការបណ្ដុះបណ្ដាលនូវវិធីសាស្ត្របង្រៀនថ្មីៗនៅឡើយ។

ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នេះផងដែរ បានធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចប្រើប្រាស់ការអប់រំពីចម្ងាយដើម្បីចៀសវាងនិងចូលរួមកាត់បន្ថយការរីករាលដាលនៃជំងឺកូវីដ១៩នេះ។ ដូចគ្នានេះ ដំណើរការបង្រៀននិងរៀននៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ក៏បានដំណើរការ និងអនុវត្តការសិក្សាអប់រំពីចម្ងាយដោយបានកំណត់យក Telegram Channel ជាមូលដ្ឋានមជ្ឈមណ្ឌលឯកសារ (មជ្ឈមណ្ឌលសិក្សា)។ លើសពីនេះទៀតគ្រូឧទ្ទេសបានបង្កើតបណ្ដាញទំនាក់ទំនងផ្សេងៗទៀតដោយប្រើប្រាស់ឧបករណ៍ បច្ចេកវិទ្យាជាជំនួយដូចជា Google Classroom, Google Meet, Zoom Meeting, Telegram Group, YouTube Channel ជាដើម..។ល។ ដើម្បីជួយពិភាក្សា ឬដាក់ និងទទួលកិច្ចការស្រាវជ្រាវបន្ថែម ព្រមទាំងកិច្ចការវាយតម្លៃសម្រាប់គរុនិស្សិត។ បច្ចេកវិទ្យា សេវាអ៊ីនធឺណែត និងសម្ភារៈគាំទ្រដល់ការសិក្សាពី

ចម្ងាយ សម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត គឺទាមទារជាចាំបាច់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងរលូននៃដំណើរការបង្រៀនពីចម្ងាយ។ ការផ្លាស់ប្តូរនេះពិតណាស់ បានជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការបង្រៀននិងរៀនរបស់គរុនិស្សិតកំឡុងពេលដែលបញ្ហាជំងឺកូវីដ-១៩ បានរីករាលដាលក្នុងរយៈពេលកន្លងមកនេះ។ ទាំងអស់នេះដែលវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញបានជួបនូវបញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមផ្សេងទៀត គឺ ចំណេះដឹងលើបច្ចេកវិទ្យារបស់គ្រូឧទ្ទេស និងគរុនិស្សិត សម្រាប់ប្រើប្រាស់នូវឧបករណ៍បង្រៀនពីចម្ងាយ គឺនៅមានកម្រិតនៅឡើយ រួមផ្សំនិងការផ្លាស់ប្តូរបន្ទាន់ ធ្វើឱ្យមានពេលវេលាតិចសម្រាប់អនុវត្តការរៀនសូត្រ។ បន្ថែមពីនេះ បញ្ហាដែលគរុនិស្សិតលើកឡើងជាប្រចាំ ទាក់ទងនឹងបណ្តាញសេវាទូរស័ព្ទ និងសេវាអ៊ីនធឺណែតពិបាកក្នុងការប្រើប្រាស់ដោយសារសេវាអ៊ីនធឺណែតមិនអំណោយផល។ ដូចបានដឹងហើយថា គរុនិស្សិតដែលមកបន្តការសិក្សានៅវិទ្យាស្ថានគរុកោសល្យភាគច្រើនរស់នៅតាមខេត្ត ដែលតំបន់ខ្លះពុំសូវមាន បណ្តាញសេវាអ៊ីនធឺណែតគ្រប់គ្រាន់ ធ្វើឱ្យមានការអាក់ខានក្នុងការចូលរៀន និងធ្វើកិច្ចការមួយចំនួន។ អ្វីដែលពិបាកសម្រាប់គរុនិស្សិត ក៏ដូចជាគ្រូឧទ្ទេសផងដែរនោះ គឺការខ្វះខាតឧបករណ៍ប្រើប្រាស់ដូចជាកុំព្យូទ័រ... ជាដើម សម្រាប់បម្រើដល់ការរៀបចំឯកសារមេរៀនដូចជារៀបចំស្លាយដើម្បី ផលិតជាវីដេអូ ថតការពិសោធ និងធ្វើសកម្មភាពផ្សេងៗទៀតដែលបម្រើដល់ការអនុវត្តកម្មវិធីសិក្សានេះ។ ដែលបញ្ហាលំបាកទាំងនេះបាន ជះឥទ្ធិពលជាអវិជ្ជមានដល់ដំណើរការបង្រៀនរបស់គ្រូឧទ្ទេសនិងការរៀនរបស់គរុនិស្សិត។

សរុបរួមមក ទាក់ទងនឹងកិច្ចការស្រាវជ្រាវគរុនិស្សិតស្ទើរតែងទាំងអស់បង្ហាញអំពីការពេញចិត្ត និងការរីកចម្រើនរបស់ខ្លួនទៅលើការអាន ការសរសេរ និងការសហការគ្នា ហើយជាពិសេស គឺការអភិវឌ្ឍខ្លួនឯង ដូចជាភាពម្ចាស់ការជាដើម *"ខ្ញុំមានភាពជឿជាក់លើសមត្ថភាពខ្លួនឯងជាងមុន"* ។ តែទន្ទឹមនឹងនេះ គរុនិស្សិតប្រហែលជា ៣៥% (២៨នាក់)បានសង្កត់ធ្ងន់ថា *"ការរៀនសូត្រនិងកិច្ចការស្រាវជ្រាវ មានសម្ពាធច្រើន.."* និង ប្រហែលជា ៩០% នៃអ្នកឆ្លើយតបជាគរុនិស្សិត បង្ហាញអំពីភាពកង្វះខាតឯកសារ និងសម្ភារៈសម្រាប់ធ្វើ

ការសិក្សាស្រាវជ្រាវ ដូចជាកុំព្យូទ័រ សេវាអ៊ីនធឺណែត ដែលជាឧបសគ្គចម្បងនៅក្នុងសិក្សារបស់ខ្លួន។ ជាក់ស្តែងស្ថានភាពបណ្ណាល័យរបស់វិទ្យាស្ថានបច្ចុប្បន្នមានលក្ខណៈមិនទាន់សមស្របនឹងស្តង់ដារ សៀវភៅឬឯកសារមានតិចតួច ហើយភាគច្រើនជាសៀវភៅចាស់ៗ ។ ដោយឡែក នៅបណ្ណាល័យប្រព័ន្ធកត់ត្រាសៀវភៅនៅមានកម្រិត ធ្វើឱ្យពិបាករក និងមិនទាន់អាចគ្រប់គ្រងទន្និន័យបាន។ ថ្មីៗនេះ វិទ្យាស្ថានបានដាក់បញ្ចូលនូវឯកសារថ្មីៗ ជាភាសាបរទេស(ភាសាអង់គ្លេស)ជាច្រើន ដើម្បីឱ្យគរុនិស្សិតក៏ដូចជាគ្រូឧទ្ទេស ធ្វើការស្រាវជ្រាវបន្ថែមលើអ្វីដែលខ្លួនបានរៀននៅក្នុងថ្នាក់។ តែនេះក៏នៅតែជាឧបសគ្គដល់គរុនិស្សិតដែលសមត្ថភាពភាសាអង់គ្លេសរបស់គាត់នៅមានកម្រិតដោយផ្អែកលើទិន្នន័យមាន៦៥%នៃគរុនិស្សិតតែប៉ុណ្ណោះដែលមានចំណេះដឹងភាសាល្អ ដោយឡែកជិតពាក់កណ្តាលស្ថិតនៅក្នុងកម្រិតខ្សោយ និងខ្សោយខ្លាំង។ ដោយហេតុនេះការបន្ថែមឯកសារជាភាសាបរទេស ឬជំរុញការស្រាវជ្រាវតាមអនឡាញ គឺជាវិធីមួយដែលមានប្រសិទ្ធភាពសម្រាប់តែគរុនិស្សិតបានមួយក្រុមតែប៉ុណ្ណោះ។ ដូចនេះ វិទ្យាស្ថានគរុកោសល្យអាចស្វែងរកឯកសារ និងផលិតឯកសារជាភាសាខ្មែរបន្ថែមទៀត ដើម្បីជួយសម្រួលដល់ក្រុមគរុនិស្សិតដែលមានកម្រិតភាសាបរទេសនៅទាប។ ស្របជាមួយគ្នានេះ បន្តផ្តល់កម្មវិធីបណ្តុះបណ្តាលភាសាបរទេសដល់គរុនិស្សិតដើម្បីអាចឱ្យគាត់ក្រោយពេលបញ្ចប់ការសិក្សាទទួលចំណេះដឹងផ្នែកភាសាបរទេសបន្ថែមទៀត ដែលជាយានឱ្យពួកគាត់បន្តការសិក្សានៅកម្រិតខ្ពស់ទៀត។ ចំណុចគួរឱ្យយកចិត្តទុកដាក់មួយទៀតគឺ ការទំនាក់ទំនងរវាងគរុនិស្សិត និងគ្រូឧទ្ទេសនៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងការតាមដានកិច្ចការស្រាវជ្រាវឬកិច្ចការដែលគ្រូបានដាក់ឱ្យ។ ដែលមានគរុនិស្សិត៨នាក់ស្នើសុំឱ្យមានការយកចិត្តទុកដាក់ដល់ការសិក្សារបស់សិស្ស*“...និងឧស្សាហ៍តាមដានសកម្មភាពសិក្សារបស់សិស្សទ្វេដង ដើម្បីជួយពួកគាត់ឈានទៅគោលដៅឆាប់រហ័ស”*។ ការស្នើសុំនេះ ក៏អាចពាក់ព័ន្ធទៅនឹងការរៀបចំបំណែងចែកកាលវិភាគសិក្សាផងដែរ ក្នុងការបែងចែកពេលវេលាឱ្យគរុនិស្សិតបានកាន់តែប្រសើរជាងមុន។

ការវាយតម្លៃលើការបង្រៀននិងរៀនជាកត្តាសំខាន់ដើម្បីឱ្យប្រាដកថាការអនុវត្តកម្មវិធីសិក្សាទទួលបានប្រសិទ្ធភាពខ្ពស់។ ដូចគ្នានេះដែរ វិទ្យាស្ថានគរុកោសល្យរាជធានី បានរៀបចំប្រព័ន្ធនៃការវាយតម្លៃលើការបង្រៀនរបស់គ្រូឧទ្ទេស និងការរៀនរបស់គរុនិស្សិត យ៉ាងហ្មត់ចត់។ ការិយាល័យធានាគុណភាពផ្ទៃក្នុង នៃវិទ្យាស្ថានបានបង្កើតឡើងដើម្បី វិភាគ និងតាមដានដំណើរការនៃការវាយតម្លៃផ្ទៃក្នុងជាប្រចាំក្នុងវិទ្យាស្ថានទាំងមូល។ បន្ថែមពីនេះទៀតការិយាល័យធានាគុណភាពផ្ទៃក្នុង មានតួនាទីសហការ និងផ្តល់ការណែនាំដល់ការិយាល័យ និងដេប៉ាតឺម៉ង់ផ្សេងៗ សម្រាប់ធ្វើការស្វ័យវាយតម្លៃផ្ទៃក្នុងតាមដេប៉ាតឺម៉ង់នីមួយៗ។ ឧបករណ៍វង្វាយតម្លៃជាច្រើនត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់។ ប៉ុន្តែការអនុវត្តនៃប្រព័ន្ធវាយតម្លៃនេះ នៅមានកម្រិតនៅឡើយ ដោយសារតែរយៈពេលអនុវត្តកន្លងមកមិនទាន់បានធ្វើការវាយតម្លៃដោយផ្ទាល់នៅឡើយទេ គឺគ្រាន់តែធ្វើតាមរយៈការស្ទង់មតិដោយប្រើប្រាស់ទម្រង់វាយតម្លៃតាម (Google Form)តែប៉ុណ្ណោះ សម្រាប់ការចុះធ្វើការវាយតម្លៃដោយផ្ទាល់តាមរយៈចុះពិនិត្យជាក់ស្តែងតាមការបង្រៀននិងរៀនមិនទាន់បានអនុវត្តនៅឡើយទេ។

## ៤.២ ការពិភាក្សានៅលើលទ្ធផលរបស់អ្នកឆ្លើយតប

សរុបជារួម តាមការស្រង់មតិទៅលើចំណាប់អារម្មណ៍ក្នុងការបន្តការសិក្សា ទៅតាមក្រុមអ្នកឆ្លើយតបបានបង្ហាញថាចំនួន១២.២៨%(១៤នាក់) និងចំនួន៨១.៥៨%(៩៣នាក់) មានបំណងចង់បន្តការសិក្សា មិនថានៅក្នុងស្រុកនិងក្រៅប្រទេស។ ដោយឡែក មានអ្នកឆ្លើយតបជាគណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស និងគរុនិស្សិត តែ ៦.១៤%(៧នាក់) ប៉ុណ្ណោះ ដែលយល់ឃើញថា ពិបាកឬពុំសូវមានចំណាប់ចង់បន្តការសិក្សា និងអភិវឌ្ឍសមត្ថភាពបន្ថែមទៀត។ ការប្តេជ្ញាចិត្ត និងឆន្ទះរបស់គ្រូឧទ្ទេសក្នុងការបន្តការអភិវឌ្ឍសមត្ថភាព នេះជាសញ្ញាណដ៏វិជ្ជមានសម្រាប់ការកែលម្អគុណភាពគ្រូបង្រៀន និងគុណភាពនៃការបង្រៀនរបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនាពេលអនាគត និងឆ្លើយតបនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាដែលនឹងកំពុងអនុវត្តទូទាំងប្រទេស។

សរុបជារួម ទៅលើការអនុវត្តកម្មវិធីសិក្សាថ្មីនេះ គ្រប់អ្នកចូលរួមឆ្លើយតប គឺពេញចិត្តទៅលើការអនុវត្តកម្មវិធីសិក្សា ដោយសារកម្មវិធីនេះបានកំណត់នូវព័ត៌មានលម្អិតដែលចាំបាច់សម្រាប់គ្រូឧទ្ទេស ដូចជា បានកំណត់នូវវត្ថុបំណងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ហើយជាពិសេសផ្តល់នូវភាពបត់បែនទៅតាមលទ្ធភាពជាក់ស្តែងនៅក្នុងម៉ោងសិក្សានីមួយៗ និងតាមឯកទេស ដែលខុសពីកម្មវិធីសិក្សាចាស់(១២+២)។ តួយ៉ាង អ្នកឆ្លើយតបមួយចំនួនបានបង្ហាញថា *"មានបំណែងចែកកម្មវិធី មានខ្លឹមសារ និងលំហូរក្នុងការបង្រៀនល្អ"* ។ បន្ថែមពីនេះទៀតក៏មានអ្នកឆ្លើយតបភាគច្រើនបង្ហាញថា *"..ការបង្រៀនតាមប្រព័ន្ធក្រេឌីតនេះ គ្រូអាចជ្រើសរើសម៉ោងបង្រៀនមួយសប្តាហ៍ ពីរ បី ឬក៏បួនម៉ោង ទៅតាមម៉ោងទំនេររបស់សិស្ស ហើយងាយចប់តាមក្រេឌីត"*។

លក្ខណៈពិសេសមួយទៀតដែលគ្រូឧទ្ទេសពេញចិត្តទៅនឹងកម្មវិធីសិក្សានេះគឺ ដោយសារកម្មវិធីសិក្សាថ្មីនេះបានផ្តល់នូវព័ត៌មានលម្អិតដូចជាការកំណត់ម៉ោងប្រតិបត្តិ ពិសោធន៍ និងស្រាវជ្រាវ ដែលខុសពីកម្មវិធីសិក្សាដែលផ្អែកលើកម្មវិធីសិក្សាគោល ផ្តល់ភាពងាយស្រួលដល់គ្រូងាយនឹងអាចយកទៅរៀបចំផែនការបង្រៀន និងកិច្ចតែងការ។ ដូចបានលើឡើងដោយក្រុមគ្រូឧទ្ទេស ថា *"មេរៀនមានវិសាលភាពធំ ធ្វើឱ្យគរុនិស្សិតសកម្មក្នុងការរៀនសូត្រ ហើយពួកគាត់មានកិច្ចការធ្វើជាប្រចាំ"*។ សកម្មភាពនេះ ជួយពង្រឹងសមត្ថភាពនិងជំនាញស្រាវជ្រាវរបស់គ្រូឧទ្ទេសបន្ថែមទៀត ។ គរុនិស្សិត ៩៩% ពេញចិត្តទៅនឹងកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ដូចនឹងការពេញចិត្តរបស់គ្រូឧទ្ទេសដែរ។ ហេតុផលសំខាន់ៗដែលក្រុមគរុនិស្សិតបានបង្ហាញពីការពេញចិត្តគឺពាក់ព័ន្ធនឹងផ្តល់ចំណេះដឹងឯកទេស វិធីសាស្ត្របង្រៀន ការងារស្រាវជ្រាវ និងជំនាញទន់ (ចិត្ត-គរុកោសល្យ..) រួមទាំងបច្ចេកវិទ្យានិងភាសាផងដែរ។ ដែលស្របនឹងការលើកឡើង ជំនាញនៃការឆ្លុះបញ្ចាំងជំនាញគរុកោសល្យ ជំនាញនៃការគ្រប់គ្រងមនុស្ស និងគ្រប់គ្រងរដ្ឋបាល និងជំនាញនៃការទំនាក់ទំនង និងសម្របសម្រួលរួមទាំងជំនាញបច្ចេកវិទ្យា និងនវានុវត្តន៍ (Ministry of Education Singapore, 2012)។

*"..មានការស្រាវជ្រាវលើមុខវិជ្ជាឯកទេសច្រើន និងមានចំណេះដឹងខាងកុំព្យូទ័រ"*

*"ខ្ញុំជឿជាក់ថាបន្ទាប់ពីបញ្ចប់ការសិក្សានៅទីនេះ នឹងអាចធ្វើឱ្យវិជ្ជាជីវៈរបស់ខ្ញុំមានភាពប្រសើរឡើង ព្រោះខ្ញុំទទួលបានការបណ្តុះបណ្តាលផ្នែកគរុកោសល្យនិងចិត្តវិទ្យាតាំងពីឆ្នាំទី១ព្រមទាំងវិធីសាស្ត្របង្រៀនគណិតវិទ្យា... ខ្ញុំមើលឃើញថាខ្លួនឯងកាន់តែមានភាពប្រសើរឡើង"* ។

*"ជំនាញផ្ទាល់ខ្លួនដែលខ្ញុំទទួលបានពីការសិក្សា និងអនុវត្តកម្មវិធីសិក្សា ១២+៤ ដែលបានសិក្សា៖ ការស្រាវជ្រាវ មានភាពម្ចាស់ការ ការសហការជាក្រុម ជំនាញសរសេរកម្មវិធីគណិតវិទ្យានិងសៀវភៅ.."*

*"ចំណុចដែលបានអភិវឌ្ឍន៍បន្ថែមក្នុងឯកទេសរបស់ខ្ញុំគឺការធ្វើពិសោធ សិក្សាពីសម្ភារៈឧបទេស ការសិក្សាភាសាអង់គ្លេសជាដើម.."*។

ទន្ទឹមនឹងនោះ វិធីសាស្ត្របង្រៀនត្រូវបានយកចិត្តទុកយ៉ាងខ្លាំងនៅវិទ្យាស្ថានគរុកោសល្យ ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាពខ្ពស់ ។ នៅក្នុងនេះ តាមរយៈកម្រងសំណួរស្រាវជ្រាវបានបង្ហាញថា គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ ប្រើប្រាស់វិធីសាស្ត្រដែលមានភាពសម្បូរបែប និងបានដាក់បញ្ចូលនូវវិធីសាស្ត្រថ្មីៗជាច្រើន ដូចជា៖ វិធីបង្រៀនតាមបែបរិះរក គម្រោងស្រាវជ្រាវ របៀបគ្រប់គ្រងថ្នាក់រៀន ការដាក់វិន័យបែបវិជ្ជមាន ពិសោធន៍ និងការអនុវត្តជាក់ស្តែង និងការធ្វើបទបង្ហាញ ។ល។ វិធីសាស្ត្របង្រៀនទាំងអស់នេះអាចជួយឱ្យគរុនិស្សិតទទួលបានចំណេះដឹង បំណិន និងជំនាញដែលបានកំណត់។ ដូចបានលើកឡើងរបស់គរុនិស្សិតថា *"..ដឹងរបៀបពិសោធន៍បានខ្លះ និងមានបំណិនក្នុងការស្រាវជ្រាវមេរៀន.."* និង *"យល់មេរៀនបានច្បាស់ជាងមុន និងយល់ដឹងពីចំណេះដឹងថ្មីៗដែលមិនធ្លាប់ជួប"* ។ ស្របជាមួយគ្នានឹងការបង្កើនចំណេះដឹងនិងជំនាញ ការបណ្តុះបណ្តាលតាមកម្មវិធីសិក្សាថ្មី ក៏ចូលរួមបង្កើននូវជំនាញទន់ ដែលចាំបាច់សម្រាប់គរុនិស្សិតនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ ដូចជា ការធ្វើការរួមគ្នា ការជឿជាក់លើខ្លួន

ឯង ការដោះស្រាយបញ្ហា ជាដើម។ ហើយនេះជាគោលបំណងមួយនៃកម្មវិធីការបណ្ដុះបណ្ដាលគ្រូនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

*"ខ្ញុំមានភាពជឿជាក់លើសមត្ថភាពខ្លួនឯងជាងមុន"*

ទន្ទឹមនឹងការរីកចម្រើនមួយចំនួនរបស់គរុនិស្សិត គ្រូឧទ្ទេសក៏បានចូលរួមក្នុងដំណើរការនៃរៀនសូត្រចេញពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត (Learning by doing) នេះផងដែរ។ ក្នុងនោះគ្រូឧទ្ទេសបានបង្ហាញពីការរីកចម្រើនពាក់ព័ន្ធទៅនឹងចំណេះដឹង (លើឯកទេស) ជំនាញស្រាវជ្រាវ និងវិធីសាស្ត្រផងដែរ។ ភាគច្រើនអ្នកឆ្លើយតបបានបង្ហាញពីការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន ដែលទទួលបានពីការអនុវត្តកម្មវិធីដូចជា៖ *"គ្រប់គ្រងការបង្រៀនតាមប្រព័ន្ធក្រេឌីត, ប្រើប្រាស់ ICT, Mentoring, STEM, Statistic, ការសិក្សាស្រាវជ្រាវមេរៀន(LS), ការសិក្សាស្រាវជ្រាវវិធីសាស្ត្របង្រៀន(Action research)"* ។

ដោយសារកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះថ្មីសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត ធ្វើឱ្យក្លាយជាបញ្ហាប្រឈមរបស់ពួកគាត់។ ដោយហេតុនេះ គឺទាមទារនូវពេលវេលាច្រើនសម្រាប់ការសិក្សាស្វែងយល់ពីសំណាក់គ្រូឧទ្ទេសខ្លួនឯងផ្ទាល់ គួបផ្សំនឹងការចំណាយពេលវេលា ដើម្បីធ្វើការស្រាវជ្រាវមេរៀន និងរៀបចំសម្ភារៈឧបទេសសម្រាប់បង្រៀនដូចនេះ គ្រូឧទ្ទេសធ្វើការងារច្រើនជាងមុន ។ បន្ថែមនឹងការស្រាវជ្រាវមេរៀន និងរៀបចំកិច្ចតែងការបង្រៀន គ្រូឧទ្ទេសក៏មានបន្ទុកលើពេលវេលាច្រើន ត្រូវត្រួតពិនិត្យលើការងាររបស់គរុនិស្សិត។ អ្នកឆ្លើយតបជាគ្រូឧទ្ទេស បង្ហាញពីការយល់ឃើញទៅលើការអនុវត្តកម្មវិធីសិក្សាថ្មីនេះគឺជួបប្រទះនឹងការពិបាកច្រើនដូចជា៖"..*ពិបាកក្នុងការគ្រប់គ្រងម៉ោងសិស្សរៀនបន្ថែម ចំណាយពេលច្រើនជាងមុនក្នុងការពិនិត្យ និងកែកិច្ចការបន្ថែមតាមសប្ដាហ៍ និងកិច្ចការស្រាវជ្រាវរបស់គរុនិស្សិតតាមឆមាស គ្រូធ្វើកិច្ចការច្រើនជាងមុន"* ។ បញ្ហានេះ គឺដូចគ្នានឹងបញ្ហាប្រឈមរបស់គរុនិស្សិតជួបប្រទះ ទៅនឹងភាព

ថ្មីនៃកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន "*...មិនទាន់ស៊ាំជាមួយវិធីសាស្ត្របង្រៀននិងកិច្ចការស្រាវជ្រាវច្រើន ព្រមទាំងការធ្វើបទបង្ហាញ*" ។

កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត ពិតជាធ្វើឡើងសមស្របទៅនឹងចំណេះដឹង និងសមត្ថភាពរបស់គរុនិស្សិត ដែលធ្វើឱ្យគរុនិស្សិតអាចទទួលបាននូវចំណេះដឹង បំណិន និងជំនាញដែលបានកំណត់ក្នុងវត្ថុបំណងនៃកម្មវិធីសិក្សា។ មានអ្នកឆ្លើយតបខ្លះ បានបញ្ជាក់ថា "*...គរុនិស្សិតចាប់បានវត្ថុបំណងមេរៀនបានល្អ តាមការវាយតម្លៃបង្ហាញថាគរុនិស្សិតទទួលបានលទ្ធផលល្អក្នុងការសិក្សា*"។ នេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្មវិធីសិក្សារបស់វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងទទួលបានលទ្ធផលល្អប្រសើរ។ ដោយឡែក កម្មវិធីសិក្សានេះ អភិវឌ្ឍន៍ឡើងដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា សកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា វិទ្យាស្ថានជាតិអប់រំ គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានគរុកោសល្យភ្នំពេញនិងបាត់ដំបង ព្រមទាំងអង្គការដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិមួយចំនួន(JICA, UNESCO, UNICEF, VVOB, NRC, JHP, KIZUNA, NIPON FOUNDATION) ។ ដែលស្របនឹង ការអះអាងរបស់លោក Martens, Lueckenhausen និង Mc Cormack (2004) ដែលថា កម្មវិធីសិក្សាដែលល្អចាំបាច់ត្រូវមានជាតុចូលពីអ្នកពាក់ព័ន្ធ។ បន្ថែមពីនេះកម្មវិធីសិក្សាផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ ដោយកម្មវិធីនេះបានសរសេរពីព័ត៌មានច្បាស់លាស់និងចាំបាច់សម្រាប់គ្រូឧទ្ទេសយកទៅអនុវត្តក្នុងការរៀបចំផែនការបង្រៀន។ ស្របជាមួយនឹងការលើកឡើងរបស់អ្នកឆ្លើយតបភាគច្រើន ថា "*...ងាយស្រួលក្នុងការរៀបចំផែនការបង្រៀន ដោយសារក្នុងកម្មវិធីសិក្សាថ្មី បានកំណត់ វត្ថុបំណង និងសំណួរគន្លឹះតាមម៉ោងនីមួយៗ .....ជាពិសេសមាន ផ្តល់ឯកសារយោងក្នុងកម្មវិធីសិក្សា អាចទៅរកមេរៀនបានងាយស្រួល*" ។

*"..ការស្វ័យសិក្សាដោយខ្លួនឯង ការសិក្សាមានភាពទូលំទូលាយ ការរៀនមានភាពឿនលឿនមាន បច្ចេកវិទ្យា មានសម្ភារៈច្រើន និង ពង្រីកចំណេះដឹងថ្មីៗ ភាសាបរទេសនិងបច្ចេកវិទ្យា" ។*

# ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

និក្ខេបបទនេះផ្តោតសំខាន់លើប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីសិក្សាថ្មី សម្រាប់បណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីត និងបញ្ហាប្រឈមនានា នៅក្នុងការបង្រៀននិងរៀនដែលវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ ទាំងទិន្នន័យមានស្រាប់ និងទិន្នន័យបឋមត្រូវបានប្រើក្នុងនិក្ខេបបទនេះ។ ទិន្នន័យត្រូវបានវិភាគយ៉ាងប្រុងប្រយ័ត្ន សម្រាប់ជាប្រយោជន៍នៃភាពត្រឹមត្រូវនៃនិក្ខេបបទនេះ។ វត្ថុបំណងសំខាន់នៃនិក្ខេបបទនេះគឺដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សាថ្មី១២+៤ និងកំណត់អំពីបញ្ហាប្រឈមដែលគ្រូឧទ្ទេស និងគរុនិស្សិតកំពុងបង្រៀននិងរៀននៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។ តាមរយៈលទ្ធផលដែលបានបង្ហាញក្នុងការសិក្សាស្រាវនេះ ចំពោះបញ្ហាប្រឈមទាំងនោះត្រូវបានដោះស្រាយដោយផ្អែកលើទស្សនៈរបស់គណៈគ្រប់គ្រង ប្រធាន/អនុប្រធាន គ្រូឧទ្ទេស គរុនិស្សិត ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀននិងរៀននៅវិទ្យាស្ថានទាំងមូល ។

## ៥ ១.សន្និដ្ឋាន

### ក. ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

តាមរយៈការស្រង់មតិពីក្រុមអ្នកឆ្លើយតប បង្ហាញថាលើសពី៩០% នៃក្រុមអ្នកឆ្លើយតបទាំងអស់ បង្ហាញពីការពេញចិត្ត និងវាយតម្លៃថា កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះ សមស្របនឹងសមត្ថភាពសិស្ស។ ជាងនេះទៅទៀត កម្មវិធីសិក្សាថ្មីនេះ បានកំណត់នូវវត្ថុបំណងច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ជាពិសេស ផ្តល់នូវភាពបត់បែនសម្រាប់គ្រូឧទ្ទេស និងគរុនិស្សិត បត់បែនម៉ោងសិក្សាទៅតាមលទ្ធភាពជាក់ស្តែង ដែលខុសពីកម្មវិធីសិក្សាតាមប្រព័ន្ធចាស់ (១២+២) ។ លើសពីនេះ កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះ បានបណ្តុះឱ្យគរុនិស្សិតទទួលបានចំណេះដឹងនិងជំនាញចាំបាច់ ដូចជាភាពជឿជាក់ ការសហការ និងការដោះស្រាយបញ្ហាជាដើម។ ជំនាញទន់ទាំងនេះគឺចាំបាច់និងមានសារៈសំខាន់ណាស់ដល់គរុនិស្សិតក្នុងជីវិតប្រចាំថ្ងៃ ដែលទាំងនេះជា

គោលបំណងមួយនៃកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីត ហើយក៏ជាចំណុចពិសេសខុសប្លែកពីកម្មវិធីសិក្សាពីមុនផងដែរ។ ទន្ទឹមនឹងការរីកចម្រើនមួយចំនួនរបស់គរុនិស្សិត កម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត នេះបានផ្តល់ឱកាសគ្រូឧទ្ទេស បង្កើននូវចំណេះដឹង វិធីសាស្ត្របង្រៀនថ្មីៗ របៀបរៀបចំកម្មវិធីសិក្សា និងជំនាញស្រាវជ្រាវជាដើម។ ដោយឡែកនៅក្នុងការអនុវត្តកម្មវិធីសិក្សានេះ ក៏ជួបនូវបញ្ហាប្រឈមមួយចំនួនទាំងគ្រូឧទ្ទេស និងគរុនិស្សិតផងដែរ។

## ខ. បញ្ហាប្រឈមនៅក្នុងការអនុវត្តកម្មវិធីសិក្សារបស់ក្រុមគ្រូឧទ្ទេស និងគរុនិស្សិត

តាមទស្សនៈរបស់គ្រូឧទ្ទេស ប្រធាន/អនុប្រធាន បញ្ហាប្រឈមដែលគ្រូឧទ្ទេសកំពុងជួបប្រទះក្នុងការបង្រៀននៅវិទ្យាស្ថានគរុកោសល្យរាជធានី ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការបង្រៀននិងរៀន រួមមាន កម្មវិធីសិក្សាមួយចំនួននៅមិនទាន់សមរម្យ ខ្លឹមសារនិងវិធីសាស្ត្របង្រៀននៅមានកម្រិត ចំណាយពេលវេលាច្រើន កង្វះខាតសម្ភារៈឧបទេស និងឯកសារបង្រៀនជាភាសាខ្មែរ ជាដើម។ ដោយសារកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីតនេះថ្មីសម្រាប់គ្រូឧទ្ទេសធ្វើឱ្យវាក្លាយជាបញ្ហាប្រឈមរបស់ក្រុមគ្រូឧទ្ទេសក៏ដូចជាគរុនិស្សិតផងដែរ។ ដោយសារកម្មវិធីថ្មី តម្រូវពេលវេលាច្រើនសម្រាប់រៀបចំឯកសារ ខ្លឹមសារមេរៀន និងសម្ភារបង្រៀន និងចងក្រងឯកសារបង្រៀន ទាំងអស់នេះគឺជាការចាំបាច់ដែលគ្រូឧទ្ទេសត្រូវធ្វើ។ ប៉ុន្តែបញ្ហានេះ នឹងដោះស្រាយនៅឆ្នាំបន្តបន្ទាប់។ ដោយហេតុនេះ ក្នុងពេលបច្ចុប្បន្ន គ្រូឧទ្ទេសត្រូវចេះគ្រប់គ្រង និងចាត់ចែងពេលវេលាឱ្យបានល្អនិងម៉ត់ចត់ ។ ទាំងនេះ ទាមទារនូវការប្តេជ្ញាចិត្ត និងឆន្ទៈរបស់គ្រូឧទ្ទេសក្នុងការអនុវត្តការងារផងដែរ។ ទាក់ទងនឹងបណ្ណាល័យ និងមន្ទីរពិសោធន៍ដែលកំពុងដំណើរការនៅវិទ្យាស្ថានបច្ចុប្បន្នពុំមានស្តង់ដារ ហើយនេះជាមូលហេតុចម្បងមួយដល់គុណភាពនៃការបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានផ្ទាល់។ បណ្ណាល័យដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឱ្យគរុនិស្សិតនូវការស្រាវជ្រាវបន្ថែមលើការងាររបស់ពួកគេ ក៏ដូចជា ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេលើមុខជំនាញឬមុខវិជ្ជាផ្សេងៗទៀត។ ក្នុងន័យស្រដៀងគ្នា មន្ទីរពិសោធន៍ពិតជាចាំបាច់ណាស់សម្រាប់គរុនិស្សិត ជាពិសេសថ្នាក់វិទ្យាសាស្ត្រ ដែលការពិសោធន៍ត្រូវធ្វើឡើងដើម្បីឱ្យគរុនិស្សិតមាន

ភាពស្ទាត់ជំនាញ និងផ្សារភ្ជាប់ទ្រឹស្តីក្នុងសៀវភៅ ទៅនឹងការអនុវត្តន៍ជាក់ស្តែង។ ចំណុចគួរឱ្យកត់សម្គាល់មួយទៀតដែលរកឃើញក្នុងក្រុមគ្រូឧទ្ទេស គឺពេលវេលាដែលកំណត់សម្រាប់បង្រៀននិងខ្លឹមសារមេរៀនដែលត្រូវបង្រៀន សម្រាប់មេរៀនមួយចំនួនមិនសមស្រប ទៅតាមឯកទេសមួយចំនួន។ ហើយចំណុចនេះដូចគ្នានឹងការលើកឡើងដោយក្រុមអ្នកឆ្លើយតបនៃគណៈគ្រប់គ្រងរបស់វិទ្យាស្ថានផងដែរ។ ដូចនេះវិទ្យាស្ថានត្រូវធ្វើការការត្រួតពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងដាក់ជាផែនការអទិភាព។ ស្រដៀងគ្នានឹងបញ្ហាប្រឈមរបស់គ្រូឧទ្ទេសដែរ ក្រុមគរុនិស្សិតក៏បានជួបប្រទះនឹងការលំបាកមួយ ចំនួនផងដែរ ដូចជា ភាពថ្មីរបស់កម្មវិធីសិក្សា និងវិធីសាស្ត្រ សម្ភារៈសិក្សា ការគាំទ្រពីគ្រូ ការគ្រប់គ្រងពេលវេលា កម្រិតភាសាអង់គ្លេស និងឯកសារជាភាសាខ្មែរ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺកង្វះការគាំទ្រពីគ្រូនិងសាលា និងការបែងចែកពេលវេលាសិក្សាមិនសូវមានប្រសិទ្ធភាព។ ទំនាក់ទំនងរវាងគ្រូឧទ្ទេសនិងគរុនិស្សិត ជាផ្នែកដ៏សំខាន់និងចាំបាច់ សម្រាប់ការបង្រៀន ព្រោះជួយឱ្យគរុនិស្សិតជំនះនូវការលំបាក និងអាចស្វែងយល់ពីចំណេះដឹងថ្មីកាន់តែឆាប់និងមានប្រសិទ្ធភាព ជាពិសេសជួយពង្រឹងទំនុកចិត្តនិងកាត់បន្ថយភាពភ័យខ្លាចព្រួយបារម្ភរបស់គរុនិស្សិត។

## ៥ ២.សំណូមពរ

ការរកឃើញពីការសិក្សានេះដើរតួនាទីយ៉ាងសំខាន់ ហើយអាចអនុវត្តបានមិនត្រឹមតែនៅក្នុងវិទ្យាស្ថានគរុកោសល្យរាជធានីប៉ុណ្ណោះទេ ប៉ុន្តែក៏មានវិទ្យាស្ថាននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូផ្សេងៗផងដែរ។ បន្ថែមពីការរកឃើញដែលបានលើកឡើងខាងលើ ការផ្តល់យោបល់និងសំណូមពរដើម្បីដោះស្រាយបញ្ហាទាំងនោះបានលើកឡើងទៅតាមផ្នែក។

## ក. វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

**ទី(១)** គ្រូគួរតែមានភាពបត់បែនក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗគ្នា ក្នុងពេលបង្រៀនដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្ស។ បើមិនដូច្នោះទេគោលបំណងនៃការបង្រៀនមិនអាចសំរេចបានឡើយ។ នេះទាមទារឱ្យគ្រូមានការលើកទឹកចិត្ត និងឆន្ទៈក្នុងការអនុវត្តការងារ។

**ទី(២)** កម្មវិធីសិក្សាគួរតែត្រូវបានរៀបចំឡើងឆ្លើយតបនឹងតម្រូវការជាក់ស្តែង ស្របតាមស្តង់ដារជាតិ និងអន្តរជាតិ។ ដើម្បីសម្រេចគោលដៅនេះ វិទ្យាស្ថាន ក៏ដូចជាស្ថាប័នអប់រំគ្រូផ្សេងទៀត គួរមានអ្នកអភិវឌ្ឍន៍កម្មវិធីសិក្សាជំនាញដើម្បីត្រួតពិនិត្យនិងធ្វើអធិការកិច្ចជាទៀងទាត់លើកម្មវិធីសិក្សាដែលបានអនុវត្តនៅក្នុងស្ថាប័ន។ ដូច្នេះ នៅពេលដែលរកឃើញថា ការអនុវត្តគ្មានប្រសិទ្ធភាពកើតមានឡើង ការត្រួតពិនិត្យនិងកំណែទម្រង់កម្មវិធីសិក្សាត្រូវធ្វើឡើងភ្លាមៗ។

**ទី(៣)** ដើម្បីធ្វើឱ្យប្រសើរឡើងនូវការបង្រៀននិងការរៀន ការលើកកម្ពស់កម្រិតស្តង់ដារបណ្ណាល័យដោយបំពាក់ឧបករណ៍ទំនើប សៀវភៅ ឯកសារថ្មីៗទាំងភាសាជាតិនិងភាសាបរទេសនិងភ្ជាប់បណ្តាញអ៊ីនធឺណែតដើម្បីជួយសម្រួលដល់ការសិក្សានិងការស្រាវជ្រាវរបស់គរុនិស្សិតក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង និងជំនាញស្រាវជ្រាវរបស់ពួកគេ។ លើសពីនេះទៀតថ្នាក់រៀន និងបន្ទប់ពិសោធន៍ និងមន្ទីរពិសោធន៍មិនអាចប្រងើយកន្តើយឡើយ បើវិទ្យាស្ថានមានបំណងចង់ទទួលបានគុណភាពនៃការបង្រៀននិងការរៀន។

**ទី(៤)** វិន័យ និងបទបញ្ជាក្នុងថ្នាក់រៀនត្រូវរឹតបន្តឹង និងអនុវត្តឱ្យបានខ្ជាប់ខ្ជួន ដោយសារការបណ្តុះបណ្តាលនៅវិទ្យាស្ថានមិនត្រឹមតែពង្រឹងចំណេះដឹង និងជំនាញ ឥរិយាបថនោះទេ គឺថែមទាំងពង្រឹងលើសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនផងដែរ។ ការពង្រឹងវិន័យឬបទបញ្ជាក្នុងថ្នាក់ ដើម្បីឱ្យគរុនិស្សិតមានទម្លាប់ល្អ និងជាផ្នែកមួយជម្រុញឱ្យគរុនិស្សិតចូលរួមយ៉ាងពេញលេញក្នុងការរៀនសូត្រ និងស៊ីជម្រៅក្នុងសកម្មភាពថ្នាក់រៀនដែលកំណត់ដោយគ្រូ។

**ទី(៥)** ទាក់ទងនឹងកង្វះខាតគ្រូបង្រៀននៅវិទ្យាស្ថានក្នុងដំណាក់បច្ចុប្បន្ន។ វិទ្យាស្ថាន គួររៀបចំផែនការប្រចាំឆ្នាំដោយពិនិត្យមើលជាមុននូវចំនួនគ្រូនៃមុខវិជ្ជានីមួយៗ ដែលត្រូវការហើយធ្វើការស្នើសុំជាផ្លូវការទៅកាន់ក្រសួង អប់រំយុវជន និងកីឡា។ ដូច្នេះបញ្ហាអាចត្រូវបានដោះស្រាយ ហើយការបង្រៀន និងការរៀនត្រូវបានជានាផងដែរ។

**ទី(៦)** ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងពេលវេលាសិក្សារបស់គរុនិស្សិត ការបែងចែកកាលវិភាគសិក្សាគួររៀបចំពិនិត្យឡើងវិញ ដើម្បីរៀបចំឱ្យគរុនិស្សិតមានម៉ោងសិក្សាស្រាវជ្រាវច្រើនជាងមុន ដោយសារ កាលវិភាគកម្មវិធីសិក្សាបច្ចុប្បន្ន ការសិក្សាធ្វើឡើងពីរពេលដោយទុកម៉ោងចន្លោះសម្រាប់គរុនិស្សិតស្វ័យសិក្សានៅរវាងម៉ោងរៀន។ ដូចនេះធ្វើឱ្យគរុនិស្សិតមានពេលខ្លីសម្រាប់ចូលសិក្សាស្រាវជ្រាវ ធ្វើកិច្ចការក្រុម និងស្វ័យសិក្សា។ ដោយហេតុនេះ កាលវិភាគកម្មវិធីសិក្សា គួររៀបចំមួយពេលដាច់ និងទុកចំនួនពេលជាក់លាក់ណាមួយសម្រាប់ស្វ័យសិក្សានិងស្រាវជ្រាវ នៅក្នុង បណ្ណាល័យគួរត្រូវបានរៀបចំនឹងបំពាក់សម្ភារៈទំនើបៗ និងឯកសារទាក់ទាញចំណាប់អារម្មណ៍ត្រូវនឹងចំណង់ចំណូលចិត្តរបស់គរុនិស្សិតដែលទាំងអស់នេះជាកត្តាជះឥទ្ធិពលនាំឱ្យពួកគេចង់ចូលបណ្ណាល័យធ្វើការ ស្រាវជ្រាវជាប្រចាំ។

**ខ. គ្រឹះស្ថានបណ្ដុះបណ្ដាលក្រោយៗដែលនឹងក្លាយខ្លួនជាវិទ្យាស្ថានគរុកោសល្យគួរត្រៀមខ្លួនទៅលើចំណុចមួយចំនួនដូចជា៖**

១. សិក្សាលើធនធានមនុស្ស

- ស្វែងយល់ពីសមត្ថភាពនិងស្ថានភាពបច្ចុប្បន្នរបស់គ្រូឧទ្ទេស បុគ្គលិកអប់រំ
- ពង្រឹងសមត្ថភាពគ្រូដែលមានស្រាប់ និងជ្រើសរើសគ្រូថ្មីបន្ថែមបើចាំបាច់

២. សិក្សាលើរចនាសម្ព័ន្ធ និងការគ្រប់គ្រង

- ប្រព័ន្ធនៃការគ្រប់គ្រងនិងការលើកទឹកចិត្ត

- សមត្ថភាពគណៈគ្រប់គ្រង

**គ. ក្រសួងអប់រំ យុវជន និងកីឡា**

**ទី(៧)** ជំនាញបច្ចេកវិទ្យាព័ត៌មាន គួរតែត្រូវបានបំពាក់និងដាក់ឱ្យប្រើប្រាស់ចាប់តាំងពីបឋមសិក្សាឬយ៉ាងហោចណាស់នៅកម្រិតវិទ្យាល័យ ដើម្បីឱ្យពួកគេអាចមានចំណេះដឹងនិងជំនាញពេញលេញនៅពេលពួកគេឈានដល់កម្រិតមហាវិទ្យាល័យឬសាកលវិទ្យាល័យ។ ស្របគ្នានេះការបណ្តុះបណ្តាលទៅលើជំនាញបច្ចេកវិទ្យាព័ត៌មាននេះគួរធ្វើឡើងជាទៀងទាត់ដល់គ្រូនៅតាមសាលាតាមរយៈថវិកាសាលាឬក្រសួង។

# ឯកសារយោង


រាជរដ្ឋាភិបាលកម្ពុជា .(២០១៩) .*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩.២០២៣*- ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា.

ក្រសួងអប់រំយុវជននិងកីឡា.(២០១៨). *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន* រសួងអប់រំ ភ្នំពេញ: ក . យុវជន និងកីឡា.

នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រិតការ.(២០១៦). *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន*ភ្នំពេញ:ក្រសួង . អប់រំយុវជន និងកីឡា.

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ.(២០១៩). *សៀវភៅណែនាំកម្មវិធីគរុកោសល្យរាជធានីភ្នំពេញ* វិទ្យាគរុកោសល្យស្ថានរាជធានីភ្នំពេញ.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៨) .*ផែនការយុទ្ធសាស្ត្រវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ២០១៩-២០២៣.* រាជរដ្ឋាភិបាលកម្ពុជា.

វិទ្យាស្ថានគរុកោសល្យ .(២០១៧).*ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ.*រាជធានីភ្នំពេញ: វិទ្យាស្ថានគរុកោសល្យ .

វិទ្យាស្ថានគរុកោសល្យ .(២០១៨) .*ផែនការអនុវត្តកម្មវិធីអប់រំ*រាជធានីភ្នំពេញ: វិទ្យាស្ថាន . .គរុកោសល្យ

ឆាយ បូនី .(២០១៩) .*ស្ថានភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ*រាជធានី . ភ្នំពេញ: ឆាយ បូនី

ជា សោភារី និង ហ៊ុយ ស៊ីវន .(២០០៧)*ការវិវត្តប្រព័ន្ធអប់រំពីសាលាវត្តមកសាលាទំនើប*រាជធានី . .ភ្នំពេញ

យ៉ង ធី និងស៊ន សំណាង .(១៩៩៨) .*ប្រវត្តិនៃការអប់រំបឋមនិងមធ្យមសិក្សានៅកម្ពុជា*រាជធានី . .ភ្នំពេញ

Aithal, P., & Kumar, P. (2015). How innovations and best practices can transform higher education institutions: A case study of SIMS. *International Journal of Management (IJM), 6*(2), 83-98.

Aithal, P., & Kumar, P. (2016). Analysis of Choice Based Credit System in Higher Education. *International Journal of Engineering Research and Modern Education (IJERME) Volume I, Issue I*, 278-284.

Chealy, C. (2009). Higher Education in Cambodia. In Y. Hirosato, & Y. Kitamura (Eds.), *The Political Economy of Educational Reforms and Capacity Development in Southeast Asia: Cases of Cambodia, Laos and Vietnam*. Dordrecht, NL: Springer.

de Guzman, E.S. (2006). A strategy for institutional change through a collaborative action model for curricular reform: the case of the Philippine Normal University. In Michael, F., & Martina, P.B. (eds). *Prospect of change in higher education: Towards new qualities & relevance*. Festschrift for Matthias Wesseler. London: IKO—Verlag fur Interkulturelle Kommunikation.

Devlin, M. (2007a, August). *Improving teaching in tertiary education: Institutional and individual influences*. Keynote address at Excellence in Education and Training Conversation. Singapore Polytechnic: Singapore.

Doygun, O., & Gulec, S. (2012). Problems faced by university students and proposals for solution. Social and behavioral sciences (47), 1115-11123.

Elliott, J. (1991). A model of professionalism and its implications for teacher education. *British educational research journal, 17*(4), 309-318.

Fook, C.Y., & Sidlu, G.K. (2014). Investigating Learning Challenges faced by Students in Higher Education. *Social and Behavioral Sciences* 186, 604-612

Gizir, C. (2005). Reason, Strategy and Teaching Practice to Direct Students to Proper Nutrition-Teaching Research of Human Nutrition. *Journal of Guilin Collage*, 155-168.

Gopinathan, S., Ho, W. K., & Tan, J. (1999). Teacher education and teaching in Singapore: Recent trends. *Asia-Pacific Journal of Teacher Education and Development, 2*(1), 3-14.

Guiffrida, D. (2008). Preparing Rural Students for Large Colleges and Universities. *Journal of school counseling* (56), 189-2012.

Hanushek, E. A., & Wöֿʒmann, L. (2007). *The Role of Education Quality in Economic Growth*. Washington, D.C.: World Bank.

Hargreaves, A. (2000). Four ages of professionalism and professional learning. *Teachers and teaching, 6* (2), 151-182.

Havtiva, N., Barak, R., & Simhi, E. (2001). Exemplary university teachers: Knowledge and beliefs regarding effective teaching dimensions and strategies. *Journal of Higher Education*, 72 (6), 699-729.

Kember, D., Ma, R., & Mc Naught, C. (2006). *Excellent university teaching*. Hong Kong: The Chinese University Press.

Kember, D., & Mc Nautht, C. (2007). *Enhancing university teaching*. London and New York: Routledge.

Kiernan, B. (1991). The Nature of the Genocide in Cambodia (Kampuchea). *Social Education*, 55 (2), pp. 114-115.

Kreber, C. (2002). Teaching excellence, teaching expertise and the scholarship of teaching. *Innovative Higher Education*, 27 (1), 5-23.

Lawton, P.H., and La Porte A.M., (2013). Beyond Traditional Art Education: Transformative Life-Long Learning in Community-Based Settings with Older Adults. Studies in Art Education: *A Journal of Issues and Research* 54 (4), 310-320.

Lay, S., Lim, V., & Man, N. (2015). *Challenges of Higher Education for Rural Students in Urban Universities in Cambodia*. Retrieved from file:///C:/Users/HP/ Desktop/The_Challenges_of_Higher_Education.pdf

Majoni, C. (2014). Challenges facing University Education in Zimbabwe. Greener Journal of Education and Training Studies, 2 (1), pp. 20-24.

Marsh, H. W. (1994). Students´ Evaluation of Educational Quality (SEEQ). A multidimensional rating instruments of students´ perceptions of teaching effectiveness. Sydney: University of Western Sydney Self Research Center.

Marsh, H. W., & Roche, L. A. (1994). The use of students´ evaluations of university teaching to improve teaching effectiveness. Canberra: Australian Government Publishing Service.

Martens, E., Lueckenhausen, G., & McCormack, C. (2004). La Trobe University processes for assessment of the quality of teaching and learning. Unpublished Discussion Paper. Melbourne: La Trobe University.

Ministry of Education Singapore. (2012). International studies affirm Singapore students´ strengths in reading mathematics and science Retrieved from http://www.moe.gov.sg/media/press/2012/12/international-studies-affirm-s.php.

Penny, A.R. (2003). Changing the agenda for research into students´ view about university teaching: Four shortcomings of SRT research. Teaching in Higher Education, 8(3), 399-411.

Phin, C. (2014). Challenges of Cambodian teachers in contributing to human and social development: are they well-trained? International Journal of Social Science and Humanity, 4 (5), pp. 344-348.

Regel, O., & Mundial, B. (1992). *The academic credit system in higher education: Effectiveness and relevance in developing countries*: Education and Employment Division, Population and Human Resources Department.

Richard, J. & Renandya, W. (2002). Methodology in Language Teaching: Anthology of Current Practice. Cambridge: Cambridge University Press.

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ (ក) ៖ កម្រងសំណួរសម្រាប់គ្រូឧទ្ទេស

# កម្រងសំណួរក្នុងការប្រមូលទិន្នន័យ

# សម្រាប់គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

នាងខ្ញុំឈ្មោះ ទៀង ចាន់សុភាព ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "ប្រសិទ្ធភាព នៃការអនុវត្តកម្មវិធីសិក្សា១២+៤ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ" ។

កម្រងសំណួរនេះមានគោលបំណងដើម្បីស្វែងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងទស្សនៈយល់ឃើញរបស់គរុនិស្សិតដែលកំពុងសិក្សាក្នុងវិទ្យាស្ថានគរុកោសល្យទៅលើការកំណែទម្រង់កម្មវិធីសិក្សារបស់វិទ្យាស្ថាន។ ទិន្នន័យដែលប្រមូលបានពីលោក-លោកស្រី គឺសម្រាប់តែការសិក្សាស្រាវជ្រាវ ដូច្នេះ សូមលោក-លោកស្រីមេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែងដើម្បីឱ្យនាងខ្ញុំអាចមានទិន្នន័យ និងហេតុផលគ្រប់គ្រាន់ តាមបែបវិទ្យាសាស្ត្រដើម្បីទាញអំណះអំណាងយកមកសិក្សាបកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវទៅប្រធានបទខាងលើ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោក-លោកស្រីទាំងអស់ក្នុងការចំណាយពេលវេលាសម្រាប់ការបំពេញកម្រងសំណួរនេះ។

## ផ្នែកទី១៖ ព័ត៌មានទូទៅ

**ការណែនាំ៖** សូមលោក-លោកស្រិគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែង

តួនាទី៖ ......................................

ភេទ □ ប្រុស □ ស្រី

អាយុ □ ក្រោម ២០ឆ្នាំ □ ចន្លោះពី ២០ឆ្នាំ ទៅ ៣០ឆ្នាំ

□ ចន្លោះពី ៣០ឆ្នាំ ទៅ ៤០ឆ្នាំ □ ពី៤០ឆ្នាំឡើងទៅ

កម្រិតវប្បធម៌ ▫ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ▫ កម្រិតបរិញ្ញាបត្រ

▫ បរិញ្ញាបត្រជាន់ខ្ពស់ ▫ បណ្ឌិត ▫ ក្រោយបណ្ឌិត

មុខជំនាញឯកទេស៖ ......................................

បទពិសោធន៍បង្រៀន ▫ ចន្លោះពី ១ឆ្នាំ ដល់ ៥ ឆ្នាំ ▫ ចន្លោះពី ៦ ឆ្នាំ ដល់ ១០ ឆ្នាំ

▫ ចន្លោះពី ១១ ឆ្នាំ ដល់ ១៥ ឆ្នាំ ▫ លើសពី ១៥ ឆ្នាំ

ចំណេះដឹងភាសាបរទេស(ភាសាអង់គ្លេស) ▫ ល្អណាស់ ▫ ល្អ ▫ មធ្យម ▫ ខ្សោយ ▫ ខ្សោយណាស់

**ផ្នែកទី២៖** ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

**ការណែនាំ៖** សូមលោក-លោកស្រីគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមកម្រិតនៃការយល់ស្របរបស់លោក-លោកស្រី

១.តើលោក-លោកស្រីកម្មវិធីសិក្សា១២+៤ បានកំណត់វត្ថុបំណងទៅតាមឯកទេសនីមួយៗ ទៅនឹងការអនុវត្តម្មវិធីសិក្សា១២+៤កម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

២. តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ សមស្របទៅនឹងចំណេះដឹង សមត្ថភាពរបស់គ្រូឧទ្ទេស និងគរុនិស្សិតទៅនឹងកម្មវិធីសិក្សាកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

៣. តើលោក-លោកស្រីគិតថាឧទ្ទេសមានការយល់ដឹងចំពោះកម្មវិធីសិក្សាថ្មី និងបំណែងចែកកម្មវិធីសម្រាប់បង្រៀនបានកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

៤.តើលោក-លោកស្រីមានការយល់ដឹងអំពីទស្សនៈវិស័យលើការលើកម្ពស់គុណភាពបង្រៀននិងរៀនបានកម្រិតណា ?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

**ផ្នែកទី៣៖ ការអនុវត្តកម្មវិធីសិក្សា (ការបង្រៀន និងរៀននិងសម្ភារឧបទេស)**

**ការណែនាំ៖** សូមលោក-លោកស្រីគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមកម្រិតនៃការយល់ស្របរបស់លោក-លោកស្រី

៥.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ពីភាពងាយស្រួលក្នុងការផលិតសម្ភារៈឧបទេសបានកម្រិតណា ?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

៦.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា ១២+៤មានភាពងាយស្រួលក្នុងការរៀបចំសម្ភារៈសិក្សា និងកិច្ចតែងការបង្រៀនជាប្រចាំបានកម្រិតណា ?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

៧. តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា ១២+៤ មានភាពងាយស្រួលក្នុងការបង្រៀន និងរៀនបានកម្រិតណា ?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

៨.តើលោក-លោកស្រីគិតថាមានយល់ដឹងអំពីការបង្រៀនតាមរយៈការបង្កើតសម្ភារៈឧបទេសសិក្សាសំបូរបែបបានកម្រិតណា ?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

៩.តើលោក-លោកស្រីមានការយល់ដឹង នឹងអនុវត្តបច្ចេកទេសបំផុសគំនិតផ្សេងៗក្នុងការបង្រៀនបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១០.តើលោក-លោកស្រីយល់ដឹងក្នុងការប្រើវិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១១.តើលោក-លោកស្រីមានភាពជឿជាក់លើការបង្រៀនប្រកបដោយប្រសិទ្ធភាពបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១២.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១១២+៤ មានភាពសមស្របក្នុងការអនុវត្តជាក់ស្តែងបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៣.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤មានការឆ្លើយតបជាមួយនឹងតម្រូវការរបស់សិស្សបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៤.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤មានវិសាលភាពការបង្រៀនដោយផ្ទាល់និងដោយប្រយោលបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

**ផ្នែកទី៤៖ទិន្នន័យឆ្លើយតបទៅលើការអភិវឌ្ឍសមត្ថភាពបង្រៀននិងជំនាញវិជ្ជាជីវៈ**

**ការណែនាំ៖** សូមលោក-លោកស្រីគូសសញ្ញា (✓)ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមកម្រិតនៃការយល់ស្របរបស់លោក-លោកស្រី

១៥.តើលោក-លោកស្រីគិតថាបុគ្គលិកអប់រំនៅវិទ្យាស្ថានមានទំនួលខុសត្រូវ(គោរពពេលវេលា)បានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៦.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤មានការរៀបចំសមស្របសមត្ថភាព និងពង្រីកវិសាលភាពនៃការបង្រៀននិងរៀនបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៧.តើលោក-លោកស្រីមានការពិនិត្យតាមដានលើដំណើរការបង្រៀនរបស់គ្រូឧទ្ទេសជាប្រចាំបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៨.តើលោក-លោកស្រីមានការប្រើប្រាស់បច្ចេកទេសក្នុងការវាយតម្លៃការបង្រៀន និងរៀនបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

១៩.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ មាននិរន្តភាពក្នុងការអនុវត្តបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

២០.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ មានទំនាក់ទំនងជាមួយខ្លឹមសារមេរៀនឯកទេស និងវិធីសាស្ត្រផ្សេងបានកម្រិតណា?

□ សមស្របណាស់ □ សមស្រប □ មិនសមស្រប □ មិនសមស្របទាល់តែសោះ

២១.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ មានការជំរុញ និងលើកទឹកចិត្តគ្រូ-សិស្សក្នុងការចូលរួមជាអតិបរមាក្នុងមេរៀននីមួយៗបានកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

២២.តើលោក-លោកស្រីគិតថាកម្មវិធីសិក្សា១២+៤ មានភាពងាយស្រួលក្នុងការប្រើបច្ចេកទេសក្នុងការវាយតម្លៃការសិក្សារបស់សិស្សបានកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

២៣.តើលោក-លោកស្រីមានចំណាប់អារម្មណ៍ក្នុងការអភិវឌ្ឍសមត្ថភាពប្រកបដោយគុណភាពតាមរយៈ ការសង្កេត និងការវាយតម្លៃបានកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

២៤.តើលោក-លោកស្រីបានចែករំលែកចំណេះដឹងពីការបណ្តុះបណ្តាលដល់បុគ្គលិកវិទ្យាស្ថានបានកម្រិតណា?

▫ សមស្របណាស់ ▫ សមស្រប ▫ មិនសមស្រប ▫ មិនសមស្របទាល់តែសោះ

**ផ្នែកទី៥៖ បញ្ហាប្រឈម និងមតិយោបល់**

**ការណែនាំ៖** សូមលោក-លោកស្រីបំពេញទៅតាមទស្សនៈនៃការយល់ឃើញផ្ទាល់

២៥. សូមលោក-លោកស្រីរៀបរាប់អំពីជំនាញផ្ទាល់ខ្លួនរបស់គ្រូឧទ្ទេសដែលទទួលបានពីការអនុវត្តកម្មវិធីសិក្សា១២+៤ដែលកំពុងប្រើប្រាស់។

.............................................................................................................................................

.............................................................................................................................................

២៦. សូមលោក-លោកស្រីរៀបរាប់អំពីចំណុចខ្លាំង និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងការបង្រៀន និងរៀននៃកម្មវិធីសិក្សានេះ

..............................................................................................................................................

..............................................................................................................................................

២៧. សូមលោក-លោកស្រីរៀបរាប់នូវចំណុចខ្លាំង និងបញ្ហាប្រឈមនៃការរៀបចំផែនការបង្រៀនរបស់កម្មវិធីសិក្សានេះ។

..............................................................................................................................................

..............................................................................................................................................

២៨.តើលោក-លោកស្រីបានផ្តល់ឱកាសដល់គ្រូឧទ្ទេសក្នុងការអភិវឌ្ឍសមត្ថភាពតាមរយៈអ្វីខ្លះ?

..............................................................................................................................................

.............................................................................................................................................

២៩.សូមលោក-លោកស្រីរៀបរាប់ពីប្រសិទ្ធភាពនិងបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា១២+៤សិក្សាថ្មីនេះ។

..............................................................................................................................................

..............................................................................................................................................

៣០.តើលោក-លោកស្រីបានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះក្នុងអំឡុងពេលចាប់ផ្តើមអនុវត្តកម្មវិធីសិក្សា១២+៤រហូតមកដល់ពេលបច្ចុប្បន្ននេះ?

..............................................................................................................................................

.............................................................................................................................................

៣១.ពេលជួបការលំបាកខាងលើតើលោក-លោកស្រីបានដោះស្រាយយ៉ាងដូចម្តេចខ្លះ?

.....................................................................................................................................................

....................................................................................................................................................

៣២.តើលោក-លោកស្រីគិតថាគ្រូគ្រូឧទ្ទេសត្រូវបន្ថែមជំនាញអ្វីទៀតសម្រាប់បំពេញនូវជំនាញវិជ្ជាជីវៈរបស់គ្រូឧទ្ទេសនាពេលអនាគត ?

.....................................................................................................................................................

.....................................................................................................................................................

